SBILH

ធនាគារ អេស ប៊ី អាយ លី ហួរ
SBI LY HOUR Bank

# របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ២០២៤




បណ្ណវីសា
ពហុរូបិយប័ណ្ណ

ធនាគារមានភាពច្នៃប្រឌិត
និងគួរឱ្យទុកចិត្ត ដើម្បីភាពរីកចម្រើន

# មាតិកា


១. ចំណាប់អារម្មណ៍ប្រធានក្រុមប្រឹក្សាភិបាល 0១

២. ចំណាប់អារម្មណ៍អគ្គនាយក 0៣

៣. ទិន្នន័យសំខាន់ៗ 0៥

៤. អំពីធនាគារ 0៨

- ៤.១ ប្រវត្តិធនាគារ 0៩
- ៤.២ បេសកកម្ម ទស្សនវិស័យ ពាក្យស្លោក និង វប្បធម៌រួម 0៩
- ៤.៣ រចនាសម្ព័ន្ធគណៈគ្រប់គ្រង ១១

៥. ក្រុមប្រឹក្សាភិបាល ១៣

៦. គណៈគ្រប់គ្រងជាន់ខ្ពស់ ២៣

៧. អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង ៣២

- ៧.១ សេចក្តីផ្តើម ៣៣
- ៧.២ ទសនវិស័យ ៣៣
- ៧.៣ បេសកកម្ម ៣៣
- ៧.៤ គោលបំណង ៣៤
- ៧.៥ វិសាលភាព ៣៤
- ៧.៦ លទ្ធផលការងារ ៣៤
- ៧.៧ ការរាយការណ៍ ៣៤

៨. ការគ្រប់គ្រងហានិភ័យ ៣៥

- ៨.១ ដំណើរការនៃការគ្រប់គ្រងហានិភ័យ ៣៧
- ៨.២ ចំណាត់ថ្នាក់ហានិភ័យ និងការគ្រប់គ្រង ៣៨
- ៨.៣ នាយកដ្ឋានប្រតិបត្តិតាម ៣៩

៩. អគ្គនាយកដ្ឋានធនធានមនុស្ស ៤១

១០. ទំនួលខុសត្រូវការងារសង្គម ៤៣

១១. ផលិតផល និងសេវាកម្ម ៤៦

- ១១.១ ឥណទាន ៤៧
- ១១.២ ភិតិសន្យា ៤៧
- ១១.៣ ប្រាក់បញ្ញើ និងសន្សំ ៤៧
- ១១.៤ ធនាគារព្រីមៀរ ៤៨
- ១១.៥ ផ្ទេរប្រាក់ ៤៨

១២. ធនាគារ ឌីជីថល ៥0

- ១២.១ អេធីអឹម ៥១
- ១២.២ កម្មវិធីធនាគារចល័ត ៥៣
- ១២.៣ បញ្ជរ QR ៥៤
- ១២.៤ បណ្ណធនាគារ អេស ប៊ី អាយ លី ហួរ ៥៥

១៣. របាយការណ៍ហិរញ្ញវត្ថុ ៦0

- ១៣.១ របាយការណ៍ក្រុមប្រឹក្សាភិបាល ៦១
- ១៣.២ របាយការណ៍សវនករឯករាជ្យ ៦៥
- ១៣.៣ របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ៦៩
- ១៣.៤ របាយការណ៍ចំណេញ-ខាត និងលទ្ធផលលម្អិតផ្សេងៗ ៧0
- ១៣.៥ របាយការណ៍បម្រែបម្រួលមូលធន ៧១
- ១៣.៦ របាយការណ៍លំហូរសាច់ប្រាក់ ៧៣

១៤. បណ្តាញការិយាល័យសាខា ៧៥

- ១៤.១ បណ្តាញសាខា ៧៧



# ចំណាប់អារម្មណ៍ប្រធានក្រុមប្រឹក្សាភិបាល

**សូមគោរពភាគីពាក់ព័ន្ធទាំងអស់ជាទីរាប់អាន!**

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ និងមានមោទនភាពក្នុងការបង្ហាញរបាយការណ៍ប្រចាំឆ្នាំ២០២៤ របស់ធនាគារ។ ឆ្នាំនេះ ជាឆ្នាំដែលពោរពេញទៅដោយភាពរឹងមាំ ការច្នៃប្រឌិត និងការរីកចម្រើន ប្រកបដោយភាពធន់ និងស្ថេរភាព។ បើពិនិត្យមើលនូវព្រឹត្តិការណ៍ក្នុងឆ្នាំកន្លងមក ធនាគាររបស់យើងមិនត្រឹមតែបានឆ្លងកាត់ការលំបាកនៃស្ថានភាពសេដ្ឋកិច្ចដែលមានភាពផ្លាស់ប្តូរប៉ុណ្ណោះទេ ធនាគារថែមទាំងបានកសាងភាពរឹងមាំ ភាពបត់បែន កាន់តែមានសមត្ថភាពក្នុងការផ្តល់សេវាជូនអតិថិជន និងរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជាទាំងមូលផងដែរ។

ឆ្នាំ ២០២៤ គឺជាឆ្នាំដែលពោរពេញដោយបញ្ហាប្រឈម និងឱកាស។ ស្ថានភាពសេដ្ឋកិច្ចពិភពលោក និងក្នុងតំបន់នៅតែមានភាពមិនប្រាកដប្រជា ដោយមានសម្ពាធអតិផរណា ភាពតានតឹងនៃភូមិសាស្ត្រនយោបាយ និងការផ្លាស់ប្តូរសក្តានុពលទីផ្សារ។ ទោះជាយ៉ាងណាក៏ដោយ សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាបានបង្ហាញពីភាពធន់គួរឱ្យកត់សម្គាល់ ដែលត្រូវបានគាំទ្រដោយតម្រូវការក្នុងស្រុកដ៏រឹងមាំ វិស័យទេសចរណ៍ដែលកំពុងងើបឡើងវិញ និងការបន្តកំណែទម្រង់របស់រាជរដ្ឋាភិបាល។

ជាមួយគ្នានេះ ធនាគារ អេស ប៊ី អាយ លី ហ្វូរ ម.ក សម្រេចបាននូវកំណើនហិរញ្ញវត្ថុគួរឱ្យកត់សម្គាល់ដូចខាងក្រោម៖

- ទ្រព្យសកម្មសរុបបានកើនឡើងដល់ជាង ១ ពាន់លានដុល្លារអាមេរិក ដែលបង្ហាញពីសញ្ញានៃភាពជោគជ័យ និងជាមូលដ្ឋានគ្រឹះសម្រាប់ការពង្រីក និងការអភិវឌ្ឍថ្មីៗនាពេលអនាគត។
- ប្រាក់កម្ចីសរុបកើនដល់ ៨២១ លានដុល្លារអាមេរិក និងអតិថិជនកម្ចីសរុបចំនួន ៤៩ ពាន់នាក់។
- ប្រាក់បញ្ញើសរុបមានចំនួន ៨២៨ លានដុល្លារអាមេរិក និងអតិថិជនប្រាក់បញ្ញើសរុបមានចំនួន ១៣៤ ពាន់នាក់។
- បុគ្គលិកសរុបមានចំនួន ១.៣៩៤ នាក់ ដែលបង្កើតជាកម្លាំងការងារដ៏រឹងមាំក្នុងការគាំទ្រដល់គោលដៅយុទ្ធសាស្ត្ររបស់ធនាគារ។
- ប្រាក់ចំណេញសុទ្ធបន្ទាប់ពីបង់ពន្ធ រហូតដល់ ៧,៦ លានដុល្លារអាមេរិក ដែលបង្ហាញពីសមត្ថភាពរបស់យើងក្នុងការរក្សាកំណើន និងប្រាក់ចំណេញ។

លទ្ធផលទាំងនេះគឺជាសក្ខីភាពមួយចំពោះភាពរឹងមាំនៃគំរូអាជីវកម្ម ការលះបង់របស់ក្រុមការងារ និងទំនុកចិត្តដែលបានផ្តល់ឱ្យធនាគារដោយអតិថិជន។

ស្របតាមចក្ខុវិស័យរបស់យើងក្នុងការក្លាយជាធនាគារឌីជីថលឈានមុខគេរបស់ប្រទេសកម្ពុជា យើងបានបោះជំហានយ៉ាងសំខាន់ ក្នុងការរីកចម្រើននូវគម្រោងប្រែក្លាយជាធនាគារឌីជីថល។ នៅឆ្នាំ២០២៤ យើងបានបើកដំណើរការសេវាកម្ម និងផលិតផលឌីជីថលជាច្រើន មានដូចជាបណ្ណវិសាពហុរូបិយប័ណ្ណ ប្រព័ន្ធធនាគារស្នូលថ្មីក្នុងដំណាក់កាលទី២ និងការអភិវឌ្ឍប្រព័ន្ធធនាគារចល័តឱ្យប្រសើរឡើង។ យើងក៏បានដាក់ពង្រាយម៉ាស៊ីនអេធីអឹមបន្ថែមទៀត និងបានសហការជាដៃគូជាមួយក្រុមហ៊ុនផ្ទេរប្រាក់ក្នុងស្រុក និងអន្តរជាតិជាច្រើន ដើម្បីបង្កើនភាពងាយស្រួល សុវត្ថិភាព និងប្រសិទ្ធភាពនៃសេវាហិរញ្ញវត្ថុសម្រាប់អតិថិជន។ ការវិនិយោគលើបច្ចេកវិទ្យាមិនត្រឹមតែផ្តល់បទពិសោធន៍ថ្មីជូនអតិថិជនកាន់តែប្រសើរឡើងប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងពង្រឹងភាពរឹងមាំក្នុងប្រតិបត្តិការផងដែរ ដែលធ្វើឱ្យមានភាពបត់បែនឆាប់រហ័សទៅតាមលក្ខខណ្ឌទីផ្សារដែលមានការផ្លាស់ប្តូរ។

ដោយយល់ឃើញថាសេដ្ឋកិច្ចកម្ពុជាមានសក្តានុពលសម្រាប់ការរីកចម្រើនបន្ត មានការលូតលាស់លើវិស័យនគរូបនីយកម្ម វិស័យបច្ចេកវិទ្យាឌីជីថល និងមានប្រជាជនភាគច្រើនជាយុវជនមានសមត្ថភាពខ្ពស់ ដូច្នេះធនាគារ អេស ប៊ី អាយ លី ហ្វូរ ម.ក បានប្តេជ្ញាក្នុងការប្រើនូវនិន្នាការទាំងនេះ ដើម្បីផ្តល់តម្លៃបន្ថែមទៅកាន់ភាគីពាក់ព័ន្ធ។ អាទិភាពជាយុទ្ធសាស្ត្ររបស់យើងសម្រាប់ឆ្នាំ២០២៥ និងឆ្ពោះទៅមុខរួមមាន ការធ្វើពិពិធកម្មលើការវិនិយោគ បង្កើនបទពិសោធន៍ល្អៗជូនអតិថិជន លើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ ពង្រឹងសុវត្ថិភាព បច្ចេកវិទ្យាព័ត៌មាន ការពង្រឹងភាពជាដៃគូ និងការសម្របខ្លួនទៅនឹងការផ្លាស់ប្តូរបទប្បញ្ញត្តិ។

ជាចុងបញ្ចប់ ខ្ញុំចង់បញ្ជាក់ឡើងវិញនូវការប្តេជ្ញាចិត្តចំពោះឧត្តមភាព ការច្នៃប្រឌិត និងនិរន្តរភាព។ យើងរួមគ្នាដើម្បីបន្តកសាងអនាគតដ៏ត្រចះត្រចង់ជូនអតិថិជន សហគមន៍ និងប្រទេសរបស់យើង ជាមួយទំនួលខុសត្រូវសង្គម។ សូមអរគុណចំពោះការជឿជាក់ និងការគាំទ្ររបស់អ្នកទាំងអស់គ្នា។

ដោយក្តីគោរព

**លោក Shuzo Shikata**

**ប្រធានក្រុមប្រឹក្សាភិបាល និងតំណាងភាគទុនិក**



# ចំណាប់អារម្មណ៍អគ្គនាយក

ភាគទុនិក អតិថិជន និងដៃគូសហការជាទីគោរព!

ខ្ញុំពិតជាមានសេចក្តីសោមនស្សរីករាយណាស់ក្នុងការបង្ហាញជូននូវរបាយការណ៍ប្រចាំឆ្នាំ២០២៤ របស់ធនាគារ។ សមិទ្ធផលឆ្នាំ២០២៤ របស់យើងគឺជាលទ្ធផលនៃការប្រឹងប្រែងរួមគ្នា ដោយមានការប្តេជ្ញាចិត្តពីក្រុមការងារបុគ្គលិកគ្រប់ជាន់ថ្នាក់ ការជឿទុកចិត្តពីអតិថិជន និងការគាំទ្រពីភាគីដែលពាក់ព័ន្ធ។ បន្ទាប់ពីការឆ្លងកាត់បរិយាកាសសេដ្ឋកិច្ចដែលមានភាពស្មុគស្មាញ និងលំបាកជាច្រើនមក ធនាគារបានព្យាយាមអភិវឌ្ឍខ្លួនឱ្យកាន់តែប្រសើរឡើងជាងមុន និងបានកំណត់បទដ្ឋានថ្មីរបស់ខ្លួននៅក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុ។ សមិទ្ធផលរបស់ធនាគារមានក្នុងថ្ងៃនេះគឺជាសក្ខីភាព ដែលឆ្លុះបញ្ចាំងពីការសហការជាក្រុមរបស់បុគ្គលិកគ្រប់ជាន់ថ្នាក់របស់ធនាគារស្របតាមចក្ខុវិស័យ និងគោលដៅរួមតែមួយ។

បរិបទសេដ្ឋកិច្ចអន្តរជាតិកាលពីឆ្នាំមុន មានការប្រឈមនឹងការប្រែប្រួលនៅក្នុងទីផ្សារយ៉ាងខ្លាំង ជាមួយនឹងការផ្លាស់ប្តូរបែបបទក្របខ័ណ្ឌបទដ្ឋានត្រួតពិនិត្យផងដែរ។ ឧបសគ្គទាំងនេះបានបង្កើតបរិយាកាសពិបាកនឹងព្យាករ សម្រាប់អាជីវកម្មនៅទូទាំងពិភពលោក។ ទោះបីជាមានឧបសគ្គទាំងឡាយក៏ដោយ សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាបានបង្ហាញពីភាពធន់គួរឱ្យកត់សម្គាល់ ដោយសម្របខ្លួនទៅនឹងការផ្លាស់ប្តូរ ព្រមទាំងរក្សាបាននូវគន្លងកំណើនសេដ្ឋកិច្ចប្រកបដោយស្ថិរភាព។ យោងតាមធនាគារអភិវឌ្ឍន៍អាស៊ី (ADB) សេដ្ឋកិច្ចរបស់កម្ពុជាត្រូវបានព្យាករណ៍ថានឹងកើនឡើងដល់ ៥,៨% នៅឆ្នាំ ២០២៤ និង ៦,0% នៅឆ្នាំ២០២៥។ ភាពធន់ និងសមត្ថភាពសម្របខ្លួននេះ ជាភស្តុតាងបញ្ជាក់ពីក្របខ័ណ្ឌសេដ្ឋកិច្ចដ៏រឹងមាំ និងអាចសម្របខ្លួនបានយ៉ាងល្អរបស់ប្រទេសកម្ពុជា។



ម្យ៉ាងវិញទៀត អំឡុងឆ្នាំ២០២៤ ធនាគារ អេស ប៊ី អាយ លី ហួរ ម.ក បានសម្របខ្លួននឹងការផ្លាស់ប្តូរបទប្បញ្ញត្តិថ្មី ជាមួយការប្រែប្រួលទីផ្សារ ដោយប្តូរមកវិញជាមួយការទទួលយកបច្ចេកវិទ្យាថ្មីៗ និងដើម្បីបង្កើនយុទ្ធសាស្ត្ររបស់ខ្លួន។ យើងបានពង្រឹងជំហរទីផ្សារ និងពង្រីកកេរ្តិ៍ឈ្មោះជាស្ថាប័នធនាគារ និងហិរញ្ញវត្ថុ ដែលមានភាពធន់ និងមានការរីកចម្រើនឆ្ពោះទៅមុខ។

គិតត្រឹមខែធ្នូ ឆ្នាំ២០២៤ យើងបានសម្រេចដំណាក់កាលសំខាន់ ដែលបានពង្រឹងគោលជំហរទីផ្សាររបស់យើងដូចខាងក្រោម៖

- **កំណើនផលប័ត្រឥណទាន៖** កើនឡើង ១៥% ពីឆ្នាំ២០២៣ ដល់ ៨២១ លានដុល្លារអាមេរិក ដែលបង្ហាញពីការប្តេជ្ញាចិត្តក្នុងការគាំទ្រអាជីវកម្មក្នុងស្រុក និងការរួមចំណែកដល់កំណើនសេដ្ឋកិច្ចរបស់ប្រទេស។
- **កំណើនផលប័ត្រប្រាក់បញ្ញើ៖** កើនឡើង ២៤% ពីឆ្នាំ២០២៣ ដល់ ៨២៨ លានដុល្លារអាមេរិក ដែលបង្ហាញពីការជឿទុកចិត្ត និងការគាំទ្រយ៉ាងខ្លាំងពីអតិថិជនចំពោះធនាគារ។
- **សេវាធនាគារឌីជីថល៖** ការដាក់ឱ្យប្រើប្រាស់បន្ថែមនូវម៉ាស៊ីន អេធីអឹម នៅទូទាំងប្រទេស និងការអភិវឌ្ឍឱ្យកាន់តែប្រសើរឡើងលើប្រព័ន្ធធនាគារស្នូលថ្មី និងហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យា ដែលបានផ្តល់ជូនបទពិសោធន៍ និងភាពងាយស្រួលដល់អតិថិជន។
- **ការពង្រីកបណ្តាញសាខា៖** ធនាគារបានពង្រីកបណ្តាញសាខាដល់ចំនួន ៤៩ សាខា ដែលនាំឱ្យសេវាកម្មរបស់យើងកាន់តែខិតទៅជិតអតិថិជនទូទាំងប្រទេស។

ក្រៅពីសមិទ្ធផលដែលបានរៀបរាប់ខាងលើ និរន្តរភាពអាជីវកម្មជាគោលដៅសំខាន់ក្នុងប្រតិបត្តិការ ដោយដឹកនាំការសម្រេចចិត្ត និងសកម្មភាពរបស់យើង។

ក្នុងឆ្នាំ២០២៤នេះ យើងបានបោះជំហានឆ្ពោះទៅមុខ ជាមួយការប្តេជ្ញាចិត្ត ចំពោះទំនួលខុសត្រូវក្នុងសង្គម ដោយអនុវត្តកម្មវិធីជាច្រើនដែលជះឥទ្ធិពលវិជ្ជមានលើសហគមន៍របស់យើង។ កម្មវិធីដែលធនាគារបានអនុវត្តបាននាំឱ្យមានការផ្លាស់ប្តូរជាច្រើននៅក្នុងសហគមន៍ តាមរយៈការផ្តោតលើការពង្រឹងចំណេះដឹងផ្នែកហិរញ្ញវត្ថុចំពោះអតិថិជនរបស់ធនាគារ។

សម្លឹងមើលទៅអនាគត ធនាគារនៅតែមានភាពវិជ្ជមានជាច្រើនចំពោះឱកាសដែលនៅចំពោះមុខយើង។ ធនាគារនឹងផ្តោតលើយុទ្ធសាស្ត្រដោយបែងចែកផ្នែកសំខាន់ៗមួយចំនួន ដើម្បីធានាបាននូវកំណើនប្រកបដោយនិរន្តរភាព និងជោគជ័យបន្តដូចខាងក្រោម៖

- **ការអភិវឌ្ឍឌីជីថល៖** យើងនឹងបន្តវិនិយោគលើបច្ចេកវិទ្យាដែលទំនើប ថ្មី និងចុងក្រោយ ដើម្បីបង្កើនសមត្ថភាពសេវាធនាគារឌីជីថលរបស់យើង ដូចជាម៉ាស៊ីន អេធីអឹម សេវាធនាគារចល័ត និងសេវាធនាគារតាមអ៊ីនធឺណិតជាដើម។ គោលដៅរបស់យើងគឺផ្តល់បទពិសោធន៍ដែលសមស្របជាមួយតម្រូវការ ហើយមានសុវត្ថិភាពខ្ពស់ និងមានភាពងាយស្រួលសម្រាប់អតិថិជន ក្នុងការធ្វើប្រតិបត្តិការរបស់ធនាគារបានគ្រប់ទីកន្លែង និងរហ័សទាន់ចិត្ត។
- **វិធីសាស្ត្រផ្តោតលើអតិថិជន៖** យើងប្តេជ្ញាចិត្តក្នុងការស្វែងយល់ និងបំពេញតម្រូវការរបស់អតិថិជន តាមរយៈការប្រើប្រាស់ការវិភាគទិន្នន័យ និងមតិកែលម្អរបស់អតិថិជន។ យើងនឹងកែសម្រួលផលិតផល និងសេវាកម្ម ដើម្បីផ្តល់តម្លៃល្អបំផុត និងដំណោះស្រាយផ្ទាល់ខ្លួនរបស់អតិថិជន។
- **បរិយាបន្នហិរញ្ញវត្ថុ៖** យើងនឹងខិតខំពង្រីកបរិយាបន្នហិរញ្ញវត្ថុ ដល់សហគមន៍ឆ្ងាយៗឱ្យមានការចូលរួមប្រើប្រាស់សេវាហិរញ្ញវត្ថុ។ តាមរយៈផលិតផលហិរញ្ញវត្ថុឌីជីថលថ្មីៗ យើងមានបំណងបង្កើនសមត្ថភាពដែលជួយដល់អតិថិជន និងអាជីវកម្ម ដើម្បីសម្រេចបានតាមគោលដៅហិរញ្ញវត្ថុរបស់ខ្លួន។
- **ការកសាងសមត្ថភាពបុគ្គលិក៖** បុគ្គលិករបស់យើងគឺជាទ្រព្យសម្បត្តិដ៏មានតម្លៃ។ យើងនឹងវិនិយោគលើការរីកចម្រើន និងការអភិវឌ្ឍរបស់ពួកគេ ដើម្បីបង្កើតវប្បធម៌នៃភាពល្អឥតខ្ចោះ និងការច្នៃប្រឌិតថ្មីៗ ដោយផ្តល់ឱកាសសិក្សាអភិវឌ្ឍខ្លួនបន្ថែម យើងមានបំណងបង្កើតកម្លាំងការងារដែលមានជំនាញខ្ពស់ និងមានការលើកទឹកចិត្តខ្ពស់។

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះភាហ៊ុនិក សម្រាប់ការជឿជាក់ និងទំនុកចិត្តដែលបានផ្តល់ឱ្យយើង។ សូមថ្លែងអំណរគុណចំពោះអតិថិជនសម្រាប់ភាពស្មោះត្រង់ និងការគាំទ្រដល់យើង និងថ្លែងអំណរគុណចំពោះបុគ្គលិកទាំងអស់សម្រាប់ការខិតខំប្រឹងប្រែង និងការឧស្សាហ៍ព្យាយាមជាមួយគ្នា។ យើងនឹងបន្តស្ថាបនាអនាគតដ៏ភ្លឺស្វាងសម្រាប់ធនាគារ អេស ប៊ី អាយ លី ហួរ ម.ក និងសហគមន៍របស់យើង។

ដោយក្តីគោរព

**លោក ជា ផល្លារិន**

**អគ្គនាយក**

# ៣. ទិន្នន័យសំខាន់ៗ

## សង្ខេបតារាងតុល្យការ (គិតជាលានដុល្លារអាមេរិក)

### ទ្រព្យសកម្មសរុប

| | |
|---|---|
| ២០២៤ | ១.០៩១ |
| ២០២៣ | ៩០៤ |

↑ ១.០៩១
ទិន្នន័យក្នុងឆ្នាំ ២០២៤

### ផលបត្រប្រាក់កម្ចី

| | |
|---|---|
| ២០២៤ | ៨១០ |
| ២០២៣ | ៧១២ |

↑ ៨១០
ទិន្នន័យក្នុងឆ្នាំ ២០២៤

### ប្រាក់បញ្ញើសរុប

| | |
|---|---|
| ២០២៤ | ៨២៨ |
| ២០២៣ | ៦៦៥ |

↑ ៨២៨
ទិន្នន័យក្នុងឆ្នាំ ២០២៤

### មូលធនសរុប

| | |
|---|---|
| ២០២៤ | ១២៣ |
| ២០២៣ | ១១៦ |

↑ ១២៣
ទិន្នន័យក្នុងឆ្នាំ ២០២៤

## សង្ខេបរបាយការណ៍ចំណេញខាត (គិតជាពាន់ដុល្លារអាមេរិក)

### ចំណូលការប្រាក់សុទ្ធ

| | |
|---|---|
| ២០២៤ | ៤២.៨២៨ |
| ២០២៣ | ៣៥.១៦១ |

↑ ៤២.៨២៨
ទិន្នន័យក្នុងឆ្នាំ ២០២៤

### ចំណូលផ្សេងៗសុទ្ធ

| | |
|---|---|
| ២០២៤ | ១.៦៩០ |
| ២០២៣ | ៦៥១ |

↑ ៩០៤
ទិន្នន័យក្នុងឆ្នាំ ២០២៤

### ប្រាក់ចំណេញសុទ្ធ

| | |
|---|---|
| ២០២៤ | ៧.៦១១ |
| ២០២៣ | ៣.៣៨៥ |

↑ ៧.៦១១
ទិន្នន័យក្នុងឆ្នាំ ២០២៤

## សូចនាករសំខាន់ៗ (គិតជាភាគរយ)

### ប្រាក់ចំណេញសុទ្ធធៀបនឹងមធ្យមភាគទ្រព្យសកម្មសរុប

| | |
|---|---|
| ២០២៤ | ០.៧០% |
| ២០២៣ | ០.៣៧% |

↑ ០.៧០%
ទិន្នន័យក្នុងឆ្នាំ ២០២៤

### ប្រាក់ចំណេញសុទ្ធធៀបនឹងមូលធន

| | |
|---|---|
| ២០២៤ | ៦.១៧% |
| ២០២៣ | ២.៩៣% |

↑ ៦.១៧%
ទិន្នន័យក្នុងឆ្នាំ ២០២៤

### ទ្រព្យសកម្មងាយស្រួល

| | |
|---|---|
| ២០២៤ | ១៨.០១% |
| ២០២៣ | ១២.២៣% |

↑ ១៨.០១%
ទិន្នន័យក្នុងឆ្នាំ ២០២៤

### អនុបាតទិន្នផលដុលសរុប

| | |
|---|---|
| ២០២៤ | ៩.៣០% |
| ២០២៣ | ៩.០១% |

↑ ៩.៣០%
ទិន្នន័យក្នុងឆ្នាំ ២០២៤

## ព័ត៌មានទូទៅ

### ចំនួនសាខា
គិតជាអគារ

| | |
|---|---|
| ២០២៤ | ៥០ |
| ២០២៣ | ៥០ |

↑ ៥០
ទិន្នន័យក្នុងឆ្នាំ ២០២៤

### ចំនួនបុគ្គលិកសរុប
គិតជានាក់

| | |
|---|---|
| ២០២៤ | ១.៣៩៤ |
| ២០២៣ | ១.៤២៦ |

↑ ១.៣៩៤
ទិន្នន័យក្នុងឆ្នាំ ២០២៤

### ចំនួនឥណទាន
លានដុល្លារអាមេរិក

| | |
|---|---|
| ២០២៤ | ៥៤.៧៦១ |
| ២០២៣ | ៤៥.៨៧៤ |

↑ ៥៤.៧៦១
ទិន្នន័យក្នុងឆ្នាំ ២០២៤

### ចំនួនអតិថិជន ដាក់ប្រាក់បញ្ញើ
គិតជានាក់

| | |
|---|---|
| ២០២៤ | ១៣៤.៤៤២ |
| ២០២៣ | ១០៦.០៣៧ |

↑ ១៣៤.៤៤២
ទិន្នន័យក្នុងឆ្នាំ ២០២៤




ក្រុមហ៊ុន អេស ប៊ី អាយ ហូលឌីង
ប្រទេសជប៉ុន

ធនាគារ អេស ប៊ី អាយ លី ហួរ ម.ក
ប្រទេសកម្ពុជា



# ៤. អំពីធនាគារ

៤.១ ប្រវត្តិធនាគារ ០៩
៤.២ បេសកកម្ម ទស្សនវិស័យ ពាក្យស្លោក និង វប្បធម៌រួម ០៩
៤.៣ រចនាសម្ព័ន្ធគណៈគ្រប់គ្រង ១១




## ៤.១ ប្រវត្តិធនាគារ

ធនាគារ អេស ប៊ី អាយ លី ហួរ ម.ក គឺជាការសហវិនិយោគរួមគ្នារវាង លោកអ្នកឧកញ៉ា លី ហួរ និងក្រុមហ៊ុន អេស ប៊ី អាយ ហូលឌីង។ ធនាគារ អេស ប៊ី អាយ លី ហួរ ម.ក គឺជាធនាគារចុះបញ្ជីផ្លូវការត្រឹមត្រូវតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

ចក្ខុវិស័យរបស់ធនាគារគឺផ្តល់ជូននូវអាជីវកម្មធនាគារពាណិជ្ជកម្មដល់ បុគ្គល សហគ្រាសធុនតូច និងមធ្យម ក្រុមហ៊ុន និងសាជីវកម្មជាទូទៅដើម្បីចូលរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចសង្គមនៅក្នុងប្រទេសកម្ពុជា និងកន្លែងផ្សេងទៀតដែលអនុវត្តដោយធនាគារពាណិជ្ជកម្មអន្តរជាតិទាំងអស់។ គោលបំណងគឺដើម្បីជួយដល់ប្រទេសកម្ពុជា អាជីវកម្ម និងប្រជាជនកម្ពុជាដើម្បីលើកកម្ពស់ជីវភាពរស់នៅ និងការរីកចម្រើនអាជីវកម្ម ដោយផ្តល់ជូននូវសេវាធនាគារដែលមានជំនាញវិជ្ជាជីវៈច្បាស់លាស់ បច្ចេកវិទ្យា ជឿនលឿន ការផ្តល់ហិរញ្ញប្បទានដែលមានតម្លៃសមរម្យ និងនាំមកនូវបច្ចេកវិទ្យាហិរញ្ញវត្ថុចុងក្រោយដើម្បីផ្តល់បទពិសោធន៍របស់អ្នកប្រើប្រាស់កាន់តែងាយស្រួល និងទាក់ទាញ។

## ៤.២ បេសកកម្ម ទស្សនវិស័យ ពាក្យស្លោក និង វប្បធម៌រួម

**បេសកកម្ម៖** ធនាគារឈានមុខគេប្រកបដោយការជឿជាក់ ជាមួយនវានុវត្តន៍ហិរញ្ញវត្ថុ តាមរយៈការបន្តអភិវឌ្ឍខ្លួនប្រកបដោយទំនួលខុសត្រូវផ្នែកសង្គម។

**ទស្សនវិស័យ៖** ជម្រុញ និងលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុតាមរយៈប្រព័ន្ធធនាគារឌីជីថលដ៏ទំនើបប្រតិបត្តិការធនាគារដែលមានទំនុកចិត្ត និងបណ្តាញភ្នាក់ងារក្នុងព្រះរាជាណាចក្រកម្ពុជា។

**ពាក្យស្លោក៖** ធនាគារមានភាពច្នៃប្រឌិត និងគួរឱ្យទុកចិត្ត ដើម្បីភាពរីកចម្រើន។

**វប្បធម៌រួម៖**

- **សុចរិតភាព៖** យើងទាំងអស់គ្នាគប្បី ប្រកាន់យកនូវភាពស្មោះត្រង់ក្នុងការបំពេញភារកិច្ច មិនមានការភូតកុហកមិនមានពុតត្បុតក្នុងការងារ មិនពុករលួយ មិនកេងបន្លំទ្រព្យសម្បត្តិរបស់ធនាគារឡើយ។
- **សហប្រតិបត្តិការ៖** គ្រប់បុគ្គលិកយើងទាំងអស់គ្នា គប្បីមានស្មារតីជាក្រុមក្នុងការសម្រេចគោលដៅការងាររបស់យើង និងផ្តល់សេវាកម្មដ៏ទាក់ទាញជូនគ្រប់ភាគីពាក់ព័ន្ធរបស់យើងគ្រប់ពេលវេលា មិនមើលបំណាំគ្នានៅពេលមានភាពចាំបាច់។
- **ការទទួលខុសត្រូវ៖** សំដៅលើការហ៊ានទទួលខុស និងត្រូវនូវរាល់ទង្វើរបស់ខ្លួន ។ ជារឿយៗ យើងគប្បីចាត់ទុកថាការងារនេះ ជារបស់ខ្លួនឯង ត្រូវមានការប្រុងប្រយ័ត្ន លើការបាត់បង់ ការទទួលផល ហើយធ្វើយ៉ាងណាឱ្យល្អអស់ពីសមត្ថភាពដែលអាចធ្វើបាន (DAPO) ។ បើមានកំហុស ត្រូវរៀនសូត្រពីវា និងចៀសវាងកុំឱ្យមានកំហុសច្រំដែល។
- **អតិថិជនជាចម្បង៖** បង្ហាញសមត្ថភាពវិជ្ជាជីវៈការងារខ្ពស់ លើផលិតផលនានា និងសេវាកម្មពេញលេញជូនអតិថិជនដោយទំនុកចិត្ត។
- **ភាពជាអ្នកដឹកនាំ៖** អ្នកដឹកនាំ បង្កើតអ្នកដឹកនាំច្រើននាក់ទៀត មានន័យថាគ្រប់គ្នាត្រូវមានគំនិតច្នៃប្រឌិតខ្ពស់ និងធ្វើឱ្យការងាររបស់ខ្លួនមានវឌ្ឍនភាព និងសម្រេចបានទៅតាមផែនការដែលបានកំណត់។
- **មិនប្រកាន់បក្សពួក៖** ក្នុងការងារប្រតិបត្តិ ការសម្រេចចិត្តនានា ការលើកទឹកចិត្ត ការពិន័យឬស្តីបន្ទោស ត្រូវផ្អែកលើគោលការណ៍របស់ធនាគារ មិនមែនផ្អែកលើទំនាក់ទំនងមិត្តភក្តិ បងប្អូន និន្នាការនយោបាយ សាសនា ពូជសាសន៍ឡើយ។
- **ផលិតភាពខ្ពស់ និងប្រកបដោយគុណភាព៖** យើងគោរព និងឱ្យតំលៃខ្ពស់ទៅលើការខិតខំប្រឹងប្រែងរបស់បុគ្គលិកណាម្នាក់ ឬជាក្រុមដែលសម្រេចបានការងារច្រើន និងប្រកបដោយគុណភាព (ធ្វើបានល្អ បានស្អាត បានរឹងមាំ បានលឿន ចំណាយមានប្រសិទ្ធភាព និងធានាបាននូវភាពប្រឈមចំពោះបញ្ហានានាពេលខាងមុខ។ល។)
- **ការគោរព និងរួសរាយរាក់ទាក់៖** មានន័យថា រាល់ទង្វើដែលយើងធ្វើ រាល់ពាក្យសំដី អាកប្បកិរិយារវាងបុគ្គលិក និងបុគ្គលិក ថ្នាក់ដឹកនាំដោយមិនប្រកាន់ឋានៈ ឬជាមួយអតិថិជនក្តី យើងត្រូវប្រកាន់ជាប់ជានិច្ចនូវការគោរពគ្នាទៅវិញទៅមកដោយពាក្យសំដីសមរម្យ រួសរាយរាក់ទាក់ និងដោយភាពថ្លៃថ្នូរ។
- **ភាពក្លាហាន៖** យើងគប្បីមានភាពក្លាហានចូលរួមយោបល់ក្នុងការកែលំអ ឬផ្តល់ការទិតៀនស្ថាបនាគ្នាទៅវិញទៅមកដើម្បីការរីកចម្រើន។ត្រូវព្យាយាមស្វែងរកអ្វីថ្មី ដែលយើងអាចធ្វើបានល្អជាងមុន។
- **ឆន្ទៈមោះមុត៖** បង្ហាញពីភាពតស៊ូ ព្យាយាម ជំនះការលំបាក ធ្វើឱ្យសម្រេចបានការងារផងទាំងពួង ទោះជាមានតំរូវការលើសម៉ោងការងារខ្លះក្តី ដោយឈរលើស្មារតីជាវិជ្ជមាន។

# ៤.៣ រចនាសម្ព័ន្ធគណៈគ្រប់គ្រង



# ៥. ក្រុមប្រឹក្សាភិបាល


- លោក Shuzo Shikata ១៥
- លោក Makoto Miyazaki ១៦
- លោក Eiichiro So ១៧
- អ្នកឧកញ៉ា លី សុភ័ក្ត ១៨
- អ្នកឧកញ៉ា លី សុភាព ១៩
- លោក ខែក រ៉ាវី ២០
- លោក ហួរ វរៈបុត្ត ២១
- លោកស្រី Wan Chi Ng ២២






## លោក Shuzo Shikata

ប្រធានក្រុមប្រឹក្សាភិបាល និងតំណាងភាគទុនិក

លោក Shuzo Shikata ត្រូវបានតែងតាំងជាប្រធានក្រុមប្រឹក្សាភិបាលនៃធនាគារ អេស ប៊ី អាយ លី ហ្ស ម.ក នៅខែមករា ឆ្នាំ២០២៣។ លោកក៏ជាអ្នកតំណាងភាគហ៊ុនិករបស់ក្រុមហ៊ុន អេស ប៊ី អាយ ហូលឌីង ដែលមានអាសយដ្ឋាននៅទីក្រុងតូក្យូ ប្រទេសជប៉ុន។

សព្វថ្ងៃនេះ លោកកំពុងបម្រើការងារ ជាអនុប្រធានក្រុមប្រឹក្សាភិបាលនៃធនាគារ Tien Phong Commercial Bank នៅទីក្រុងហូជីមិញ ប្រទេសវៀតណាម។ លោក Shikata ធ្លាប់ធ្វើការនៅធនាគារ MUFG ដ៏ធំមួយ នៅទីក្រុងតូក្យូ ប្រទេសជប៉ុន មុនពេលលោកចូលបម្រើការងារនៅប្រទេសកម្ពុជា និងប្រទេសវៀតណាម។ ក្នុងនាមជាអ្នកឯកទេសក្នុងវិស័យសាជីវកម្ម និងធនាគារ វិនិយោគ លោកបានចូលរួមកាន់តួនាទីសំខាន់ៗជាច្រើន នៅក្នុងការពង្រឹងប្រព័ន្ធអភិបាលកិច្ចល្អ និងការគ្រប់គ្រងឱ្យមានតម្លាភាពនៅក្នុងធនាគារ អេស ប៊ី អាយ លី ហ្ស ម.ក។

ដោយមានបទពិសោធន៍យ៉ាងច្រើននៅក្នុងការដឹកនាំ គ្រប់គ្រងធនាគារនៅបរទេស ខ្លួនលោកផ្ទាល់ ព្រមទាំងក្រុមហ៊ុន អេស ប៊ី អាយ ហូលឌីង បាននឹងកំពុងជួយជ្រោមជ្រែងធនាគារ អេស ប៊ី អាយ លី ហ្ស ម.ក ក្នុងការរៀបចំ និងអនុវត្តនូវយុទ្ធសាស្ត្រសាជីវកម្មរបស់ធនាគារបានយ៉ាងល្អប្រសើរ។

លោក Shikata បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកសេដ្ឋកិច្ច ពីសាកលវិទ្យាល័យ Ritsumeikan នៃប្រទេសជប៉ុន។



## លោក Makoto Miyazaki

សមាជិកក្រុមប្រឹក្សាភិបាល

លោក Makoto Miyazaki មានបទពិសោធន៍ជាង២០ឆ្នាំ ក្នុងការដឹកនាំគ្រប់គ្រងជាន់ខ្ពស់នៅក្រុមហ៊ុន អេស ប៊ី អាយ ហូលឌីង និង ក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុនដ៏ធំនេះ ហើយសព្វថ្ងៃនេះ លោកជានាយកប្រតិបត្តិមួយរូបនៃក្រុមហ៊ុន អេស ប៊ី អាយ ហូលឌីង ដោយលោកមានតួនាទីដឹកនាំនាយកដ្ឋានគ្រប់គ្រង ពាណិជ្ជកម្មក្រៅប្រទេស។ លោកក៏កាន់តួនាទីធំៗមួយចំនួនទៀតដែរ ដូចជាអភិបាល អភិបាលមិនប្រតិបត្តិ ប្រធានក្រុមប្រឹក្សាភិបាល និងប្រធាន (President) នៃក្រុមហ៊ុនធំៗ ផ្សេងៗទៀត ដែលជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុន អេស ប៊ី អាយ ហូលឌីង។ លោក Miyazaki មានតួនាទីជាអភិបាល នៅតាមបណ្ដាក្រុមហ៊ុនបុត្រសម្ព័ន្ធ និងក្រុមហ៊ុនវិនិយោគផលប័ត្រជាច្រើនទៀត។

លោក Miyazaki បានចាប់ផ្ដើមអាជីពការងារដំបូងរបស់គាត់ជាមួយក្រុមហ៊ុន អេស ប៊ី អាយ ហូលឌីង ជានាយកប្រតិបត្តិប្រចាំការិយាល័យតំណាងទីក្រុងប៉េកាំងកាលពីឆ្នាំ២០០៥ រហូតដល់ ឆ្នាំ២០១២។ បន្ទាប់មកលោកក៏ត្រូវបានតែងតាំងជានាយកប្រតិបត្តិ ដឹកនាំនាយកដ្ឋានគ្រប់គ្រងពាណិជ្ជកម្មក្រៅប្រទេសរហូតមកដល់សព្វថ្ងៃនេះ។ នាយកដ្ឋានគ្រប់គ្រងពាណិជ្ជកម្មក្រៅប្រទេស គឺជានាយកដ្ឋានដែលទទួលខុសត្រូវក្នុងការគ្រប់គ្រង និងដឹកនាំការអភិវឌ្ឍរបស់បណ្ដាក្រុមហ៊ុនសម្ព័ន្ធទាំងឡាយដែលមានអាជីវកម្មចម្រុះ មានតាំងពីក្រុមហ៊ុនគ្រប់គ្រងមូលនិធិ ក្រុមហ៊ុនបណ្ដាក់ទុនសាជីវកម្ម (Corporate Venture Capital) និងក្រុមហ៊ុនគ្រប់គ្រងទ្រព្យសកម្មជាដើម ដែលមានទីតាំងនៅក្រៅប្រទេសជប៉ុន រួមមាន ប្រទេសអាល្លឺម៉ង់ ហុងកុង ម៉ាឡេស៊ី សាធារណរដ្ឋប្រជាមានិតចិន សិង្ហបុរី កូរ៉េខាងត្បូង ថៃ សហរដ្ឋអាមេរិក និងប្រទេសវៀតណាម។

លោក Miyazaki គឺជាអតីតនិស្សិតនៃសាកលវិទ្យាល័យ Western Oregon University នៃសហរដ្ឋអាមេរិក (ពីមុនត្រូវបានគេស្គាល់ជា Western Oregon State College) ជាកន្លែងដែលលោកបានទទួលបរិញ្ញាបត្រផ្នែកធុរកិច្ច។



## លោក Eiichiro So

សមាជិកក្រុមប្រឹក្សាភិបាល

លោក Eiichiro So បានចូលជាសមាជិកក្រុមប្រឹក្សាភិបាលកាលពី ខែធ្នូ ឆ្នាំ២០១៩។ លោកបានធ្វើការជាមួយក្រុមហ៊ុន អេស ប៊ី អាយ ហូលឌីង អស់រយៈពេលជាង ១៥ឆ្នាំ ហើយសព្វថ្ងៃនេះលោកជា សហនាយកប្រតិបត្តិ ជានាយកប្រតិបត្តិជាន់ខ្ពស់ និងអនុប្រធាននៃក្រុមហ៊ុន SBI Investment Korea Co., Ltd ដែលជាក្រុមហ៊ុនបណ្តាក់ដើមទុនសាជីវកម្ម (listed venture capital firm) ដែលបានចុះបញ្ជីក្នុងផ្សារភាគហ៊ុននៅទីផ្សារភាគហ៊ុនកូរ៉េឈ្មោះ KOSDAQ (Korean Securities Dealers Automated Quotations) ជាប្រធាននាយកប្រតិបត្តិរបស់ក្រុមហ៊ុន SBI Royal Security Plc.។

ជាមួយបទពិសោធន៍ជាង២៥ឆ្នាំ របស់លោកនៅក្នុងវិស័យធនាគារវិនិយោគ និងមូលធនឯកជន (Private Equity) ជាពិសេសបទពិសោធន៍នៅក្នុងទីផ្សារដែលកំពុងមានការរីកចម្រើនខ្លាំង (រួមមាន កូរ៉េខាងត្បូង សិង្ហបុរី និងកម្ពុជា) ដោយផ្តោតទៅលើវិស័យហិរញ្ញវត្ថុ (មានដូចជា ធនាគារ មូលបត្រ និងមូលធនឯកជន) លោកបានចូលរួមចំណែកយ៉ាងច្រើនទៅក្នុងការអភិវឌ្ឍអាជីវកម្ម និងបច្ចេកទេសគ្រប់គ្រងរបស់ធនាគារ។ ពីមុនមក លោកធ្លាប់ជាអនុប្រធាននៃធនាគារ Sumitomo Mitsui Banking Corporation ជាអភិបាលនៃធនាគារភ្នំពេញពាណិជ្ជ ជាអភិបាលប្រតិបត្តិនៃ ក្រុមហ៊ុន SBI Ven Capital Pte. Ltd (ប្រទេសសិង្ហបុរី) និងជាអភិបាលនៃ ក្រុមហ៊ុន FPT Securities (ប្រទេសវៀតណាម)។

លោក So បានបញ្ចប់ការសិក្សាកម្រិតថ្នាក់អនុបណ្ឌិតមកពីសាកលវិទ្យាល័យ Hitotsubashi ថ្នាក់ក្រោយឧត្តមសិក្សានៃនាយកដ្ឋានយុទ្ធសាស្ត្រសាជីវកម្មអន្តរជាតិ (ប្រទេសជប៉ុន) និងបរិញ្ញាបត្រផ្នែកគណនេយ្យ មហាវិទ្យាល័យពាណិជ្ជកម្ម ពីសាកលវិទ្យាល័យ Chuo (ប្រទេសជប៉ុន)។



## អ្នកឧកញ៉ា លី សុភ័ក្ត

សមាជិកក្រុមប្រឹក្សាភិបាល និងតំណាងភាគទុនិក

អ្នកឧកញ៉ា លី សុភ័ក្ត ជាសហគ្រិន និងជាអ្នកដឹកនាំធុរកិច្ចដ៏លេចធ្លោរមួយរូបនៅកម្ពុជា។ អ្នកឧកញ៉ា កើតនៅឆ្នាំ ១៩៧៨ ក្នុងខេត្តកំពង់ចាម។ ចាប់តាំងពីខែមករា ឆ្នាំ ២០២៣ មក អ្នកឧកញ៉ាមានតួនាទីជាអភិបាល នៃធនាគារ អេស ប៊ី អាយ លី ហួរ ម.ក ដែល អ្នកឧកញ៉ាបាននាំយកមកនូវបទពិសោធន៍ជាច្រើនមកកាន់វិស័យហិរញ្ញវត្ថុ។ លើសពីនេះ អ្នកឧកញ៉ា កាន់តំណែងជាអនុប្រធាននៃក្រុមហ៊ុន លី ហួរ គ្រុប និងជាប្រធានក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុនបុត្រសម្ព័ន្ធលើវិស័យហិរញ្ញវត្ថុ កសិកម្ម អចលនទ្រព្យ ការជួលរថយន្ត ធានារ៉ាប់រង និងប្រព័ន្ធផ្សព្វផ្សាយ។

ជាមួយបទពិសោធន៍ជាងពីរទសវត្សរ៍ក្នុងការគ្រប់គ្រងធុរកិច្ច អ្នកឧកញ៉ា លី សុភ័ក្ត ត្រូវបានគេស្គាល់ជាទូទៅដោយសារភាពដឹកនាំប្រកបដោយថាមពល និងទាក់ទាញរបស់អ្នកឧកញ៉ា ។ ចក្ខុវិស័យ និងការប្តេជ្ញាចិត្តរបស់អ្នកឧកញ៉ា បានជួយពង្រឹងវិស័យឯកជនរបស់កម្ពុជាយ៉ាងខ្លាំង ជំរុញកំណើនប្រកបដោយនិរន្តរភាព និងពង្រឹងការវិនិយោគក្នុងស្រុក។

ដោយមានចំណាប់អារម្មណ៍ខ្លាំងក្នុងការជំរុញការអភិវឌ្ឍជាតិ អ្នកឧកញ៉ា បន្តពង្រីកឥទ្ធិពលរបស់ខ្លួនតាមរយៈការវិនិយោគជាយុទ្ធសាស្ត្រ ជាពិសេសនៅក្នុងវិស័យហិរញ្ញវត្ថុ និងកសិកម្ម ដែលធ្វើឱ្យអ្នកឧកញ៉ា ក្លាយជាឥស្សរជនសំខាន់មួយរូបនៅក្នុងទិដ្ឋភាពសេដ្ឋកិច្ចរបស់កម្ពុជា។



## អ្នកឧកញ៉ា លី សុភាព

### សមាជិកក្រុមប្រឹក្សាភិបាល

មុនពេលត្រូវបានតែងតាំងជាអភិបាលប្រតិបត្តិនៃធនាគារ អេស ប៊ី អាយ លី ហួរ ម.ក អ្នកឧកញ៉ា លី សុភាព កាន់តំណែងសំខាន់ៗមួយចំនួនក្នុងការជម្រុញកំណើនអាជីវកម្មធនាគារ អ្នកឧកញ៉ាគ្រប់គ្រងអគ្គនាយកដ្ឋានប្រតិបត្តិការ ដោយគ្រប់គ្រងលើប្រតិបត្តិការប្រចាំថ្ងៃជូនទៅដល់អ្នកប្រើប្រាស់ចុងក្រោយ គ្រប់គ្រងខ្សែសង្វាក់ផ្គត់ផ្គង់ សកម្មភាពនៃការលក់ និងសេវាកម្មផ្សេងៗរបស់សាខាទូទាំង ២៥ រាជធានី-ខេត្ត រៀបចំផែនការទំនាក់ទំនងក្នុងការចែកចាយក្នុងការលក់បន្ត និងអ្នកផ្គត់ផ្គង់ ធានាបាននូវភាពបត់បែនក្នុងការឆ្លើយតបទៅនឹងតម្រូវការទីផ្សារដែលមានកំណើនកាន់តែខ្លាំងឡើង។ បន្ទាប់មកអ្នកឧកញ៉ាបានផ្លាស់ទៅគ្រប់គ្រងអគ្គនាយកដ្ឋានធនាគារពាណិជ្ជ ក្នុងការរៀបចំយុទ្ធសាស្ត្រប្រតិបត្តិការអាជីវកម្មធនាគារ ដឹកនាំ និងផ្តួចផ្តើមគំនិតក្នុងការប្រមូលប្រាក់បញ្ញើសន្សំពីសាធារណជនបានចំនួន ៥០០ លានដុល្លារ ត្រឹមតែក្នុងរយៈពេល១៨ខែ ចាប់ពីខែមេសា ឆ្នាំ២០២០ ដែលជាការចាប់ផ្តើមនៃវិបត្តិជំងឺកូវីដ១៩។ អ្នកឧកញ៉ាក៏ជាអ្នកដឹកនាំក្នុងនាយកដ្ឋានសំខាន់ៗផ្សេងទៀតដូចជា ផ្នែកពាណិជ្ជកម្មភតិសន្យា ទីផ្សារ និងទំនាក់ទំនង ឌីជីថល និងធនាគារព្រីមៀរ៍។

អ្នកឧកញ៉ាមានបទពិសោធន៍ក្នុងតំណែងជាថ្នាក់ដឹកនាំកំពូលសំខាន់ៗជាច្រើនដូចជា ប្រធានក្រុមប្រឹក្សាភិបាល ក្រុមហ៊ុន លី ហួរ ផេប្រូ នាយកប្រតិបត្តិ ក្រុមហ៊ុនរតនៈអលង្ការ ខូអិលធីឌី និងជានាយកគ្រប់គ្រងទូទៅក្រុមហ៊ុន លី ហួរ ប្តូរប្រាក់ផងដែរ។ លើសពីនេះទៅទៀត អ្នកឧកញ៉ាមានបទពិសោធន៍យ៉ាងជ្រាលជ្រៅក្នុងការក្នុងដឹកនាំកិច្ចពិភាក្សាធំៗទាំងក្នុង និងក្រៅប្រទេស ហើយលោកមានក៏មានបទពិសោធន៍ជាង២០ឆ្នាំក្នុងវិស័យហិរញ្ញវត្ថុថែមទៀតផង។

អ្នកឧកញ៉ា លី សុភាព ទទួលបានសញ្ញាប័ត្រជាច្រើនទាំងក្នុង និងក្រៅប្រទេស ក្នុងនោះលោកទទួលបានបរិញ្ញាបត្រកិត្តិយសផ្នែកពហុរចនាប្រព័ន្ធផ្សព្វផ្សាយ ពីសាកលវិទ្យាល័យក្នុងទីក្រុងនៃចក្រភពអង់គ្លេស ឆ្នាំ២០២៤។





## លោក ខៃក វ៉ារី

### សមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យ

លោក ខៃក វ៉ារី គឺជាអភិបាលឯករាជ្យមួយរូបនៅក្នុងក្រុមប្រឹក្សាភិបាលរបស់ធនាគារ អេស ប៊ី អាយ លី ហួរ ម.ក។ បច្ចុប្បន្នលោកជាប្រធានគណៈកម្មការតែងតាំង និងផ្តល់តម្លៃការ និងជាសមាជិកនៃគណៈកម្មការសវនកម្ម និងគណៈកម្មការត្រួតពិនិត្យហានិភ័យផងដែរ។

ក្នុងអំឡុងពេលនៃការងាររបស់លោក ចាប់ពីឆ្នាំ ១៩៨៥ ដល់ឆ្នាំ ២០១៩ លោក វ៉ារី បានកាន់នូវមុខតំណែងសំខាន់ៗជាច្រើន ដូចជាម្ចាស់ក្រុមហ៊ុន  នាយកក្រុមហ៊ុន ជាច្រើននៅប្រទេសបារាំង ប្រទេសសិង្ហបុរី និងប្រទេសកម្ពុជា។ លោកក៏ធ្លាប់ជាអនុរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មក្នុងរាជរដ្ឋាភិបាលកម្ពុជា (១៩៩៨-២០០៤)។

ក្នុងនាមជាអភិបាលឯករាជ្យ លោកបាននាំយកបទពិសោធន៍ជាច្រើន ពីតួនាទីរបស់លោកទាំងក្នុងវិស័យរដ្ឋាភិបាល និងវិស័យឯកជន រួមទាំងបទពិសោធន៍ជាអនុរដ្ឋមន្ត្រីនៅក្រសួងពាណិជ្ជកម្មនៅកម្ពុជាផងដែរ។



## លោក ហួរ វរៈបុត្គ

សមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យ

សព្វថ្ងៃនេះ លោក ហួរ វរៈបុត្គ គឺជាសាស្ត្រាចារ្យនៅវិទ្យាស្ថាន CamEd Business School និងជាទីប្រឹក្សាផ្នែកហិរញ្ញវត្ថុនិរន្តភាព នៅអង្គការ UNESCAP-GGGI ដោយបានពាំនាំនូវបទពិសោធន៍យ៉ាងក្រាស់ក្រែលប្រហែលជាង ២០ឆ្នាំ ក្នុងវិស័យសេវាហិរញ្ញវត្ថុ រួមជាមួយបទពិសោធន៍ផ្នែកអភិបាលកិច្ចក្រុមប្រឹក្សាភិបាល ជាច្រើនទសវត្សន៍ ក្នុងវិស័យជាច្រើនរួមមាន ធនាគារ ធានារ៉ាប់រងថាមពលកកើតឡើងវិញ និងអង្គការមិនស្វែងរកប្រាក់ចំណេញ នៅក្នុងតំបន់អឺរ៉ុប និងអាស៊ីប៉ាស៊ីហ្វិក។

លោកជាអតីតអភិបាលប្រចាំប្រទេសនៃក្រុមហ៊ុន The Blue Circle និងធ្លាប់ជាអ្នកគ្រប់គ្រងទូទៅនៅវិទ្យាស្ថានធនាគារ និងហិរញ្ញវត្ថុ (IBF) លោកក៏ធ្លាប់បម្រើការងារនៅស្ថាប័នហិរញ្ញវត្ថុធំៗនៅអឺរ៉ុបមានដូចជា Credit Suisse (ចំនួន ១២ឆ្នាំ) ក្រុមហ៊ុនគ្រប់គ្រងទ្រព្យសកម្ម Aberdeen Asset Management ក្រុមហ៊ុនធានារ៉ាប់រង AXA និងក្រុមហ៊ុន Banque Hottinguer។

លោកមានកម្រិតវប្បធម៌ថ្នាក់អនុបណ្ឌិតមកពីសាលាពាណិជ្ជកម្ម Chicago Booth school of Business ឆ្នាំ២០១២។ លោក ហួរ វរៈបុត្គ គឺជាអ្នកវិភាគហិរញ្ញវត្ថុដែលទទួលស្គាល់ដោយសហភាពអឺរ៉ុប ពីសាលា The European Federation of Financial Analyst Societies – EFFAS ហើយថ្មីៗនេះ លោកបានទទួលវិញ្ញាបនបត្រវគ្គសិក្សាអភិបាលសាជីវកម្ម ឆ្នាំ២០២០ ពីសាកលវិទ្យាល័យ Harvard Business School និងមានងារជា អភិបាលជាន់ខ្ពស់មានគុណវុឌ្ឍិ ពីវិទ្យាស្ថាន The Singapore Institute of Directors ឆ្នាំ២០២៤។



## លោកស្រី Wan Chi Ng

សមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យ

លោកស្រី Wan Chi Ng គឺជាគណនេយ្យករដែលមានបទពិសោធន៍ ជំនាញផ្នែកហិរញ្ញវត្ថុ ថវិកា និងរបាយការណ៍។ លោកស្រី បានគ្រប់គ្រងផ្នែកគ្រប់គ្រងហិរញ្ញវត្ថុនៅក្រុមហ៊ុន Allnison Auditing and Consulting និងជាសាស្ត្រាចារ្យនៅវិទ្យាស្ថាន CamEd Business School។ ជាមួយសាវតាផ្នែកសវនកម្មនៅក្រុមហ៊ុន PwC នៃទីក្រុង Montreal លោកស្រី បានទទួលសញ្ញាប័ត្របញ្ចប់ការសិក្សាផ្នែកគណនេយ្យសាធារណៈ និងអាចនិយាយ ភាសាបារាំង ចិនកាតាំង ចិនកុកងឺ និង ភាសាអង់គ្លេស។

# ៦. គណៈគ្រប់គ្រងជាន់ខ្ពស់


- លោក ជា ផល្លារិន ២៥
- លោក ម៉ៅ ប៉ូឡូ ២៥
- លោក ឡាយ សារ៉េត ២៦
- លោក កែណែម វីដាណូ ២៦
- លោក ហ៊ុម សីលា ២៧
- លោក ផាត់ រតនា ២៧
- លោក នី បូរ៉ាត ២៨
- លោក វ៉ា លួងសុរិន ២៨
- លោក ទ្រី វិសាល ២៩






## លោក ជា ផល្លារិន

### អគ្គនាយក

លោក ជា ផល្លារិន ត្រូវបានតែងតាំងជា អគ្គនាយក របស់ ធនាគារ អេស ប៊ី អាយ លី ហួរ ម.ក នៅថ្ងៃទី ១៧ ខែកុម្ភៈ ឆ្នាំ២០២៣។ មុនពេលនឹងចូលរួមបម្រើការងារជាមួយ ធនាគារ អេស ប៊ី អាយ លី ហួរ ម.ក លោក ផល្លារិន បានបម្រើការជាអគ្គនាយកជាង ២០ ឆ្នាំ នៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹត។

លើសពីនេះទៅទៀត លោកក៏ធ្លាប់បានបំពេញ តួនាទីជាសមាជិកក្រុមប្រឹក្សាភិបាល របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹត និងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា ថែមទាំងជា សមាជិក នៃក្រុមប្រឹក្សាភិបាលនៅក្នុងស្ថាប័នផ្សេងៗ ដូចជាធនាគារ អភិវឌ្ឍន៍ជនបទ និងការិយាល័យឥណទានកម្ពុជា (ស៊ីប៊ីស៊ី) ផងដែរ។

លោក ផល្លារិន បានបញ្ចប់ការសិក្សាថ្នាក់អនុបណ្ឌិតផ្នែកគ្រប់គ្រងពាណិជ្ជកម្មនៅសាកលវិទ្យាល័យ UTARA នៃប្រទេស ម៉ាឡេស៊ី បន្ទាប់បានបញ្ចប់បរិញ្ញាបត្រផ្នែកសេដ្ឋកិច្ចកសិកម្មនៅវិទ្យាស្ថានវិទ្យាសាស្ត្រសេដ្ឋកិច្ច នៅភ្នំពេញ។



## លោក ឡយ សារ៉េត

### អគ្គនាយករង

លោក ឡយ សារ៉េត មានបទពិសោធន៍ជាង១៨ឆ្នាំ ក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុ អង្គការអន្តរជាតិ និងក្នុងវិស័យអប់រំ។ លោកបានត្រឡប់ចូលបម្រើការងារឡើងវិញជាមួយ ធនាគារ អេស ប៊ី អាយ លី ហួរ ម.ក ជានាយកប្រតិបត្តិអាជីវកម្ម នៅខែវិច្ឆិកា ឆ្នាំ២០១៩ ហើយបន្ទាប់មកត្រូវបានតែងតាំងជា អគ្គនាយករង នៅថ្ងៃទី១ ខែមេសា ឆ្នាំ២០២២ រហូតមកដល់បច្ចុប្បន្ន។

មុនពេលចូលបម្រើការងារជាថ្មីនៅ ធនាគារ អេស ប៊ី អាយ លី ហួរ ម.ក លោក ឡយ សារ៉េត ធ្លាប់កាន់តួនាទីជានាយកប្រតិបត្តិជាន់ខ្ពស់នៅធនាគារប្រៃសណីយ៍កម្ពុជា ធនាគារ អេ អ៊ិន ហ្សិត រ៉ូយ៉ាល់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត និងអង្គការ UNDP។ លោកក៏បានចូលរួមចំណែកក្នុងវិស័យអប់រំ តាមរយៈការកាន់តួនាទីជាអ្នកដឹកនាំនៅសាលាអន្តរជាតិភ្នំពេញ (ISPP)។

លោក សារ៉េត គឺជា Fellow Chartered Management Accountant (FCMA) និង Chartered Global Management Accountant (CGMA) ដែលទទួលស្គាល់រួមគ្នាដោយវិទ្យាស្ថាន Chartered Institute of Management Accountants (CIMA) ដែលមានមូលដ្ឋាននៅចក្រភពអង់គ្លេស និង The American Institute of Certified Public Accountants (AICPA)។ លោកក៏ជា Chartered Banker ដែលផ្តល់ការទទួលស្គាល់រួមគ្នាដោយវិទ្យាស្ថាន Chartered Banker Institute (CBI) ដែលមានមូលដ្ឋាននៅចក្រភពអង់គ្លេស និងវិទ្យាស្ថាន Asian Institute of Chartered Bankers (AICB)។ លើសពីនេះ គាត់គឺជា Certified Management Accountant (CMA) ដែលទទួលស្គាល់ដោយ Institute of Certified Management Accountants ប្រទេសអូស្ត្រាលី។

លោកបានបញ្ចប់ថ្នាក់អនុបណ្ឌិតលើជំនាញគ្រប់គ្រងហិរញ្ញវត្ថុពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងថ្នាក់បរិញ្ញាបត្រជំនាញគណនេយ្យពីសាកលវិទ្យាល័យវេទមហាឫស្សី។



## លោក ម៉ៅ ប៊ូឡូ

### អគ្គនាយករង

លោក ម៉ៅ ប៊ូឡូ បានចូលបម្រើការនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ លី ហួរ ភីអ៊ិលស៊ី តួនាទីជា អគ្គនាយករង និងជានាយកប្រតិបត្តិ ហានិភ័យចាប់តាំងពីឆ្នាំ២០១២ និងបន្ទាប់មកជា អគ្គនាយករង របស់ធនាគារ អេស ប៊ី លី ហួរ ម.ក នៅពេលដែលគ្រឹះស្ថានបានកំឡាយខ្លួនទៅជាធនាគារពាណិជ្ជក្នុងឆ្នាំ២០២០។

លោកគឺជានិស្សិតអាហារូបករណ៍ដែលបានបញ្ចប់ថ្នាក់បរិញ្ញាបត្រផ្នែកគណនេយ្យ និងហិរញ្ញវត្ថុ ក្នុងឆ្នាំ១៩៩៩ ពីសាកលវិទ្យាល័យជាតិគ្រប់គ្រង។ បន្ទាប់មកនៅឆ្នាំ២០០៤ លោកបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងទូទៅពីសាកលវិទ្យាល័យប្រេសស្តុននៅសហរដ្ឋអាមេរិក (ជាមហាវិទ្យាល័យពាណិជ្ជសាស្ត្រ និងគ្រប់គ្រងរដ្ឋបាល) ដែលទទួលស្គាល់ដោយរដ្ឋ Wyoming សហរដ្ឋអាមេរិក។

លោកមានបទពិសោធន៍ជាង ២៥ឆ្នាំ ក្នុងការគ្រប់គ្រងរដ្ឋបាល ការគ្រប់គ្រងធនធានមនុស្ស ប្រព័ន្ធព័ត៌មានវិទ្យា ឌីជីថល គណនេយ្យ ហិរញ្ញវត្ថុ ការគ្រប់គ្រងផលប័ត្រឥណទាន និងការគ្រប់គ្រងអតិថិជន ទាំងនៅក្នុងអង្គការអន្តរជាតិធំៗ និង គ្រឹះស្ថានធនាគារ ដូចជាធនាគារ អេ អ៊ិន ហ្សិត រ៉ូយ៉ាល់ ជាដើម។ ក្នុងអាជីពការងារជាមួយធនាគារ អេ អ៊ិន ហ្សិត រ៉ូយ៉ាល់ លោកធ្លាប់ធ្វើជាប្រធានគ្រប់គ្រងហានិភ័យឥណទាន ដែលមានសិទ្ធិអនុម័តសំណើឥណទាន របស់អតិថិជនក្នុងមួយនាក់រហូតដល់ទៅ ទឹកប្រាក់ ២លានដុល្លារអាមេរិក មុនពេលដែលគាត់ត្រូវបានតំឡើងឋានៈជា នាយកឥណទាន បុគ្គលដែលគ្រប់គ្រងឥណទានគេហដ្ឋាន និងឥណទានអាជីវកម្មខ្នាតតូច-មធ្យមរបស់ធនាគារទាំងមូលក្នុងប្រទេសកម្ពុជា។



## លោក កែណែម វីដាណូ

### នាយកប្រតិបត្តិ

លោក កែណែម វីដាណូ គឺជាអ្នកជំនាញដែលមានបទពិសោធន៍ខ្ពស់ក្នុងវិស័យហិរញ្ញវត្ថុ និងការគ្រប់គ្រង។ លោកមានចំណេះដឹង និងបទពិសោធន៍ការងារជាច្រើនក្នុងរយៈពេលជាង ២០ឆ្នាំលើវិស័យការងារក្នុងមុខតំណែងជានាយកប្រតិបត្តិ ដែលមានដូចជានាយកប្រតិបត្តិផ្នែកគ្រប់គ្រងទំនាក់ទំនងនៃក្រុមប្រឹក្សាភិបាល នាយកប្រតិបត្តិហិរញ្ញវត្ថុ នាយកប្រតិបត្តិរដ្ឋបាល នាយកប្រតិបត្តិ និងនាយកប្រតិបត្តិផ្នែកព័ត៌មានវិទ្យា។

លោកបានចូលបម្រើការនៅធនាគារ អេស ប៊ី អាយ លី ហួរ ម.ក នៅខែកុម្ភៈ ឆ្នាំ២០២៣ ក្នុងនាមជានាយកប្រតិបត្តិ។ គួរបញ្ជាក់ផងដែរថា លោកជាសមាជិកឯករាជ្យនៃក្រុមប្រឹក្សាភិបាល និងជាប្រធានគណៈកម្មាធិការសវនកម្មចាប់ពីខែកក្កដា ឆ្នាំ២០២០។

លោកទទួលបានសញ្ញាបត្រអនុបណ្ឌិតផ្នែកយុទ្ធសាស្ត្រ និងការគ្រប់គ្រងប្រតិបត្តិការ ពីសាលាធុរកិច្ច ESCP នៅទីក្រុងប៉ារីស សញ្ញាបត្រក្រោយឧត្តមសិក្សាផ្នែកសេដ្ឋកិច្ចអន្តរជាតិ និងការអភិវឌ្ឍ ពីសាកលវិទ្យាល័យប៉ារីស ១ ប៉ង់តេអុង-សូប៊ូន និងបរិញ្ញាបត្រផ្នែកវិទ្យាសាស្ត្រនយោបាយជំនាញសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពី IEP Grenoble។

ជាមួយបទពិសោធន៍ និងសមត្ថភាពដឹកនាំដ៏រឹងមាំ លោកប្តេជ្ញាចិត្តចូលរួមចំណែកក្នុងការសម្រេចបាននូវចក្ខុវិស័យ និងបេសកកម្មរបស់ធនាគារ។



## លោក ហ៊ឹម សីលា
### នាយកប្រតិបត្តិសេវាហិរញ្ញវត្ថុខ្នាតតូច

លោក ហ៊ឹម សីលា គឺជានាយកប្រតិបត្តិក្នុងវិស័យធនាគារដែលមានបទពិសោធន៍ជាងពីរទសវត្សរ៍ដែលបានជំរុញការផ្លាស់ប្តូរអាជីវកម្ម កំណើននៃការលក់ និងនវានុវត្តន៍ឌីជីថលនៅក្នុងវិស័យហិរញ្ញវត្ថុរបស់កម្ពុជា។

ការឡើងតួនាទីពីមន្ត្រីឥណទានទៅកាន់តួនាទីជាអ្នកដឹកនាំជាន់ខ្ពស់នេះ លោកបានដើរតួយ៉ាងសំខាន់ក្នុងការបង្កើតយុទ្ធសាស្ត្រសម្រាប់សេវាហិរញ្ញវត្ថុខ្នាតតូចនៅស្ថាប័នឈានមុខគេជាច្រើន រួមមានធនាគារ ស៊ីអាយអិមប៊ី ធនាគារ ហ្វីលីព និងធនាគារ អេ អ៊ិន ហ្សិត រ៉ូយ៉ាល់។

ក្នុងនាមជានាយកប្រតិបត្តិសេវាហិរញ្ញវត្ថុខ្នាតតូចនៅធនាគារ អេស ប៊ី អាយ លី ហ្វូ ម.ក លោក សីលា បានបង្កើតឱ្យមានសេវាហិរញ្ញវត្ថុផ្សេងៗ ដើម្បីក្លាយទៅជាធនាគារពាណិជ្ជពេញលេញ។

លោកមានជំនាញខ្ពស់ក្នុងការផ្តល់ឥណទានដល់អតិថិជន ការបង្កើត និងច្នៃផលិតផល និងការបែងចែកការលក់ដើម្បីជំរុញឱ្យមានការពង្រីកទីផ្សារ និង ការបង្កើនកំណើនអតិថិជនជាបន្តបន្ទាប់។

លោក សីលា បានផ្តល់នូវមតិដ៏ល្អសម្រាប់ការផ្លាស់ប្តូរផ្នែកបរិវត្តកម្មឌីជីថល និងបានដឹកនាំការដាក់ឱ្យប្រើប្រាស់ម៉ាស៊ីនដាក់ប្រាក់ដំបូងគេរបស់កម្ពុជានៅធនាគារ ស៊ីអាយអិមប៊ី ដែលបានជួយលើកកម្ពស់នូវភាពងាយស្រួល និងប្រសិទ្ធភាពនៃប្រតិបត្តិការរបស់អតិថិជន។

លោកបានបញ្ចប់ថ្នាក់អនុបណ្ឌិតផ្នែកគ្រប់គ្រងពីវិទ្យាស្ថានជាតិពាណិជ្ជសាស្ត្រ បរិញ្ញាបត្រផ្នែកទីផ្សារ និងវិទ្យាសាស្ត្រកុំព្យូទ័រ ហើយបានបញ្ចប់កម្មវិធីសិក្សាធនាគារប្រតិបត្តិនៅសាកលវិទ្យាល័យ Nanyang Technological និង CIMB Academy ។



## លោក នី បូរ៉ាត
### នាយកប្រតិបត្តិហិរញ្ញវត្ថុ

លោក នី បូរ៉ាត ធ្លាប់ជាសវនករនៅក្នុងក្រុមហ៊ុន KPMG ក្នុងប្រទេសកម្ពុជា និងមានបទពិសោធន៍សវនកម្មក្នុងវិស័យធនាគារ គ្រឹះស្ថានហិរញ្ញវត្ថុ និងវិស័យផ្សេងៗទៀតអស់រយៈពេល១៣ឆ្នាំ ដែលក្នុងនោះលោកធ្លាប់បានបម្រើការងារជាសនវករនៅក្រុមហ៊ុន KPMG ដែលមានការិយាល័យនាទីក្រុង Los Angeles សហរដ្ឋអាមេរិករយៈពេល ១ឆ្នាំ និង៥ខែ ផងដែរ ។ ក្នុងកំឡុងពេលបម្រើការងារជាសវនករនៅក្រុមហ៊ុន លោកក៏មានតួនាទីជាអ្នកប្រឹក្សាយោបល់សម្រាប់គម្រោង IFRS វាយតម្លៃការគ្រប់គ្រងផ្ទៃក្នុង កំណត់ម៉ូឌែលហានិភ័យឥណទាន វិភាគស្ថានការណ៍ហិរញ្ញវត្ថុសម្រាប់ការរួមបញ្ចូលក្រុមហ៊ុន និងសម្រាប់ក្រុមហ៊ុនដែរចង់បោះផ្សាយមូលបត្រ។

លោកក៏បានបម្រើការក្នុងតួនាទីជាថ្នាក់ដឹកនាំជាន់ខ្ពស់ ដោយទទួលខុសត្រូវយ៉ាងចម្បងក្នុងទំនាក់ទំនងអតិថិជន រៀបចំយុទ្ធសាស្ត្រអាជីវកម្ម គ្រប់គ្រងផែនការថវិកា និងវិភាគលើរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ថ្នាក់ដឹកនាំជាន់ខ្ពស់ និងក្រុមប្រឹក្សាភិបាល ។

បើក្រឡេកទៅមើលកម្រិតវប្បធម៌លោកផ្ទាល់ លោកបានបញ្ចប់បរិញ្ញាប័ត្រជំនាញ គ្រប់គ្រងអាជីវកម្ម នៅសកលវិទ្យាល័យបៀលប្រាយ។ លោកក៏ទទួលបានសញ្ញាប័ត្រជំនាញ Investment Foundation ពីវិទ្យាស្ថាន CFA នៅក្នុងខែកញ្ញា ឆ្នាំ២០២១។ បន្ថែមទៀតនោះ លោកក៏ជាសមាជិកនៃ Fellow Member of the Association of Chartered Certified Accountants (FCCA), UK។

បច្ចុប្បន្នលោកកំពុងបន្តការសិក្សាជំនាញ Chartered Banker ក្នុងកម្រិតបញ្ចប់ទី៣ នៅវិទ្យាស្ថាន Chartered Banker (ហៅកាត់ថា"CB") និង វិទ្យាស្ថាន Asian Institute of Chartered Banker (ហៅកាត់ថា "AICB")។



## លោក ផាត់ រតនា
### នាយកប្រតិបត្តិសវនកម្មផ្ទៃក្នុង

លោក ផាត់ រតនា មានបទពិសោធន៍ការងារជាង២៥ឆ្នាំក្នុងវិស័យធនាគារ និងសេវាហិរញ្ញវត្ថុ។ លោកបានចូលបម្រើការងារនៅធនាគារ អេស ប៊ី អាយ លី ហ្វូ ម.ក មុខតំណែងជានាយកប្រតិបត្តិសវនកម្មផ្ទៃក្នុង តាំងពី ខែមិថុនា ឆ្នាំ២០១៨។

កន្លងមកលោកមានបទពិសោធន៍ ជាមួយស្ថាប័នហិរញ្ញវត្ថុក្នុងតួនាទីជាគណៈគ្រប់គ្រងជាន់ខ្ពស់ផ្នែក សវនករផ្ទៃក្នុង ប្រតិបត្តិការ និងការគ្រប់គ្រងហានិភ័យនិងប្រតិបត្តិតាម។ អំឡុងពេលនោះ លោកបានសម្រេចនូវសមិទ្ធផលដ៏ល្អជាច្រើន ដូចជា ការបង្កើតឱ្យមានជាតួនាទី និងដំណើរការប្រតិបត្តិសវនកម្មផ្ទៃក្នុង និងគ្រប់គ្រងហានិភ័យនិងប្រតិបត្តិតាម នៅក្នុងស្ថាប័ន។

លោកបានទទួលបរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងពាណិជ្ជកម្ម ជំនាញហិរញ្ញវត្ថុ នៅសាកលវិទ្យាល័យ Charles Stuart នៃប្រទេសអូស្ត្រាលី និងបានបញ្ចប់ថ្នាក់បរិញ្ញាបត្រគ្រប់គ្រងពាណិជ្ជកម្ម ជំនាញគណនេយ្យ នៃសាកលវិទ្យាល័យជាតិគ្រប់គ្រង និងវគ្គជំនាញបន្ថែមជាច្រើនទៀតទាំងក្នុង និងក្រៅទេស។



## លោក ទាង ស្រេង
### នាយកប្រតិបត្តិធនធានមនុស្ស

លោក ទាង ស្រេង ជានាយកប្រតិបត្តធនធានមនុស្សនៃធនាគារ អេស ប៊ី អាយ លី ហ្វូ។ លោកមានបទពិសោធន៍ជាង២៣ឆ្នាំក្នុងវិស័យផ្សេងគ្នាៗ ជាពិសេសនៅក្នុងស្ថាប័នធនាគារ និងហិរញ្ញវត្ថុ។ លោកធ្វើការជាដៃគូយុទ្ធសាស្ត្រ និងធុរកិច្ចផ្នែកធនធានមនុស្ស ព្រមទាំងមានតួនាទីនៅក្នុងសមាជិកគណៈកម្មាធិការប្រតិបត្តិជាង១៥ឆ្នាំរួមមាននៅអម្រឹត និង ធនាគារព្រីនស៍ ។

លោកមានជំនាញក្នុងការបណ្តុះបណ្តាល និងអភិវឌ្ឍន៍ យុទ្ធសាស្ត្រធនធានមនុស្ស ប្រព័ន្ធគ្រប់គ្រងធនធានមនុស្ស និងប្រព័ន្ធគ្រប់គ្រងការសិក្សា។ លោក ទាង ស្រេង បានបញ្ចប់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងពាណិជ្ជកម្មក្នុងជំនាញគ្រប់គ្រងទូទៅពីសាកលវិទ្យាល័យបៀលប្រាយ បរិញ្ញាបត្រគ្រប់គ្រងពាណិជ្ជកម្មក្នុងជំនាញទីផ្សារពីសកលវិទ្យាល័យជាតិគ្រប់គ្រង និងបរិញ្ញាបត្រផ្នែកអប់រំក្នុងជំនាញបង្រៀន និងបណ្តុះបណ្តាលពីវិទ្យាស្ថានភាសាបរទេសផ្នែកភាសាអង់គ្លេស ។

លោកក៏បានចូលរួមវគ្គបណ្តុះបណ្តាលធនធានមនុស្ស និង ការអនុវត្តយុទ្ធសាស្ត្រ ពីសាលា Harvard Business School ការគ្រប់គ្រងមីក្រូហិរញ្ញវត្ថុពី Boulder និងវគ្គបណ្តុះបណ្តាលជំនាញខ្លីៗ និងឯកទេសផ្សេងៗ ទាំងសាលាបណ្តុះបណ្តាលវិជ្ជាជីវៈក្នុងស្រុក និងអន្តរជាតិ។



លោក វ៉ា លួងសុរិន បានចូលបម្រើការក្នុងធនាគារ អេស ប៊ី អាយ លី ហួរ ម.ក ជានាយកប្រតិបត្តិព័ត៌មានវិទ្យា ជាមួយបទពិសោធន៍ក្នុងការដឹកនាំជាច្រើនដូចជា ផ្នែកព័ត៌មានវិទ្យា ផ្នែកបរិវត្តកម្មឌីជីថល និងផ្នែកបច្ចេកវិទ្យាធនាគារ។ មុនពេលចូលបម្រើការងារជាមួយធនាគារ អេស ប៊ី អាយ លី ហួរ ម.ក លោកជានាយកប្រតិបត្តិព័ត៌មានវិទ្យា និងជានាយកប្រតិបត្តិផ្នែកសន្តិសុខព័ត៌មាន នៅធនាគារពាណិជ្ជដ៏ធំបំផុតមួយក្នុងប្រទេសកម្ពុជា ដែលលោកជាអ្នកដឹកនាំ និងជាប្រធានប្រឹក្សាភិបាលផ្នែកយុទ្ធសាស្ត្រព័ត៌មានវិទ្យា ផ្នែកគណៈកម្មាធិការព័ត៌មានវិទ្យា ផ្នែកឌីជីថល និងជាសមាជិកគណៈកម្មាធិការប្រតិបត្តិ និងគណៈកម្មាធិការគ្រប់គ្រងហានិភ័យអស់រយៈពេលជាងមួយទសវត្សរ៍។

លោក សុរិន ទទួលបានបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកវិទ្យាសាស្ត្រព័ត៌មានវិទ្យា និងបានចូលរួមក្នុងកម្មវិធីបណ្តុះបណ្តាលផ្សេងៗទាំងក្នុងប្រទេស និងក្រៅប្រទេស ដែលជួយបង្កើនជំនាញរបស់លោកបន្ថែមទៀតក្នុងការគ្រប់គ្រងព័ត៌មានវិទ្យា ការគ្រប់គ្រងគម្រោងព័ត៌មានវិទ្យា សន្តិសុខតាមអ៊ីនធឺណិត ផែនការបន្តអាជីវកម្ម ការរួមបញ្ចូលបច្ចេកវិទ្យាហិរញ្ញវត្ថុ និងដំណោះស្រាយធនាគារឌីជីថល។

## លោក វ៉ា លួងសុរិន
### នាយកប្រតិបត្តិព័ត៌មានវិទ្យា

លោក ទ្រី វិសាល មានបទពិសោធន៍ការងារជាង ១៣ឆ្នាំ ក្នុងវិស័យធនាគារពាណិជ្ជ រួមមាន សវនកម្មផ្ទៃក្នុង ប្រតិបត្តិតាម និងការគ្រប់គ្រងហានិភ័យ។

លោកបានបញ្ចប់ថ្នាក់ បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគណនេយ្យ និងហិរញ្ញវត្ថុ ពីសាកលវិទ្យាល័យ La Trobe ប្រទេសអូស្ត្រាលីបរិញ្ញាបត្រផ្នែកហិរញ្ញវត្ថុ និងធនាគារ ពីសាកលវិទ្យាល័យជាតិគ្រប់គ្រង និងបរិញ្ញាបត្រវិទ្យាសាស្ត្រកំព្យូទ័រ ពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

លោកក៏ទទួលបាន នូវសញ្ញាបត្រជំនាញសំខាន់ៗ រួមមាន ផ្នែកគ្រប់គ្រងហានិភ័យ (Certified Expert in Risk Management) ពីសាលា Frankfurt School of Finance and Management ប្រទេសអាល្លឺម៉ង់ ផ្នែកប្រឆាំងការសម្អាតប្រាក់ (Advanced Certification in AML) ពី International Compliance Association (ICA) ចក្រភពអង់គ្លេស និង ផ្នែកប្រតិបត្តិតាមពីវិទ្យាស្ថាន ធនាគារ និងហិរញ្ញវត្ថុ (IBF) នៅកម្ពុជា។



## លោក ទ្រី វិសាល
### នាយកប្រតិបត្តិហានិភ័យ







# ៧. អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង


| | | |
|---|---|---|
| ៧.១ | សេចក្តីផ្តើម | ៣៣ |
| ៧.២ | ទស្សនវិស័យ | ៣៣ |
| ៧.៣ | បេសកកម្ម | ៣៣ |
| ៧.៤ | គោលបំណង | ៣៤ |
| ៧.៥ | វិសាលភាព | ៣៤ |
| ៧.៦ | លទ្ធផលការងារ | ៣៤ |
| ៧.៧ | ការរាយការណ៍ | ៣៤ |

## ៧.១ សេចក្តីផ្តើម

អង្គភាពសវនកម្មផ្ទៃក្នុង ដើរតួនាទីយ៉ាងសំខាន់ក្នុងការគ្រប់គ្រងហានិភ័យ តាមរយៈការផ្តួចផ្តើមសកម្មភាពកែលម្អគុណភាព ការអនុវត្តធ្វើតេស្តលទ្ធផលការងារ និងការកំណត់ពីលទ្ធភាពធ្វើឱ្យប្រសើរឡើងនៃប្រតិបត្តិការ។ បន្ថែមពីនេះទៀត គ្រឹះស្ថានហិរញ្ញវត្ថុ គឺត្រូវបានតម្រូវដោយធនាគាជាតិនៃកម្ពុជា ដើម្បីបង្កើតប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរឹងមាំ និងសុវត្ថិភាព តាមរយៈប្រកាស ប៧-០១០-១៧២ប្រក ចុះថ្ងៃទី ២៨ ខែកញ្ញា ឆ្នាំ២០១០ ហើយមុខងារសវនកម្មផ្ទៃក្នុង គឺជាផ្នែកមួយដែលតម្រូវឱ្យមានជាចាំបាច់។ វាគឺជាផ្នែកដ៏សំខាន់មួយនៃអភិបាលកិច្ច និងជាមធ្យោបាយដ៏ល្អ ដើម្បីភាពរីកចម្រើនអាជីវកម្មរបស់ធនាគារ។

- **ទី១៖** អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុងដ៏មានប្រសិទ្ធភាព អាចជួយឱ្យសម្រេចគោលដៅធនាគារ តាមរយៈការជួយគណៈគ្រប់គ្រងកែលម្អការគ្រប់គ្រង ដំណើរការអាជីវកម្ម និងការគ្រប់គ្រងហានិភ័យអាជីវកម្ម។
- **ទី២៖** សវនករផ្ទៃក្នុងដើរតួនាទីសំខាន់ ដែលជាផ្នែកមួយនៅក្នុងរចនាសម្ព័ន្ធអភិបាលកិច្ច ក្នុងការធានាថាធនាគារសម្រេចនូវគោលបំណងរបស់ខ្លួនប្រកបដោយក្រមសីលធម៌ ស្របតាមច្បាប់ និងបានគ្រប់គ្រងយ៉ាងល្អ។
- **ទី៣៖** អ្វីដែលសំខាន់ជាងនេះ សវនករផ្ទៃក្នុង ជួយទប់ស្កាត់ការគៃបន្លំ។ សវនករផ្ទៃក្នុង ត្រូវបានចាត់ទុកជាអ្នកតំណាងឱ្យក្រុមប្រឹក្សាភិបាល និងម្ចាស់ភាគហ៊ុន។

## ៧.២ ទសនវិស័យ

សម្រេចឱ្យបាននូវគុណភាពមុខងារសវនកម្មផ្ទៃក្នុង ជាមួយនឹងបទដ្ឋានខ្ពស់បំផុតនៃអភិបាលកិច្ច និងប្រកបទៅដោយវិជ្ជាជីវៈ។

## ៧.៣ បេសកកម្ម

ដើម្បីបង្កើន និងការពារទ្រព្យរបស់ធនាគារ តាមរយៈផ្តល់នូវការធានា ផ្តល់ការប្រឹក្សា និងការយល់ដឹងស៊ីជម្រៅដោយផ្អែកលើហានិភ័យ និងមិនលម្អៀង។

## ៧.៤ គោលបំណង

គោលបំណងនៃសវនកម្មផ្ទៃក្នុង គឺជួយក្រុមប្រឹក្សាភិបាល គណៈកម្មការសវនកម្ម និងគណៈគ្រប់គ្រងជាន់ខ្ពស់ក្នុងការសម្រេចគោលដៅរបស់ពួកគេ ដោយនាំមកនូវវិធីសាស្ត្រជាលក្ខណៈប្រព័ន្ធ និងប្រកបដោយវិន័យ ដើម្បីធ្វើការវាយតម្លៃ និងធ្វើឱ្យប្រសើរឡើងនូវអភិបាលកិច្ច ការគ្រប់គ្រងហានិភ័យ និងការគ្រប់គ្រងដំណើរការរបស់ធនាគារ។ សវនកម្មផ្ទៃក្នុង អាចដើរតួក្នុងការប្រឹក្សាយោបល់ នៅពេលមានតម្រូវការ ដោយមិនមានការប៉ះពាល់ដល់ឯករាជ្យភាពរបស់ខ្លួន។

## ៧.៥ វិសាលភាព

សវនកម្មផ្ទៃក្នុងមានវិសាលភាពលើគ្រប់ទិដ្ឋភាពនៃប្រតិបត្តិការរបស់ធនាគារ ស្របជាមួយវិសាលភាពដែលបានកំណត់នៅក្នុងធម្មនុញ្ញរបស់សវនកម្មផ្ទៃក្នុង។ គំលាតនៃការប្រតិបត្តិសវនកម្មផ្ទៃក្នុងគឺផ្អែកលើស្ថានភាពជាក់ស្តែង ដូចជាលទ្ធផលនៃសវនកម្មកន្លងមក ហានិភ័យដែលជាប់ពាក់ព័ន្ធជាមួយនាយកដ្ឋាន/សាខា កំហុសជាសារវន្ត ភាពគ្រប់គ្រាន់នៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងធនធាននានាលើមុខងារសវនកម្មផ្ទៃក្នុង។

## ៧.៦ លទ្ធផលការងារ

ផែនការសវនកម្មប្រចាំឆ្នាំ សម្រាប់ឆ្នាំ២០២៤ ត្រូវបានបង្កើតឡើងដោយផ្អែកលើវិធីសាស្ត្រវាយតម្លៃហានិភ័យយ៉ាងជាក់លាក់ ដើម្បីឆ្លើយតបតាមយុទ្ធសាស្ត្ររបស់ធនាគារ ក្នុងការកំណត់គោលដៅ និងវិសាលភាពនៃសវនកម្មនីមួយៗ។ គណៈកម្មការសវនកម្ម បានអនុម័តផែនការសវនកម្មផ្ទៃក្នុងប្រចាំឆ្នាំ រួមបញ្ចូលទាំងថវិកាដើម្បីគាំទ្រសកម្មភាពសវនកម្មផ្ទៃក្នុង ធនធានមនុស្ស និងការអភិវឌ្ឍចំណេះដឹង ជំនាញវិជ្ជាជីវៈ។ នៅក្នុងឆ្នាំ២០២៤ អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង បានប្រតិបត្តិការងារសវនកម្មយ៉ាងជោគជ័យ ទៅលើសាខា និងនាយកដ្ឋាន/ការិយាល័យ ទាំងអស់ស្របទៅតាមផែនការប្រចាំឆ្នាំ។

សម្រាប់បញ្ហាជាសារវន្ត ដែលត្រូវបានរកឃើញតាមរយៈការធ្វើសវនកម្ម អនុសាសន៍សវនកម្ម គឺត្រូវបានបង្ហាញជូនគណៈគ្រប់គ្រង និងសវនកម្មផ្ទៃក្នុងធានាថា គណៈគ្រប់គ្រងរៀបចំសកម្មភាពកែតម្រូវយ៉ាងសមស្រប ជាមួយនឹងពេលវេលាជាក់លាក់ ដើម្បីធ្វើការកែលម្អ ដូចជា ការធ្វើបច្ចុប្បន្នភាព/ការអភិវឌ្ឍ គោលនយោបាយ គោលការណ៍ប្រតិបត្តិ/នីតិវិធី ការពង្រឹងសមត្ថភាពបុគ្គលិក និងការគ្រប់គ្រងការបណ្តុះបណ្តាល។

## ៧.៧ ការរាយការណ៍

របាយការណ៍សវនកម្មផ្ទៃក្នុង ប្រចាំត្រីមាសត្រូវបានរាយការណ៍ជូនគណៈកម្មការសវនកម្ម និងចម្លងជូនគណៈគ្រប់គ្រងជាន់ខ្ពស់។ មាតិកានៃរបាយការណ៍ រួមបញ្ចូលសកម្មភាពកែតម្រូវរបស់គណៈគ្រប់គ្រង ដើម្បីមានចំណាត់ការ ក៏ជាចំណុចដែលត្រូវតាមដានដោយសវនកម្មផ្ទៃក្នុង ដើម្បីពិនិត្យមើលលើការកែតម្រូវចំណុចខ្វះខាតដែលរកឃើញដោយសវនករ។

# ៨. ការគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាម


| | | |
|---|---|---|
| ៨.១ | ការគ្រប់គ្រងហានិភ័យ | ៣៧ |
| ៨.២ | ដំណើរការនៃការគ្រប់គ្រងហានិភ័យ | ៣៧ |
| ៨.៣ | ចំណាត់ថ្នាក់ហានិភ័យ និងការគ្រប់គ្រង | ៣៨ |
| ៨.៤ | នាយកដ្ឋានប្រតិបត្តិតាម | ៤០ |






## ៨.១ ការគ្រប់គ្រងហានិភ័យ

ការគ្រប់គ្រងហានិភ័យដើរតួយ៉ាងសំខាន់នៅក្នុងធនាគារ អេស ប៊ី អាយ លី ហួរ ម.ក ដែលអ្នកគ្រប់គ្រងកំពុងផ្តោត និងផ្តល់អាទិភាពព្រោះវាជាកាតាលីករដែលជួយនាំស្ថាប័នទាំងមូលឆ្ពោះទៅរកភាពជោគជ័យ ក៏ដូចជារក្សាបាននូវនិរន្តរភាពយូរអង្វែងរបស់ខ្លួន។

ដូច្នេះ ដើម្បីធានាថាមានការគ្រប់គ្រងហានិភ័យប្រកបដោយប្រសិទ្ធភាព និប្រសិទ្ធផល ធនាគារ ប្រើគោលការណ៍សំខាន់មួយ ដើម្បីទប់ស្កាត់ហានិភ័យដែលមិននឹកស្មានដល់ណាមួយកើតឡើង។

តាមបច្ចេកទេស ដើម្បីធានាបាននូវការអនុវត្តល្អបំផុតនៃក្របខ័ណ្ឌគ្រប់គ្រងហានិភ័យ ធនាគារ អេស ប៊ី អាយ លី ហួរ ម.ក បានកំណត់វិសាលភាពច្បាស់លាស់នៃការងារ និងទំនួលខុសត្រូវ ហើយត្រូវបានបែងចែកជា ៣ ខ្សែមុខងារស្នូល (ខ្សែការពារទាំងបី)។




## ៨.២ ដំណើរការនៃការគ្រប់គ្រងហានិភ័យ

អគ្គនាយកដ្ឋានគ្រប់គ្រងហានិភ័យដើរតួនាទីយ៉ាងសកម្មក្នុងការជួយគាំទ្រធនាគារក្នុងការកំណត់អត្តសញ្ញាណហានិភ័យ ដែលពាក់ព័ន្ធនឹងការអនុវត្តការងារ របស់បុគ្គលិក ក៏ដូចជាដំណើរការ និងនីតិវិធី នៃនាយកដ្ឋានពាក់ព័ន្ធផ្សេងៗទៀត។ បន្ទាប់ពីហានិភ័យត្រូវបានកំណត់ នោះការវាយតម្លៃក៏នឹងត្រូវបានធ្វើឡើងដើម្បីស្វែងយល់ពីលទ្ធភាពនៃការកើតឡើង និងផលប៉ះពាល់ដែលអាចនឹងទទួលរង។

ជំហាននេះ អគ្គនាយកដ្ឋានគ្រប់គ្រងហានិភ័យ នឹងជួយធានាឱ្យមានភាពស៊ីសង្វាក់គ្នា នៃការកំណត់អត្តសញ្ញាណហានិភ័យ និងដើម្បីធានាឱ្យមានការត្រួតពិនិត្យ និងរាយការណ៍ឱ្យបានត្រឹមត្រូវ និងទាន់ពេលវេលាលើហានិភ័យដែលបានកំណត់នៅក្នុងធនាគារ។

លើសពីនេះ ដើម្បីឆ្លើយតបទៅនឹងហានិភ័យដែលខ្លួនបានកំណត់ ធនាគារបានបង្កើត និងអនុវត្តយន្តការក្នុងការឆ្លើយតបទៅនឹងហានិភ័យ ដើម្បីដោះស្រាយ និង/ឬ កាត់បន្ថយកម្រិតនៃហានិភ័យ ឱ្យមកនៅត្រឹមកម្រិតដែលអាចទទួលយកបាន ដែលយន្តការទាំងនោះមានដូចជា ការកាត់បន្ថយហានិភ័យ ការជៀសវាងហានិភ័យ ការផ្ទេរហានិភ័យ និងការទទួលយកហានិភ័យ។






## ៨.៣ ចំណាត់ថ្នាក់ហានិភ័យ និងការគ្រប់គ្រង

### ហានិភ័យឥណទាន

ក្រោមសម្ពាធនៃភាពមិនច្បាស់លាស់នៃសេដ្ឋកិច្ចក្នុងស្រុក និងសេដ្ឋកិច្ចសកល ដែលបណ្តាលមកពីការអូសបន្លាយនៃសង្គ្រាមរវាងអ៊ុយក្រែន-រុស្ស៊ី ការបញ្ឆេះសង្គ្រាមនៅអ៊ីស្រាអែល ការកើនឡើងនៃអត្រាការប្រាក់ និងការថមថយនូវតម្រូវការក្នុងសេដ្ឋកិច្ច ធនាគារអាចគ្រប់គ្រងផលបត្រហានិភ័យ (PAR៣0+) បាន ៣.៦៣% ក្នុងឆ្នាំ ២០២៤ បើធៀបទៅនឹងវិស័យធនាគារបច្ចុប្បន្នដែលមាន PAR៣0+ ជារួមលើសពី ៧.៥៤%។

នៅឆ្នាំ ២០២៥ ធនាគារបន្តពង្រឹងគុណភាពឥណទាន និងការធ្វើពិពិធកម្មផលបត្រតាមរយៈការគ្រប់គ្រង និងធ្វើឱ្យមានតុល្យភាពជាមួយវិសអាប់កែថាយ និងវិសថលើវែន។ លើសពីនេះ ធនាគារនឹងធ្វើឱ្យប្រសើរឡើងនូវការអនុវត្តគំរូវិភាគឥណទាន ការធ្វើស្រ្តេសតេស្តឥណទានជាប្រចាំ និងការជំរុញឧបករណ៍ត្រួតពិនិត្យ និងរាយការណ៍។ ធនាគារ នឹងពង្រឹងការអនុវត្ត សង្គម បរិស្ថាន និងអភិបាលកិច្ច (ESG) តាមរយៈគោលនយោបាយ នីតិវិធី និងឧបករណ៍ដែលផ្អែកលើគោលការណ៍ហិរញ្ញវត្ថុប្រកបដោយនិរន្តរភាពរបស់កម្ពុជា។

### ហានិភ័យប្រតិបត្តិការ

ហានិភ័យនៃការបាត់បង់កើតឡើងពីដំណើរការខាងក្នុងមិនគ្រប់គ្រាន់ ឬបរាជ័យ មនុស្ស ប្រព័ន្ធ ឬព្រឹត្តិការណ៍ខាងក្រៅ។ ការគ្រប់គ្រងហានិភ័យប្រតិបត្តិការ រួមមានការបង្កើតក្របខណ្ឌគ្រប់គ្រងហានិភ័យប្រតិបត្តិការច្បាស់លាស់ ការកំណត់តួនាទី និងការទទួលខុសត្រូវសម្រាប់ខ្សែការពារទាំងបី ការបង្កើតបន្ទាត់រាយការណ៍ និងការអនុវត្តយន្តការកែលម្អទៅលើដំណើរការ។ គោលនយោបាយ ការត្រួតពិនិត្យផ្ទៃក្នុង នីតិវិធី និងឧបករណ៍ដទៃទៀត រួមទាំងការគ្រប់គ្រងការបាត់បង់ ការគ្រប់គ្រងហានិភ័យ ការវាយសិក្សាវាយតម្លៃ ហានិភ័យ និងប្រព័ន្ធត្រួតពិនិត្យដោយខ្លួនឯង (RCSA) ការវាយតម្លៃហានិភ័យនៃផលិតផល/បទប្បញ្ញត្តិ ការគ្រប់គ្រងហានិភ័យនៃការកេងបន្លំ និងការគ្រប់គ្រងនិរន្តភាពអាជីវកម្ម ត្រូវបានអនុវត្ត និងត្រូវបានត្រួតពិនិត្យជាបន្តបន្ទាប់ ដើម្បីដោះស្រាយហានិភ័យប្រតិបត្តិការដែលអាចកើតមានឡើងទៅលើ សកម្មភាពអាជីវកម្មរបស់ធនាគារ និងធានានូវប្រសិទ្ធភាពនៃក្របខ័ណ្ឌ និងការអនុវត្តទៅលើហានិភ័យនេះ។

នៅឆ្នាំ ២០២៥ ធនាគារបន្តពង្រឹងការអនុវត្តការត្រួតពិនិត្យផ្ទៃក្នុង និងអភិបាលកិច្ច ជាមួយនឹងឧបករណ៍គ្រប់គ្រងហានិភ័យប្រតិបត្តិការ និងរបាយការណ៍ឱ្យប្រសើរឡើងជាលំដាប់។

### ហានិភ័យសន្ទនីយភាព និងដើមទុន

ធនាគារយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការគ្រប់គ្រងសន្ទនីយភាព និងដើមទុនរបស់ខ្លួន ដោយបានកំណត់ទ្រនាប់ផ្ទៃក្នុងលើសពីតម្រូវការនៃបទប្បញ្ញត្តិ ដើម្បីធានាបាននូវអនុលោមភាពពេញលេញ និងស្ថានភាពសន្ទនីយភាពដ៏រឹងមាំ។ ធនាគារបានរក្សានូវអនុបាតគ្របខណ្ឌសន្ទនីយភាព (LCR) ក្នុងកម្រិត ១៩៧.៧៧% និងអនុបាតសោធនភាព (CAR) ក្នុងកម្រិត ១៧.០៣% ក្នុងឆ្នាំ ២០២៤ ដែលអនុលោមតាមដែនកំណត់ទាំងផ្ទៃក្នុង និងបទប្បញ្ញត្តិ។ អនុបាតសន្ទនីយភាពផ្សេងៗទៀតត្រូវបានកំណត់ និងត្រួតពិនិត្យតាមរយៈសូចនាករហានិភ័យគន្លឹះ រួមមានប្រាក់បញ្ញើប្រមូលផ្តុំ តម្រូវការទុនបម្រុង ស្ថានភាពសាច់ប្រាក់ ទ្រព្យសកម្មងាយស្រួល និងអនុបាតប្រាក់កម្ចីធៀបនឹងប្រាក់បញ្ញើ។ ហានិភ័យសន្ទនីយភាព និងសោធនភាព ត្រូវបានតាមដាន និងត្រួតពិនិត្យជាប្រចាំយ៉ាងតឹងរ៉ឹងដោយគណៈកម្មាការគ្រប់គ្រងទ្រព្យសកម្មនិងទ្រព្យអកម្ម (ALCO) និងគណៈកម្មការត្រួតពិនិត្យហានិភ័យ (ROC) ដែលការវិភាគ ការត្រួតពិនិត្យ និងការតាមដានជាប្រចាំ ត្រូវបានអនុវត្តដោយនាយកដ្ឋានទទួលបន្ទុក។

### ហានិភ័យអត្រាការប្រាក់

ហានិភ័យអត្រាការប្រាក់សំដៅលើភាពប្រែប្រួលនៃចំណូលការប្រាក់សុទ្ធ ដែលបណ្តាលមកពីការផ្លាស់ប្តូរកម្រិតនៃអត្រាការប្រាក់ និងការប្រែប្រួលសមាសភាពនៃទ្រព្យសកម្ម និងបំណុល។ ផលប៉ះពាល់នៃហានិភ័យអត្រាការប្រាក់ ទាក់ទងជាចម្បងទៅនឹងប្រាក់កម្ចី ប្រាក់បញ្ញើរបស់អតិថិជន និងការខ្ចីប្រាក់។ ធនាគារបានធ្វើការតាមដាន និងវិភាគ យ៉ាងជិតដល់ជាប្រចាំ នូវការប្រែប្រួលអត្រាការប្រាក់នៅក្នុងទីផ្សារ តាមរយៈព័ត៌មានគ្រប់គ្រាន់ និងអាចជឿជាក់បានអំពីទីផ្សារ វិស័យធនាគារ គោលនយោបាយរូបិយវត្ថុរបស់ធនាគារជាតិនៃកម្ពុជា គោលនយោបាយអត្រាការប្រាក់នៅបរទេសពីធនាគារកណ្តាលអាមេរិក ធនាគារកណ្តាលអឺរ៉ុប និងធនាគារកណ្តាលផ្សេងៗក្នុងតំបន់ ដើម្បីមានភាពសកម្មក្នុងការគ្រប់គ្រងហានិភ័យអត្រាការប្រាក់ ធនាគារបានអនុវត្តជាប្រចាំនូវការធ្វើស្ត្រេសតេស្តអត្រាការប្រាក់ និងរាយការណ៍ជូនគណៈកម្មការត្រួតពិនិត្យហានិភ័យ និងក្រុមប្រឹក្សាភិបាលសម្រាប់ជាព័ត៌មាន ឬការសម្រេចចិត្ត។

ធនាគារប្តេជ្ញាក្នុងការគ្រប់គ្រងហានិភ័យអត្រាការប្រាក់ប្រកបដោយប្រសិទ្ធភាព តាមរយៈការតាមដានយ៉ាងជិតស្និទ្ធនៃតម្លៃទីផ្សារ និងថ្លៃដើមនៃមូលនិធិ។ ការថយចុះសក្តានុពលនៃប្រាក់ចំណូលការប្រាក់សុទ្ធមកពីចលនាអត្រាការប្រាក់មិនអំណោយផលត្រូវបានតាមដាន និងត្រួតពិនិត្យជាប្រចាំដោយ គណៈកម្មាការគ្រប់គ្រងទ្រព្យសកម្មនិងទ្រព្យអកម្ម (ALCO) និងគណៈកម្មាធិការត្រួតពិនិត្យហានិភ័យ (ROC)។

### ហានិភ័យផ្សេងៗ

ហានិភ័យផ្សេងៗ សំដៅដល់ហានិភ័យដែលកើតឡើងពីការសម្រេចចិត្តអាជីវកម្មមិនល្អ ឬការអនុវត្តមិនត្រឹមត្រូវ និង/ឬមិនសមរម្យចំពោះការសម្រេចចិត្តទាំងនោះ ក៏ដូចជាព្រឹត្តិការណ៍អវិជ្ជមានចំពោះធនាគារ។ ហានិភ័យទាំងនោះរួមមាន ហានិភ័យផ្នែកព័ត៌មានវិទ្យា ហានិភ័យអត្រាប្តូរប្រាក់ ហានិភ័យកេរ្តិ៍ឈ្មោះ ហានិភ័យផ្នែកច្បាប់ និងហានិភ័យប្រតិបត្តិតាម។ ធនាគារបានយកចិត្តទុកដាក់ក្នុងការត្រួតពិនិត្យ និងវាយតម្លៃហានិភ័យទាំងនេះដោយប្រុងប្រយ័ត្ន តាមរយៈសូចនាករហានិភ័យគន្លឹះដែលបានអនុម័តដោយក្រុមប្រឹក្សាភិបាល។



## ៨.៤ នាយកដ្ឋានប្រតិបត្តិតាម

នាយកដ្ឋាននេះត្រួតពិនិត្យដោយផ្ទាល់ពីគណៈកម្មការត្រួតពិនិត្យហានិភ័យ និងក្រុមប្រឹក្សាភិបាល និងមានមុខងារចម្បងចំនួនពីរគឺ៖

១. មុខងារអនុលោមតាមបទប្បញ្ញត្តិ៖ ការវាយតម្លៃហានិភ័យ វិធីសាស្ត្រផ្អែកតាមហានិភ័យសម្រាប់បទបញ្ញត្តិពាក់ព័ន្ធ នៅក្នុងកម្រិតការិយាល័យកណ្តាល និងសាខាត្រូវបានអនុវត្ត ដែលរួមបញ្ចូលនៅក្នុងវិសាលភាពស្នូលនៃបទបញ្ញត្តិប្រុងប្រយ័ត្ន វិស្សលប្ប៉ូវីង កិច្ចគាំពារអតិថិជន និងការរាយការណ៍ជាដើម។

២. មុខងារប្រឆាំងការសម្អាតប្រាក់ ហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យត្រូវបានបង្កើតឡើងដើម្បីធានាថាធនាគារអាចទប់ស្កាត់ ស្វែងរក និងរាយការណ៍ប្រតិបត្តិការសង្ស័យទាក់ទងនឹងការសម្អាតប្រាក់។

៣. ហិរញ្ញប្បទាន ភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យទៅនិយ័តករ និងអនុលោមតាបបទបញ្ញត្តិជាធរមានពាក់ព័ន្ធ។

យន្តការស្តីពីការប្រឆាំងការសម្អាតប្រាក់ ហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាល បានដាក់បញ្ចូល និងអនុវត្ត រួមមានគោលនយោបាយ នីតិវិធី និងសេចក្តីណែនាំ មានប្រព័ន្ធត្រួតពិនិត្យប្រតិបត្តិការប្រចាំថ្ងៃ និងយន្តការផ្សេងៗ ដូចជា ការទទួលស្គាល់អតិថិជន ការយកចិត្តទុកដាក់ស្គាល់អតិថិជន និងការបន្ថឹងការយកចិត្តទុកដាក់ស្គាល់អតិថិជន និងការដាក់ទណ្ឌកម្មដែលត្រូវបានអនុវត្តគ្រប់ទំនាក់ទំនងអាជីវកម្មទាំងអស់ជាមួយធនាគារក្នុងការការពារ ការស្វែងរក និងការរាយការណ៍ ក៏ដូចជាកម្មវិធីបណ្តុះបណ្តាលសម្រាប់បុគ្គលិកថ្មី និងចាស់ទាំងអស់ ការទុកដាក់ និងរក្សាព័ត៌មាន និងឯកសារជាដើម។



# ៩. អគ្គនាយកដ្ឋានធនធានមនុស្ស



អគ្គនាយកដ្ឋានធនធានមនុស្សរបស់ធនាគារ អេស ប៊ី អាយ លី ហួរ ម.ក បានប្រឹងប្រែងយ៉ាងខ្លាំងក្នុងឆ្នាំ២០២៤ លើឌីជីថលនីយកម្ម សម្រាប់គ្រប់គ្រងប្រតិបត្តិការសេវាកម្មធនធានមនុស្ស និងគ្រប់គ្រងទិន្នន័យបុគ្គលិកស្របតាមការប្តេជ្ញាចិត្តក្នុងការធ្វើឱ្យប្រសើរឡើងជាបន្តបន្ទាប់នូវគុណភាពសេវាកម្ម។

ទាំងនេះពាក់ព័ន្ធនឹងការសម្រួលដំណើរការផ្សេងៗដែលទាក់ទងនឹងវដ្តអាជីពការងាររបស់បុគ្គលិក ការបើកប្រាក់បៀវត្សរ៍ ការគ្រប់គ្រងទិន្នន័យបុគ្គលិក ការជ្រើសរើស និងការគ្រប់គ្រងលទ្ធផលការងារតាមរយៈ ប្រព័ន្ធគ្រប់គ្រងធនធានមនុស្ស (HRIS) រួមជាមួយប្រព័ន្ធគ្រប់គ្រងការសិក្សា (LMS)។ ប្រព័ន្ធឌីជីថលទាំងនេះបានបើកដំណើរការដើម្បីផ្តល់សេវាកម្មធនធានមនុស្សដែលកាន់តែងាយស្រួល និងរហ័សទាន់ចិត្តដល់បុគ្គលិកទាំងអស់។

ផ្តោតលើការវិនិយោគលើការសិក្សា និងការអភិវឌ្ឍសមត្ថភាពបស់បុគ្គលិកដោយទទួលស្គាល់ពួកគាត់ពិតជាទ្រព្យសម្បត្តិដែលមិនអាចកាត់ថ្លៃបាន និងជាកត្តាជំរុញនៃភាពជោគជ័យរបស់យើង ធនាគារបានផ្សព្វផ្សាយយ៉ាងសកម្មនូវវប្បធម៌នៃការសិក្សារៀនសូត្រជាបន្តបន្ទាប់។ វិធីសាស្ត្រនេះគាំទ្រដល់និយោជិតក្នុងការបង្កើនជំនាញថ្មីៗ និងបំពេញជំនាញខ្វះខាតឡើងវិញ ដើម្បីធានាថា ពួកគាត់អាចអនុវត្តតួនាទី និងភារៈកិច្ចបច្ចុប្បន្នរបស់ពួកគេប្រកបដោយប្រសិទ្ធភាពខ្ពស់ និងសម្របខ្លួនទៅនឹងការផ្លាស់ប្តូរបរិយាកាសការងារ និងភាពរីកចម្រើនផ្នែកបច្ចេកវិទ្យាផងដែរ។

ការបណ្តុះបណ្តាល និងការអភិវឌ្ឍគុណវុឌ្ឍិបុគ្គលិក គឺជាចំណុចស្នូលមួយរបស់ធនាគារក្នុងការលើកកម្ពស់សមត្ថភាពបុគ្គលិកទាំងជំនាញរឹង និងជំនាញទន់។ ជាអាទិ៍ យើងបានចាប់ផ្តើមពីវគ្គសិក្សាមូលដ្ឋានគ្រឹះសម្រាប់បុគ្គលិកថ្មីៗជាមួយវគ្គសិក្សានានាដែលផ្តោតលើបេសកកម្ម ចក្ខុវិស័យ គុណតម្លៃរួម និងវប្បធម៌រួមរបស់ធនាគារ ហើយក្នុងពេលជាមួយគ្នានេះផងដែរ វាក៏ត្រូវបានអនុវត្តតាមយ៉ាងតឹងរ៉ឹង និងខ្ជាប់ខ្ជួននូវវគ្គបណ្តុះបណ្តាលបទបញ្ញត្តិច្បាប់ពាក់ព័ន្ធនានាដែលជាកាតព្វកិច្ចតម្រូវចាំបាច់។

ដោយឡែកសម្រាប់បុគ្គលិកចាស់ដែលកំពុងបម្រើការងារ យើងក៏មានវគ្គបណ្តុះបណ្តាលរំលឹកបំប៉នបន្ថែមជាច្រើន ដែលផ្តោតសំខាន់លើផ្នែកផលិតភាពការងារ និងចក្ខុវិស័យ យុទ្ធសាស្ត្រសកម្មភាពចម្បងៗរបស់ធនាគារផងដែរ។ ភាពជាដៃគូក្នុងការបណ្តុះបណ្តាលបាន ផ្តល់នូវភាពពាក់ព័ន្ធយ៉ាងសំខាន់ ជាមួយវគ្គបណ្តុះបណ្តាលផ្នែកសេវាធានារ៉ាប់រងរបស់ក្រុមហ៊ុនធានារ៉ាប់រង លី ហួរ អេស ប៊ី អាយ អ៊ិនស្ឈរេន និងក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតសុវណ្ណភូមិ ឡាយហ្វ៍ ដើម្បីទទួលបានវិញ្ញាបនបត្របញ្ជាក់ជាផ្លូវការថាជាភ្នាក់ងារលក់ប្រកបដោយវិជ្ជាជីវៈខ្ពស់ និងអនុលោមភាព។

លើសពីនេះ យើងបានផ្តល់វគ្គបណ្តុះបណ្តាលសំខាន់ៗសម្រាប់នាយក/នាយិកានៃនាយកដ្ឋាន និងអ្នកគ្រប់គ្រងជាន់ខ្ពស់ រួមជាមួយកម្មវិធីពង្រឹងសមត្ថភាពគ្រូបណ្តុះបណ្តាលផ្ទៃក្នុង ដែលខិតខំប្រឹងប្រែងដើម្បីទទួលបាននូវជំនាញជាគ្រូបណ្តុះបណ្តាលប្រកបដោយវិជ្ជាជីវៈខ្ពស់ និងបន្តបន្ទាប់ដោយកម្មវិធី វិជ្ជាជីវៈគ្រប់គ្រងសាខាដែលសង្កត់ធ្ងន់លើទាំងជំនាញមុខងារ និងជំនាញទន់សម្រាប់ប្រធានសាខាផងដែរ ។

ដើម្បីជំរុញឱ្យបរិយាកាសការងារវិជ្ជមានដូច្នេះ អគ្គនាយកដ្ឋានធនធានមនុស្សផ្តោតលើកម្មវិធីសុខុមាលភាពបុគ្គលិក ដោយបានរៀបចំព្រឹត្តិការណ៍សកម្មភាពចូលរួមរបស់បុគ្គលិកក្នុងស្មារតីសាមគ្គីភាពជាក្រុមរឹងមាំចំនួន ២ ដងក្នុងមួយឆ្នាំ និងប្រារព្ធពិធីជាក់លាក់មួយចំនួនដូចជា ទិវាអន្តរជាតិនារី ៨មីនា បុណ្យចូលឆ្នាំខ្មែរ បុណ្យភ្ជុំបិណ្ឌជាដើម។ ម៉្យាងវិញទៀតការស្ទង់មតិភាពជាអ្នកដឹកនាំ និងមតិព័ត៌មានត្រលប់ពីមិត្តរួមការងារ (360 Degree Feedback) ក៏ត្រូវបានប្រមូល និងវាយតម្លៃជាប់លាប់ផងដែរ ដើម្បីបង្កើនរបៀបរបបការងារ និងភាពជាអ្នកដឹកនាំឆ្នើមនៅទូទាំងធនាគារ ដែលនាំឱ្យមានអត្រាបុគ្គលិកលាឈប់ពីការងារទាបនៅក្នុងឆ្នាំនេះ ។ ទាំងនេះក៏កំពុងជំរុញឱ្យមានវប្បធម៌លើកកម្ពស់លទ្ធផលការងារឆ្នើម ការអភិវឌ្ឍបុគ្គលិក និងការកែលម្អជាបន្តបន្ទាប់។ កន្លែងធ្វើការប្រកបដោយផាសុកភាព និងមានបរិយាបន្នទូលំទូលាយ ដែលនិយោជិតអាចផ្សារភ្ជាប់ទំនាក់ទំនងគ្នា បន្តរីកចម្រើន និងជោគជ័យជាមួយគ្នាផងដែរ។

# ១០. ទំនួលខុសត្រូវការងារសង្គម

នៅធនាគារ អេស ប៊ី អាយ លី ហ្វូ ម.ក យើងជឿជាក់ថាការទទួលខុសត្រូវរបស់យើង មានលើសពីការផ្តល់សេវាហិរញ្ញវត្ថុ។ យើងប្តេជ្ញាចិត្តយ៉ាងម៉ឺតមាំក្នុងការរួមចំណែកជាវិជ្ជមាន ដល់សហគមន៍ដែលកំពុងធ្វើប្រតិបត្តិការ និងរួមចំណែកដល់ការរីកចម្រើន និងសុខុមាលភាពទូទៅនៅព្រះរាជាណាចក្រកម្ពុជា។ ក្នុងនាមជាធនាគារដែលមានទំនួលខុសត្រូវ យើងចូលរួមយ៉ាងសកម្ម នៅក្នុងគំនិតផ្តួចផ្តើមពីការងារសង្គម និងសប្បុរសធម៌ ដើម្បីលើកកម្ពស់សុខភាព ការអប់រំ និងសុខុមាលភាព។

ការប្តេជ្ញាចិត្តរបស់យើង ត្រូវបានបង្ហាញឱ្យឃើញនៅក្នុងផលិតផលហិរញ្ញវត្ថុជាច្រើន និងកម្មវិធីផ្សព្វផ្សាយទៅកាន់សហគមន៍។ ផលិត ផលកម្ចី ចាប់ពីខ្នាតតូចរហូតដល់ទំហំធំ ត្រូវបានបង្កើតឡើងដើម្បីផ្តល់ជូនដល់ក្រុមគ្រួសារដែលមានតម្រូវការ។ លើសពីនេះ យើងជំរុញយ៉ាងសកម្មនូវការប្រើប្រាស់ប្រាក់រៀល (KHR) តាមរយៈការផ្តល់អត្រាការប្រាក់ប្រកួតប្រជែងលើផលិតផលសន្សំរបស់យើង ស្របតាមយុទ្ធនាការគាំទ្រប្រាក់រៀលរបស់ធនាគារជាតិនៃកម្ពុជា។

ដោយទទួលស្គាល់ពីសារៈសំខាន់នៃការអប់រំ យើងក៏មានផ្តល់ប្រាក់កម្ចីសម្រាប់ការសិក្សាដែលបង្កលក្ខណៈងាយស្រួលដល់និស្សិតដែលចង់បន្តការសិក្សា និងលើកទឹកចត្តិដល់ពួកគេដើម្បីធ្វើឱ្យប្រសើរឡើងចំពោះហិរញ្ញវត្ថុរបស់ពួកគេនាពេលអនាគត ព្រមទាំងចូលរួមចំណែកដល់សេដ្ឋកិច្ចជាតិទាំងមូល។ បុគ្គលិកធនាគារដែលមានការប្តេជ្ញាចិត្តខ្ពស់ ជាអ្នកទីប្រឹក្សាផ្នែកហិរញ្ញវត្ថុដល់គ្រួសារ និងអាជីវកម្មលើការប្រើប្រាស់ប្រាក់កម្ចីប្រកបដោយការទទួលខុសត្រូវ និងសារៈសំខាន់នៃការសន្សំប្រាក់ សម្រាប់សម្រេចក្តីបំណងនាពេលអនាគត និងបញ្ហាផ្សេងៗដែលអាចកើតឡើងជាយថាហេតុ។

ទំនួលខុសត្រូវការងារសង្គម នឹងជួងពង្រឹងទាំងសហគមន៍ និងអាជីវកម្មរបស់យើង ឱ្យមានកំណើនរយៈពេលវែង និងយូរអង្វែង។ គំនិតផ្តួចផ្តើមការងារសង្គមរួមមាន:

- **គាំទ្រដល់សុខុមាលភាពកុមារ៖** យើងរៀបចំយុទ្ធនាការ ៤,០០០រៀល ក្រោមប្រធានបទ "ស្នាមញញឹមកុមារ" ជាមួយនឹងការបរិច្ចាគពីបុគ្គលិក និងធនាគារដោយផ្តល់ការគាំទ្រយ៉ាងសំខាន់ដល់កុមារដែលងាយរងគ្រោះ។ យើងបានបរិច្ចាគកុំព្យូទ័រប្រើប្រាស់រួច ដែលនៅមានគុណភាពល្អ និងសម្ភារៈការិយាល័យ ដល់អង្គការស្នាមញញឹមកុមារ (PSE)" ដោយចូលរួមកាត់បន្ថយការចំណាយរបស់អង្គការ និងជួយដល់ការអប់រំរបស់កុមារ។
- **ជំនួយសហគមន៍ និងអំណោយសប្បុរសធម៌៖** យើងបានចាប់ផ្តើមយុទ្ធនាការសប្បុរសធម៌ក្រោមប្រធានបទ "បរិច្ចាគដោយក្តីស្រលាញ់" ដោយប្រមូល និងបរិច្ចាគវត្ថុប្រើប្រាស់រួចដែលនៅមានគុណភាពដល់អ្នកដែលត្រូវការ។ យើងក៏បានចូលរួមក្នុងកម្មវិធីសប្បុរសធម៌ ម៉ារ៉ាតុងដំណើរទៅកាន់មនុស្សធម៌ "Journey to Humanity" របស់ក្រុមហ៊ុន លី ហ្វូ គ្រុប ដើម្បីរៃអង្គាសថវិកាជួយដល់មន្ទីរពេទ្យគន្ធបុប្ផា ក្នុងរាជធានីភ្នំពេញ។
- **ការលើកកម្ពស់សុខភាព និងសុខុមាលភាព៖** យើងបានរៀបចំព្រឹត្តិការណ៍ "ជិះកង់ដើម្បីមិត្តភាព និងសុខុមាលភាពបុគ្គលិក" ដោយលើកកម្ពស់ពីរបៀបរស់នៅ ប្រកបដោយសុខភាពល្អ និងសាមគ្គីភាពក្នុងក្រុម។ យើងបានចូលរួមជាមួយមជ្ឈមណ្ឌលជាតិផ្តល់ឈាម (NBTC) ក្នុងព្រឹត្តិការណ៍ "ទិវាអ្នកបរិច្ចាគឈាមពិភពលោក" និង "ទិវានៃក្តីស្រឡាញ់" ដោយសង្កត់ធ្ងន់លើសារៈសំខាន់នៃការបរិច្ចាគឈាមនិងប្លាស្មា យ៉ាងទៀងទាត់។ អាវយឺតត្រូវបានជូនដល់អ្នកដែលចូលចិត្តហាត់ប្រាណ ដើម្បីលើកទឹកចិត្តដល់ការចូល រួមនៅក្នុងសហគមន៍ក្នុងសកម្មភាពហាត់ប្រាណ នៅក្នុងទិវាកុមារអន្តរជាតិ សម្រាប់ការលើកកម្ពស់សុខភាពនៅក្នុងសហគមន៍។
- **ភាពជាដៃគូសហការ៖** យើងចូលរួមយ៉ាងសកម្មក្នុងសកម្មភាពសប្បុរសធម៌ផ្សេងៗ តាមរយៈការចូលរួមជាមួយធនាគារជាតិនៃកម្ពុជា សមាគមធនាគារនៅកម្ពុជា សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា និងអង្គការផ្សេងៗទៀត។ ធនាគារ អេស ប៊ី អាយ លី ហ្វូ ម.ក នៅតែបន្តខិតខំប្រឹងប្រែងដើម្បីទទួលបានផលជាវិជ្ជមានយូរអង្វែងដល់សង្គមកម្ពុជា។

យើងនឹងបន្តបង្កើតគំនិតផ្តួចផ្តើមផ្សេងៗទៀត ក្នុងការចូលរួម លើកកំពស់សុខភាព ការអប់រំ និងសុខុមាលភាព នឹងចូលរួមចំណែកធ្វើឱ្យកាន់តែប្រសើរឡើងនាពេលអនាគតសម្រាប់ប្រជាជនកម្ពុជាទាំងអស់។











# ១១. ផលិតផល និងសេវាកម្ម


| | |
|---|---|
| ១១.១ ឥណទាន | ៤៧ |
| ១១.២ ភតិសន្យា | ៤៧ |
| ១១.៣ ប្រាក់បញ្ញើ និងសន្សំ | ៤៧ |
| ១១.៤ ធនាគារព្រីមៀរ៍ | ៤៨ |
| ១១.៥ ផ្ទេរប្រាក់ | ៤៨ |

# ១១. ផលិតផល និងសេវាកម្ម

ធនាគារផ្តល់ជូននូវផលិតផល និងសេវាកម្មជាច្រើនសម្រាប់បុគ្គល និងអាជីវកម្ម។ លើសពីផលិតផលឥណទាន និងសន្សំ យើងក៏ផ្តល់នូវផលិតផលឌីជីថល សេវាផ្ទេរប្រាក់ បង់វិលស់ និងសេវាផ្សេងៗទៀត ដើម្បីផ្តល់នូវសេវាល្អបំផុត និងគួរឱ្យទុកចិត្ត ដល់អតិថិជនរបស់យើង។

## ១១.១ ឥណទាន

ស្ថិតក្នុងស្ថានភាពប្រកួតប្រជែងក្នុងវិស័យហិរញ្ញវត្ថុ ធនាគារ អេស ប៊ី អាយ លី ហួរ ម.ក បានបង្កើតផលិតផលឥណទានច្រើនប្រភេទផ្សេងៗគ្នា សម្រាប់អតិថិជនគ្រប់ប្រភេទដែលស្ថិតនៅក្នុងវិស័យសាធារណៈ សហគ្រាស និងក្រុមហ៊ុនឯកជនផ្សេងទៀត និង  អតិថិជនដែលបច្ចុប្បន្នស្ថិតនៅក្រោមផលប័ត្ររបស់គ្រឹះស្ថានហិរញ្ញវត្ថុផ្សេងទៀត ដើម្បីប្រគួតប្រជែងក្នុងទីផ្សារ ដូចដែលមានរៀបរាប់ជូនខាងក្រោម៖

- ឥណទានបុគ្គល និងខ្នាតតូច៖
  - ឥណទានសិក្សា
  - ឥណទានណាណូ
  - ឥណទានណាណូផ្លាស
  - ឥណទានខ្នាតតូច និងខ្នាតតូចបំផុត
  - ឥណទានអាជីវកម្មខ្នាតតូច និងមធ្យម
  - ឥណទានគេហដ្ឋាន
- ឥណទានពាណិជ្ជកម្ម៖
  - ឥណទានសម្រាប់ក្រុមហ៊ុនអាជីវកម្ម
  - ឥណទានវិបារូបន៍
  - សេវាហិរញ្ញប្បទានពាណិជ្ជកម្ម

## ១១.២ ភតិសន្យា

គឺជាសេវាហិរញ្ញវត្ថុដែលអតិថិជនចង់ក្លាយជាម្ចាស់កម្មសិទ្ធិទ្រព្យដោយមិនចាំបាច់មានប្រាក់ទាំងអស់ នោះទេដោយគ្រាន់តែទូទាត់ប្រាក់ជាមុនមួយចំនួន (ប្រាក់បង់មុន) និងបង់ប្រចាំខែ ឬមធ្យោបាយផ្សេងៗទៀតជាមួយលក្ខខណ្ឌជាក់លាក់នៃកិច្ចព្រមព្រៀង។

អតិថិជននឹងក្លាយជាម្ចាស់ទ្រព្យជួលនៅពេលដែលការទូទាត់ត្រូវបានទូទាត់រួចរាល់នៅចុងបញ្ចប់នៃកិច្ចព្រមព្រៀង។

- សេវាភតិសន្យាហិរញ្ញវត្ថុ ម៉ូតូ
- សេវាភតិសន្យាហិរញ្ញវត្ថុ គ្រឿងចក្រធុនធ្ងន់

## ១១.៣ ប្រាក់បញ្ញើ និងសន្សំ

ធនាគារ អេស ប៊ី អាយ លី ហួរ ម.ក មានផលិតផលប្រាក់បញ្ញើ និងសន្សំជាច្រើនប្រភេទដែលត្រូវបានបង្កើតឡើងដើម្បីផ្តល់អត្ថប្រយោជន៍ដល់គ្រប់វិស័យអាជីវកម្មនៅក្នុងសហគមន៍កម្ពុជា។

ផលិតផល និងសេវាកម្មខាងក្រោមត្រូវបានបង្កើតឡើងយ៉ាងពិសេសដើម្បីបំពេញតម្រូវការ និងផ្តល់ភាពងាយស្រួលដល់អតិថិជនរបស់យើងបានគ្រប់តម្រូវការទៅលើវិស័យធនាគារ។



ការទូទាត់អាចធ្វើឡើងតាមរយៈកម្មវិធីទូរសព្ទដៃ សាច់ប្រាក់ និងមូលប្បទានបត្រ ផ្ទេរសាច់ប្រាក់ចេញចូលនៅក្នុងប្រទេស និងទៅក្រៅប្រទេស។ អ្វីដែលគួរឱ្យចាប់អារម្មណ៍បំផុត គណនីរបស់យើងអាចទទួលបានការប្រាក់បង្គរជារៀងរាល់ថ្ងៃ។ ផលិតផលសំខាន់ៗ រួមមាន៖

- គណនីចរន្ត
- គណនីសន្សំ
- គណនីព្រីមៀរ៍
- គណនីបញ្ញើមានកាលកំណត់
- គណនីចម្រើនផែនការអនាគត
- គណនីចម្រើនតាមបំណង

## ១១.៤ ធនាគារព្រីមៀរ៍

សូមរីករាយជាមួយភាពជាឯកសិទ្ធិ ភាពជាឯកជន និងទីកន្លែងដែលមានផាសុកភាពដើម្បីពិភាក្សាអំពីតម្រូវការហិរញ្ញវត្ថុ និងដំណោះស្រាយសម្រាប់សេវាធនាគារជាមួយប្រធានផ្នែកទំនាក់ទំនងរបស់ធនាគារសម្រាប់អ្នក។

រីករាយជាមួយការផ្តល់ជូននូវកាហ្វេ Espresso ឬ Latté និងការប្រើប្រាស់ Wi-Fi ដោយឥតគិតថ្លៃទៅតាមតម្រូវការរបស់អ្នក។ សូមអញ្ជើញទៅកាន់ទីតាំងធនាគារព្រីមៀរ៍ណាមួយក៏បានទាំងប្រាំមួយទីតាំងដែលនៅជិត និងមានភាពងាយស្រួលសម្រាប់អ្នកនៅតាមសាខារបស់ធនាគាររួមមាន៖

- សាខា៧មករា
- សាខាចំការមន
- សាខាទួលគោក
- សាខាឫស្សីកែវ
- សាខាច្បារអំពៅ(២)
- សាខាពោធិ៍សែនជ័យ

## ១១.៥ ផ្ទេរប្រាក់

អត្ថប្រយោជន៍នៃការប្រើប្រាស់សេវាផ្ទេរប្រាក់ គឺមានភាពងាយស្រួល ប្រសិទ្ធភាពខ្ពស់ ភាពជឿជាក់ និងឆាប់រហ័ស។ ការផ្តួចផ្តើមរបស់យើងក្នុងការសហការជាមួយធនាគារទាំងក្នុង និងក្រៅប្រទេស  ជាមួយនឹងសេវាផ្ទេរប្រាក់ដែលអាចជឿទុកចិត្តបាន។ ផលិតផលសំខាន់រួមមាន៖

- សេវាផ្ទេរប្រាក់ក្នុងស្រុក
- សេវាទូទាត់រហ័សក្នុងស្រុក
- សេវាផ្ទេរប្រាក់ក្រៅប្រទេសតាមរយៈប្រព័ន្ធស្វីស
- ការផ្ទេរប្រាក់ក្រៅប្រទេសតាមប្រព័ន្ធរីបផល
- បេឡាជាតិសន្តិសុខសង្គម (ប.ស.ស)




# ១២. ធនាគារ ឌីជីថល


| | |
|---|---|
| ១២.១ អេធីអឹម | ៥១ |
| ១២.២ កម្មវិធីធនាគារចល័ត | ៥៣ |
| ១២.៣ បញ្ជរ QR | ៥៤ |
| ១២.៤ បណ្ណធនាគារ អេស ប៊ី អាយ លី ហួរ | ៥៥ |

## ១២.១ អេធីអឹម

ម៉ាស៊ីនអេធីអឹមរបស់យើង គឺជាម៉ាស៊ីនច្រកចេញចូលតែមួយដែល អនុញ្ញាតឱ្យអ្នកធ្វើប្រតិបត្តិការហិរញ្ញវត្ថុច្រើនក្នុងរយៈពេលប៉ុន្មាននាទីប៉ុណ្ណោះ និងជាបណ្តាញអេធីអឹមដ៏ធំទូលាយដែល ជួយឱ្យអ្នកអាចចូលទៅកាន់គណនីរបស់អ្នកបានភ្លាមៗ គ្រប់ពេលវេលា។ ម៉ាស៊ីនអេធីអឹម របស់យើង អនុញ្ញាតឱ្យអ្នកធ្វើប្រតិបត្តិការហិរញ្ញវត្ថុមូលដ្ឋានដែលជាសាច់ប្រាក់ និងបណ្ណក្នុង ២៤/៧ ដោយមិនត្រូវការទៅកាន់បញ្ជររបស់ធនាគារឡើយ៖

- ដក និង ដាក់ប្រាក់ បានជាប្រាក់រៀល និងដុល្លារអាមេរិក
- ពិនិត្យសមតុល្យសាច់ប្រាក់
- ប្ដូរលេខសម្ងាត់របស់បណ្ណ
- ទាញយករបាយការណ៍សង្ខេប






## ១២.២ កម្មវិធីធនាគារចល័ត

កម្មវិធីធនាគារចល័ត អេស ប៊ី អាយ លី ហួរ គឺសម្រាប់អតិថិជនដែលចូលប្រើប្រាស់គណនីរបស់ពួកគេបានគ្រប់ពេលវេលា គ្រប់ទីកន្លែង និងមានភាពងាយស្រួល ហើយជាកម្មវិធីធនាគារចល័តដែលបម្រើប្រជាជនកម្ពុជាទូទាំងប្រទេស និងជាដៃគូធនាគារចល័តដែលអ្នកទុកចិត្តបាន។

កម្មវិធីធនាគារចល័ត អេស ប៊ី អាយ លី ហួរ គឺបង្កើតឡើងដើម្បីបំពេញតម្រូវការ និងជួយក្នុងការគ្រប់គ្រងសមតុល្យរបស់អ្នកប្រកបដោយប្រសិទ្ធភាព។ អ្នកអាចពិនិត្យមើលសមតុល្យរបស់អ្នកភ្លាមៗ និងមានភាពងាយស្រួលធ្វើការបង់វិក្កយបត្របានយ៉ាងឆាប់រហ័ស មានភាពងាយស្រួលក្នុងការបើកគណនី និងទទួលបាននូវមុខងារដ៏អស្ចារ្យជាច្រើនទៀតដែលមានរៀបរាប់ដូចខាងក្រោម។ ធ្វើការទាញយក កម្មវិធីធនាគារចល័ត អេស ប៊ី អាយ លី ហួរ នៅថ្ងៃនេះ ដើម្បីទទួលបានបទពិសោធន៍ថ្មី!






## ១២.៣ បញ្ជរ QR

ឥឡូវនេះ អ្នកអាចមកកាន់សាខារបស់ធនាគារ ដើម្បីធ្វើការដាក់ប្រាក់ ឬដកប្រាក់យ៉ាងរលូនដោយមិនចាំបាច់មានឯកសារ ហត្ថលេខាឡើយ ដោយគ្រាន់តែចូលទៅកាន់កម្មវិធីធនាគារចល័ត អេស ប៊ី អាយ លី ហួរ ហើយស្កេន KHQR នៅលើបញ្ជរ ដើម្បីចាប់ផ្តើមប្រតិបត្តិការ។ ហេរញ្ញិកនៅតាមបញ្ជរនឹងចាប់ផ្តើមដំណើរការ និងបម្រើការទៅតាមតម្រូវការរបស់អ្នក។



## ១២.៤ បណ្ណធនាគារ អេស ប៊ី អាយ លី ហួរ

បណ្ណធនាគារ អេស ប៊ី អាយ លី ហួរ ជាបណ្ណដែលផ្តល់ជូននូវបទពិសោធន៍ និងអត្ថប្រយោជន៍ជាច្រើនយ៉ាង ហើយត្រូវបាន រចនាឡើងជាមួយភាពល្អឥតខ្ចោះសម្រាប់អតិថិជនរបស់យើង និងការផ្តោតទៅលើការផ្តល់នូវសេវាកម្មដ៏ពិសេសពីធនាគារដែលប្រកបទៅដោយសុវត្ថិភាព ឯកជនភាព និងការយកចិត្តទុកដាក់យ៉ាងដិតដល់នៅធនាគារ អេស ប៊ី អាយ លី ហួរ ម.ក និងឯកសិទ្ធិពិសេសក្នុងការចូលទៅកាន់កន្លែងសម្រាកនៅអាកាសយានដ្ឋាន សណ្ឋាគារ ហាងទំនើបៗ ភោជនីយដ្ឋាន ជាច្រើនទៀត ជុំវិញសកលលោក រួមទាំងអត្ថប្រយោជន៍ជាច្រើនដូចជា៖

- បណ្ណស៊ីអេសអេស (CSS) របស់ធនាគារ អាចធ្វើប្រតិបត្តិការបាននៅតាមបណ្តាម៉ាស៊ីនអេធីអឹម ជាប្រាក់រៀល និង/ឬ ប្រាក់ដុល្លារអាមេរិក ជាមួយតម្លៃសេវាទាបបំផុតទូទាំងប្រទេស។
- មានភាពងាយស្រួល និងប្រើប្រាស់ទូទាំងពិភពលោក គ្រប់ទីកន្លែងដែលមានទទួលយកបណ្ណវីសា (VISA)។
- ធ្វើការទូទាត់ ឬទិញទំនិញតាមរយៈម៉ាស៊ីនឆូតបណ្ណ និងតាមអ៊ីនធឺណិត។
- ដកប្រាក់ពីម៉ាស៊ីនអេធីអឹម ជាង ២លានកន្លែងនៅទូទាំងពិភពលោក។
- សុវត្ថិភាពក្នុងការបញ្ជាទិញតាមអ៊ីនធឺណិតជាមួយបច្ចេកវិទ្យាចុងក្រោយបំផុត 3DS។
- សុវត្ថិភាពខ្ពស់នៃការទិញតាមអ៊ីនធឺណិតជាមួយបច្ចេកវិទ្យាលេខកូដផ្ទៀងផ្ទាត់សុវត្ថិភាព (OTP)។
- ការជូនដំណឹងសារអេឡិចត្រូនិច (SMS) លើគ្រប់ប្រតិបត្តិការ។
- រីករាយជាមួយប្រូម៉ូសិនដ៏ច្រើនសន្ធឹកសន្ធាប់ពី វីសា (VISA) នៅទូទាំងពិភពលោក។
- ប្រតិបត្តិការសង្ខេបនៅលើកម្មវិធីទូរសព្ទចល័ត អេស ប៊ី អាយ លី ហួរ ។
- កាន់តែងាយស្រួល និងមានសុវត្ថិភាពជាងកាន់សាច់ប្រាក់។
- ទទួលបានសាច់ប្រាក់ត្រឡប់មកវិញរហូតដល់ ១% ។
- សមាជិកបណ្ណមាស និងបណ្ណផ្លាទីនៀម ទទួលបានការធានារ៉ាប់រង លើការធ្វើដំណើររហូតដល់ ១ លានដុល្លារអាមេរិក។
- ចូលទៅកន្លែងសម្រាកនៅអាកាសយានដ្ឋានជាង ១.៣០០ កន្លែងនៅទូទាំងពិភពលោកសម្រាប់សមាជិកបណ្ណមាស និងបណ្ណផ្លាទីនៀម។



# ពានរង្វាន់ឈានមុខគេ

ពានរង្វាន់ឈានមុខគេ ខាងផ្នែកចេញប័ណ្ណឥណទាន និងប័ណ្ណឥណពន្ធ
ជូនអតិថិជន និងការអនុម័តឥណទានសម្រាប់ការទូទាត់
តាមប្រព័ន្ធអេឡិចត្រូនិក




# ពានរង្វាន់ផ្នែកនវានុវត្តន៍ **ឆ្នាំ ២០២៤** ពីក្រុមហ៊ុនវីសា!





# ១៣. របាយការណ៍ហិរញ្ញវត្ថុ


| | | |
|---|---|---|
| ១៣.១ | របាយការណ៍ក្រុមប្រឹក្សាភិបាល | ៦១ |
| ១៣.២ | របាយការណ៍សវនករឯករាជ្យ | ៦៥ |
| ១៣.៣ | របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ | ៦៩ |
| ១៣.៤ | របាយការណ៍ចំណេញ-ខាត និងលទ្ធផលលម្អិតផ្សេងៗ | ៧០ |
| ១៣.៥ | របាយការណ៍បម្រែបម្រួលមូលធន | ៧១ |
| ១៣.៦ | របាយការណ៍លំហូរសាច់ប្រាក់ | ៧៣ |

# ១៣.១ របាយការណ៍ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលសូមបង្ហាញរបាយការណ៍របស់ខ្លួន និងរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើ សវនកម្មរួចរបស់ធនាគារ អេស ប៊ី អាយ លី ហួរ ម.ក (ហៅកាត់ថា ធនាគារ) សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤។

## សកម្មភាពអាជីវកម្មចម្បង

គោលដៅរបស់ធនាគារគឺធ្វើការផ្តល់ជូននូវអាជីវកម្មធនាគារពាណិជ្ជទាំងអស់ដល់រូបវន្តបុគ្គល សហគ្រាសធុន តូចនិងមធ្យម ក្រុមហ៊ុន និងសាជីវកម្មទូទៅ ដើម្បីចូលរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម នៅក្នុងប្រទេសកម្ពុជា និងកន្លែងផ្សេងៗទៀត ដូចដែលបានធ្វើឡើងដោយធនាគារពាណិជ្ជអន្តរជាតិទាំងអស់។ គោលបំណងរបស់ធនាគារគឺដើម្បីជួយដល់ប្រទេសកម្ពុជា អាជីវកម្ម និងប្រជាពលរដ្ឋកម្ពុជា ក្នុងការលើកកម្ពស់ជីវភាពរស់នៅ និងការរីកលូតលាស់ក្នុងអាជីវកម្ម ដោយធ្វើការផ្តល់នូវសេវាធនាគារប្រកបដោយវិជ្ជាជីវៈខ្ពស់ បច្ចេកវិទ្យាជឿនលឿនក្នុងវិស័យធនាគារ ជាមួយនឹងហិរញ្ញប្បទានដែលមានលក្ខណៈសមរម្យ។

ធនាគារ មានសកម្មភាពអាជីវកម្មចម្បងៗដូចខាងក្រោម៖

ក. ប្រតិបត្តិការនៃសកម្មភាពធនាគារតាមរយៈការផ្តល់សេវាធនាគារ និង

ខ. សកម្មភាពអាជីវកម្មផ្សេងទៀត ដែលត្រូវបានចាត់ទុកថាសមស្របចំពោះធនាគារ និងដែលអនុលោមទៅតាមបទប្បញ្ញត្តិរបស់ធនាគារជាតិនៃកម្ពុជា។

## លទ្ធផលហិរញ្ញវត្ថុ

លទ្ធផលហិរញ្ញវត្ថុរបស់ធនាគារសម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ ត្រូវបានបង្ហាញក្នុងរបាយការណ៍ចំណេញ-ខាត និងលទ្ធផលលម្អិតផ្សេងៗ នៅលើទំព័រទី៧០។

ក្នុងអំឡុងឆ្នាំ មិនមានការប្រកាស ឬទូទាត់ភាគលាភទេ។

## ដើមទុន

ក្នុងអំឡុងឆ្នាំ  មិនមានការផ្លាស់ប្តូរភាគទុនិក និងរចនាសម្ព័ន្ធនៃការកាន់កាប់ភាគហ៊ុនរបស់ធនាគារទេ។

## ឥណទាន និងបុរេប្រទានអាក្រក់ និងសង្ស័យ

មុនពេលរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ក្រុមប្រឹក្សាភិបាលបានចាត់វិធានការដែលមានមូលដ្ឋានសមស្រប ពាក់ព័ន្ធទៅនឹងការជម្រះឥណទាន និងបុរេប្រទានអាក្រក់ចេញពីបញ្ជី និងការកត់ត្រាសំវិធានធនសម្រាប់ការខាតបង់ដែលបណ្តាលមកពីការថយចុះតម្លៃ ហើយបានយល់ស្របថារាល់ឥណទាន និងបុរេប្រទានអាក្រក់ទាំងអស់ដែលបានដឹង ត្រូវបានជម្រះចេញពីបញ្ជី និងបានកត់ត្រាសំវិធានធនសម្រាប់ការខាតឥណទាន និងបុរេប្រទានអាក្រក់ និងសង្ស័យពេញលេញ។

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ និងផ្អែកលើកម្រិតនៃការយល់ដឹង ក្រុមប្រឹក្សាភិបាលពុំបានដឹងពីកាលៈទេសៈណាមួយ ដែលនាំឱ្យចំនួនឥណទាន និងបុរេប្រទានអាក្រក់ដែលបានជម្រះចេញពីបញ្ជី ឬចំនួនសំវិធានធនសម្រាប់ការខាតបង់ដែលបណ្តាលមកពីការថយចុះតម្លៃ ក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ មានតម្លៃមិនគ្រប់គ្រាន់ជាសារវន្តនោះទេ។

## ទ្រព្យសកម្ម

មុនពេលរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ក្រុមប្រឹក្សាភិបាលបានចាត់វិធានការដែលមានមូលដ្ឋានសមស្រប ដើម្បីបញ្ជាក់ថាបណ្តាទ្រព្យសកម្មទាំងឡាយ ដែលទំនងជាមិនអាចបង្វិលមកវិញនៅក្នុងប្រតិបត្តិការអាជីវកម្មធម្មតា ទៅតាមតម្លៃក្នុងបញ្ជីគណនេយ្យរបស់ធនាគារ ត្រូវបានកត់ត្រាបន្ថយឱ្យនៅស្មើនឹងតម្លៃដែលរំពឹងថានឹងអាចលក់បាននៅលើទីផ្សារជាក់ស្តែង។

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ និងផ្អែកលើកម្រិតនៃការយល់ដឹង ក្រុមប្រឹក្សាភិបាលពុំបានដឹងពីកាលៈទេសៈណាមួយ ដែលអាចបណ្តាលឱ្យតម្លៃនៃទ្រព្យសកម្មនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារមិនត្រឹមត្រូវជាសារវន្តនោះទេ។

## បំណុលយថាហេតុ និងបំណុលផ្សេងៗ

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ៖

ក. មិនមានបន្ទុកណាមួយលើទ្រព្យសកម្មរបស់ធនាគារ ដែលបានកើតឡើងដោយសារការដាក់បញ្ចាំសម្រាប់ការធានាបំណុលរបស់បុគ្គលណាម្នាក់ឡើយ ចាប់តាំងពីដំណាច់ឆ្នាំមក និង

ខ. មិនមានបំណុលយថាហេតុណាមួយរបស់ធនាគារ ដែលបានកើតឡើងចាប់តាំងពីដំណាច់ឆ្នាំមក ក្រៅពីបំណុលផ្សេងៗនៅក្នុងដំណើរការអាជីវកម្មធម្មតានោះទេ។

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល ពុំមានបំណុលយថាហេតុ ឬបំណុលផ្សេងៗរបស់ធនាគារ ដែលត្រូវបានទាមទារឱ្យសង ឬអាចនឹងត្រូវបានទាមទារឱ្យសងក្នុងរយៈពេល១២ខែ បន្ទាប់ពីដំណាច់ឆ្នាំ ដែលនឹង ឬអាចនឹងមានផលប៉ះពាល់ជាសារវន្តដល់លទ្ធភាពរបស់ធនាគារ ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួននៅថ្ងៃដល់ពេលកំណត់សងនោះទេ។

## ការប្រែប្រួលកាលៈទេសៈ

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលមិនបានដឹងពីកាលៈទេសៈណាមួយដែលមិនបានឆ្លុះបញ្ចាំងនៅក្នុងរបាយការណ៍នេះ ឬរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ដែលអាចបណ្តាលឱ្យចំនួនទឹកប្រាក់ដែលបានបង្ហាញក្នុងរបាយការណ៍ហិរញ្ញវត្ថុ មានភាពមិនត្រឹមត្រូវជាសារវន្តនោះទេ។

## ប្រតិបត្តិការមិនប្រក្រតី

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល លទ្ធផលនៃប្រតិបត្តិការរបស់ធនាគារសម្រាប់ឆ្នាំហិរញ្ញវត្ថុនេះមិនមានរងនូវផលប៉ះពាល់ជាសារវន្តពីគណនី ប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលមានលក្ខណៈជាសារវន្ត  និងមិនធម្មតានោះទេ។ តាមយោបល់របស់ក្រុមប្រឹក្សាភិបាល នៅចន្លោះពេលរវាងដំណាច់ឆ្នាំហិរញ្ញវត្ថុ មកទល់នឹងកាលបរិច្ឆេទនៃរបាយការណ៍នេះ មិនមានគណនី ប្រតិបត្តិការ ឬ  ព្រឹត្តិការណ៍ណាមួយដែលមានលក្ខណៈជាសារវន្ត និងមិនធម្មតាដែលទំនងជាមានផលប៉ះពាល់ជាសារវន្តដល់លទ្ធផលនៃប្រតិបត្តិការរបស់ធនាគារ ក្នុងឆ្នាំហិរញ្ញវត្ថុដែលរបាយការណ៍នេះត្រូវបានធ្វើឡើងនោះទេ។

## ក្រុមប្រឹក្សាភិបាល

សមាជិកក្រុមប្រឹក្សាភិបាលរបស់ធនាគារដែលនៅបម្រើការក្នុងអំឡុងឆ្នាំ រហូតដល់កាលបរិច្ឆេទនៃរបាយការណ៍នេះមានរាយនាមដូចខាងក្រោម៖

| | |
|---|---|
| លោក Shuzo Shikata | ប្រធានក្រុមប្រឹក្សាភិបាល |
| លោក Makoto Miyazaki | អភិបាល |
| លោក Eiichiro So | អភិបាល |
| អ្នកឧកញ៉ា លី សុភ័ក្ត | អភិបាល |
| អ្នកឧកញ៉ា លី សុភាព | អភិបាល |
| លោក ខែក វ៉ាវី | អភិបាលឯករាជ្យ |
| លោក ហួរ វរៈបុត្ត | អភិបាលឯករាជ្យ |
| លោកស្រី Wan Chi Ng | អភិបាលឯករាជ្យ |

## ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលទទួលខុសត្រូវក្នុងការបញ្ជាក់ថារបាយការណ៍ហិរញ្ញវត្ថុបានបង្ហាញត្រឹមត្រូវនូវគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់នៃស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់សម្រាប់ដំណាច់ឆ្នាំ ដោយអនុលោមទៅតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (ហៅកាត់ថា CIFRS)។

ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ តម្រូវឱ្យក្រុមប្រឹក្សាភិបាល ៖

i) អនុវត្តគោលការណ៍គណនេយ្យសមស្រប ដែលគាំទ្រដោយការវិនិច្ឆ័យ និងការប៉ាន់ស្មានសមហេតុផល និងប្រកបដោយការប្រុងប្រយ័ត្ន ព្រមទាំងអនុវត្តតាមគោលការណ៍ទាំងនោះឱ្យមានសង្គតិភាព។

ii) អនុវត្តតាមតម្រូវការក្នុងការលាតត្រដាងព័ត៌មានរបស់ CIFRS ឬប្រសិនបើមានការប្រាសចាកណាមួយក្នុងការបង្ហាញឱ្យមានភាពត្រឹមត្រូវ ការប្រាសចាកទាំងនោះត្រូវបានលាតត្រដាង ពន្យល់ និងកំណត់ចំនួនទឹកប្រាក់ឱ្យបានត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

iii) រក្សាទុកកំណត់ត្រាគណនេយ្យឱ្យបានគ្រប់គ្រាន់ និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងមួយប្រកបដោយប្រសិទ្ធភាព។

iv) រៀបចំរបាយការណ៍ហិរញ្ញវត្ថុដោយផ្អែកលើមូលដ្ឋាននិរន្តរភាពនៃដំណើរការអាជីវកម្ម លើកលែងតែមានករណីមិនសមស្របក្នុងការសន្មតថា ធនាគារអាចបន្តប្រតិបត្តិការអាជីវកម្មនៅពេលអនាគតដ៏ខ្លី និង

v) គ្រប់គ្រងនិងដឹកនាំធនាគារឱ្យមានប្រសិទ្ធភាព តាមរយៈការសម្រេចចិត្តជាសារវន្តទាំងអស់ដែលជះឥទ្ធិពលដល់ប្រតិបត្តិការ និងលទ្ធផលរបស់ធនាគារ ហើយត្រូវធានាថាផលប៉ះពាល់ទាំងនោះត្រូវបានឆ្លុះបញ្ចាំងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាលអះអាងថា ធនាគារបានអនុវត្តតាមតម្រូវការខាងលើក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។



## ការអនុម័តរបាយការណ៍ហិរញ្ញវត្ថុ

របាយការណ៍ហិរញ្ញវត្ថុដែលបានភ្ជាប់មកជាមួយ ព្រមទាំងកំណត់សម្គាល់ទាំងឡាយ បានបង្ហាញត្រឹមត្រូវនូវគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់នៃស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ និងលទ្ធផលហិរញ្ញវត្ថុ ព្រមទាំងលំហូរសាច់ប្រាក់របស់ធនាគារ សម្រាប់ដំណាច់ឆ្នាំ ដោយអនុលោមទៅតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាល។

ចុះហត្ថលេខាយោងទៅតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល

**លោក Shuzo Shikata**
**ប្រធានក្រុមប្រឹក្សាភិបាល**

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៥

## ១៣.២ របាយការណ៍សវនកររឯករាជ្យ

### ជូនភាគទុនិករបស់ធនាគារ អេស ប៊ី អាយ លី ហួរ ម.ក

### មតិយោបល់របស់យើងខ្ញុំ

តាមមតិយោបល់របស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុបានបង្ហាញត្រឹមត្រូវនូវគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់ នៃស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារ អេស ប៊ី អាយ លី ហួរ ម.ក (ហៅកាត់ថា ធនាគារ) គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ និងលទ្ធផលហិរញ្ញវត្ថុ ព្រមទាំងលំហូរសាច់ប្រាក់សម្រាប់ដំណាច់ឆ្នាំ ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (ហៅកាត់ថា CIFRS)។

*របាយការណ៍ដែលយើងខ្ញុំបានធ្វើសវនកម្ម*

របាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ រួមមាន៖

- របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤
- របាយការណ៍ចំណេញ-ខាត និងលទ្ធផលលម្អិតផ្សេងៗ សម្រាប់ដំណាច់ឆ្នាំ
- របាយការណ៍បម្រែបម្រួលមូលធន សម្រាប់ដំណាច់ឆ្នាំ
- របាយការណ៍លំហូរសាច់ប្រាក់ សម្រាប់ដំណាច់ឆ្នាំ និង
- កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ រួមទាំងព័ត៌មានគោលការណ៍គណនេយ្យជាសារវន្ត និងព័ត៌មានពន្យល់ផ្សេងៗទៀត។

### មូលដ្ឋាននៃមតិយោបល់របស់យើងខ្ញុំ

យើងខ្ញុំបានធ្វើសវនកម្មដោយអនុលោមទៅតាម ស្តង់ដាអន្តរជាតិស្តីពីសវនកម្មនៃកម្ពុជា (ហៅកាត់ថា ស្តង់ដា សវនកម្ម)។ ការទទួលខុសត្រូវរបស់យើងខ្ញុំដែលអនុលោមទៅតាមស្តង់ដាទាំងនោះ ត្រូវបានពណ៌នាបន្ថែមទៀតនៅក្នុងកថាខណ្ឌ *ការទទួលខុសត្រូវរបស់សវនករក្នុងការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ* នៅក្នុងរបាយការណ៍សវនកររបស់យើងខ្ញុំ។

យើងខ្ញុំជឿជាក់ថាភ័ស្តុតាងសវនកម្មដែលយើងខ្ញុំបានទទួល មានភាពគ្រប់គ្រាន់ និងសមហេតុផល ដើម្បីធ្វើជាមូលដ្ឋានសម្រាប់ការបញ្ចេញមតិយោបល់របស់យើងខ្ញុំ។

*ឯករាជ្យ*

យើងខ្ញុំមានឯករាជ្យពីធនាគារ ដែលអនុលោមទៅតាមក្រមសីលធម៌អន្តរជាតិ សម្រាប់គណនេយ្យករវិជ្ជាជីវៈ (រួមទាំងស្តង់ដាឯករាជ្យអន្តរជាតិ) ដែលចេញផ្សាយដោយក្រុមប្រឹក្សាស្តង់ដាក្រមសីលធម៌អន្តរជាតិសម្រាប់គណនេយ្យករ(ហៅកាត់ថា ក្រមសីលធម៌អន្តរជាតិ) និងអនុលោមទៅតាមក្រមសីលធម៌របស់វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា (ហៅកាត់ថា ក្រមសីលធម៌ វគសក) ដែលពាក់ព័ន្ធនឹងការធ្វើសវនកម្មរបស់យើងខ្ញុំ ចំពោះរបាយការណ៍ហិរញ្ញវត្ថុ នៅក្នុងប្រទេសកម្ពុជា។ យើងខ្ញុំបានបំពេញកាតព្វកិច្ចក្នុងការទទួលខុសត្រូវផ្អែកក្រមសីលធម៌ផ្សេងៗទៀត ដែលកំណត់ដោយក្រមសីលធម៌អន្តរជាតិ និងក្រមសីលធម៌ វគសក។

### ព័ត៌មានផ្សេងៗ

គណៈគ្រប់គ្រងទទួលខុសត្រូវចំពោះព័ត៌មានផ្សេងៗ។ ព័ត៌មានផ្សេងៗដែលយើងខ្ញុំបានទទួលនាកាលបរិច្ឆេទនៃរបាយការណ៍សវនករនេះរួមមាន របាយការណ៍ក្រុមប្រឹក្សាភិបាល និងព័ត៌មានហិរញ្ញវត្ថុបន្ថែមទៅតាម តម្រូវការរបស់ធនាគារជាតិ នៃ កម្ពុជា ប៉ុន្តែមិនរួមបញ្ចូលនូវរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សវនកររបស់យើងខ្ញុំទេ។



មតិយោបល់របស់យើងខ្ញុំចំពោះរបាយការណ៍ហិរញ្ញវត្ថុ ពុំបានគ្របដណ្តប់ទៅលើព័ត៌មានផ្សេងៗនោះទេ ហើយយើងខ្ញុំមិនធ្វើការធានាអះអាងចំពោះព័ត៌មានទាំងនោះទេ។

ទាក់ទងនឹងការធ្វើសវនកម្មរបស់យើងខ្ញុំទៅលើរបាយការណ៍ហិរញ្ញវត្ថុ យើងខ្ញុំទទួលខុសត្រូវក្នុងការអានព័ត៌មានផ្សេងៗ ដើម្បីពិចារណាថាតើព័ត៌មានផ្សេងៗទាំងនោះមានភាពផ្ទុយគ្នាជាសារវន្តពីរបាយការណ៍ហិរញ្ញវត្ថុ ឬផ្ទុយពីការយល់ដឹងរបស់យើងខ្ញុំផ្អែកលើលទ្ធផលនៃការធ្វើសវនកម្ម ឬមានការរាយការណ៍ពីកំហុសឆ្គងជាសារវន្តដែលបានកើតឡើងឬទេ។

ផ្អែកទៅលើការងារដែលយើងខ្ញុំបានបំពេញ ទៅលើព័ត៌មានផ្សេងៗដែលយើងបានទទួល មុនកាលបរិច្ឆេទនៃរបាយការណ៍សវនករនេះ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថាមានកំហុសឆ្គងជាសារវន្តដែលកើតចេញពីព័ត៌មានផ្សេងៗទាំងនេះ យើងខ្ញុំត្រូវរាយការណ៍ពីអង្គហេតុនៃកំហុសឆ្គងទាំងនោះ។ យើងខ្ញុំមិនមានអ្វីត្រូវរាយការណ៍ចំពោះបញ្ហានេះទេ។

### ការទទួលខុសត្រូវរបស់គណៈគ្រប់គ្រង និងអ្នកដែលទទួលបន្ទុកលើអភិបាលកិច្ចចំពោះរបាយការណ៍ហិរញ្ញវត្ថុ

គណៈគ្រប់គ្រងទទួលខុសត្រូវក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ និងបង្ហាញរបាយការណ៍ទាំងនោះឱ្យបានត្រឹមត្រូវ ដោយអនុលោមទៅតាម CIFRS និងទទួលខុសត្រូវលើការត្រួតពិនិត្យផ្ទៃក្នុង ដែលគណៈគ្រប់គ្រងកំណត់ថាមានភាពចាំបាច់ក្នុង ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុឱ្យចៀសផុតពីការរាយការណ៍ខុសជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គងផ្សេងៗ។

ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ គណៈគ្រប់គ្រងទទួលខុសត្រូវក្នុងការវាយតម្លៃអំពីលទ្ធភាពរបស់ធនាគារ ក្នុងការបន្តនិរន្តរភាពអាជីវកម្ម ការលាតត្រដាងព័ត៌មានដែលពាក់ព័ន្ធ ក៏ដូចជាបញ្ហាផ្សេងៗដែលទាក់ទិនទៅនឹងនិរន្តរភាពអាជីវកម្មដោយប្រើមូលដ្ឋានគណនេយ្យសម្រាប់និរន្តរភាពអាជីវកម្ម លើកលែងតែគណៈគ្រប់គ្រងមានគម្រោងបិទអាជីវកម្មរបស់ធនាគារ ឬបញ្ឈប់ប្រតិបត្តិការ ឬដោយមិនមានជម្រើសណាផ្សេងប្រកបដោយភាពប្រាកដប្រជាណាមួយ។

អ្នកដែលទទួលបន្ទុកលើអភិបាលកិច្ច ទទួលខុសត្រូវក្នុងការត្រួតពិនិត្យដំណើរការនៃការរាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ។

### ការទទួលខុសត្រូវរបស់សវនករ ក្នុងការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ

គោលបំណងរបស់យើងខ្ញុំ គឺស្វែងរកអំណះអំណាងដែលសមហេតុផល ថារបាយការណ៍ហិរញ្ញវត្ថុទាំងមូលពុំមានការរាយការណ៍ខុសជាសារវន្តដែលបណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គងផ្សេងៗ និងចេញរបាយការណ៍សវនករដែលមានមតិយោបល់របស់យើងខ្ញុំ។ អំណះអំណាងដែលសមហេតុផលគឺជាការអះអាងក្នុងកម្រិតខ្ពស់ ប៉ុន្តែវាមិនមែនជាការធានាថាសវនកម្មដែលបានធ្វើឡើង ដោយអនុលោមទៅតាមស្តង់ដាសវនកម្ម តែងតែរកឃើញជានិច្ចនូវការរាយការណ៍ខុសជាសារវន្តដែលបានកើតឡើងនោះទេ។ ការរាយការណ៍ខុសអាចកើតឡើងពីការក្លែងបន្លំ ឬកំហុសឆ្គង ហើយវាត្រូវបានចាត់ទុកថាមានលក្ខណៈជាសារវន្ត ប្រសិនបើការរាយការណ៍ខុសនីមួយៗ ឬការរាយការណ៍ខុសសរុប អាចត្រូវបានរំពឹងថា វាជះឥទ្ធិពលលើមូលដ្ឋាននៃការសម្រេចចិត្តផ្អែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុទាំងនេះ។

ផ្នែកមួយនៃការធ្វើសវនកម្មដែលអនុលោមទៅតាមស្តង់ដាសវនកម្ម តម្រូវឱ្យយើងខ្ញុំប្រើប្រាស់ការវិនិច្ឆ័យប្រកបដោយវិជ្ជាជីវៈ និងរក្សាការសង្ស័យស្របតាមវិជ្ជាជីវៈ ក្នុងពេលបំពេញការងារសវនកម្មរបស់យើងខ្ញុំ។ យើងខ្ញុំ៖

- កំណត់ និងវាយតម្លៃហានិភ័យនៃភាពខុសជាសារវន្តនៃរបាយការណ៍ហិរញ្ញវត្ថុ ដែលអាចបណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គងផ្សេងៗ ដោយតាក់តែងនីតិវិធីសវនកម្ម និងធ្វើសវនកម្មដើម្បីឆ្លើយតបទៅនឹងហានិភ័យទាំងនោះ និងស្វែងរកភ័ស្តុតាងសវនកម្មគ្រប់គ្រាន់និងសមស្រប ដើម្បីធ្វើជាមូលដ្ឋានសម្រាប់ការបញ្ចេញមតិយោបល់របស់យើងខ្ញុំ។ ហានិភ័យដែលបណ្តាលមកពីការរកមិនឃើញកំហុសឆ្គងជាសារវន្តពីការក្លែងបន្លំ វាមានទំហំធំជាងហានិភ័យដែលបណ្តាលមកពីកំហុសឆ្គងអចេតនា ដោយសារការក្លែងបន្លំរួមមាន ការសមគំនិត ការក្លែងបន្លំឯកសារ ការលុបបំបាត់ដោយចេតនា ការបង្ហាញខុស ឬការរំលងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង។

- ស្វែងយល់អំពីប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងដែលពាក់ព័ន្ធទៅនឹងសវនកម្ម ដើម្បីតាក់តែងនីតិវិធីសវនកម្មដែលសមស្រប ទៅតាមកាលៈទេសៈ ប៉ុន្តែមិនបញ្ចេញមតិយោបល់របស់យើងខ្ញុំ ទៅលើប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង របស់ធនាគារទេ។
- វាយតម្លៃអំពីភាពសមស្របនៃគោលការណ៍គណនេយ្យដែលបានប្រើប្រាស់ ភាពសមហេតុផលនៃការប៉ាន់ស្មាន គណនេយ្យ និងការលាតត្រដាងពាក់ព័ន្ធ ដែលគណៈគ្រប់គ្រងបានធ្វើឡើង។
- សន្និដ្ឋានលើភាពសមស្រប នៃការប្រើប្រាស់មូលដ្ឋានគណនេយ្យនិរន្តរភាពអាជីវកម្មរបស់គណៈគ្រប់គ្រងអាស្រ័យ ទៅលើភ័ស្តុតាងសវនកម្មដែលយើងខ្ញុំទទួលបាន ថាតើវាមានភាពមិនច្បាស់លាស់ជាសារវន្តដែលបានកើតឡើង កម្រិតណា ពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍ ឬលក្ខខណ្ឌនានា ដែលអាចបណ្តាលឱ្យមានការសង្ស័យជាដុំកំភួនទៅលើ លទ្ធភាពរបស់ធនាគារ ក្នុងការបន្តនិរន្តរភាពអាជីវកម្មរបស់ខ្លួនដែរឬទេ។ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថា វាមាន ភាពមិនច្បាស់លាស់ជាសារវន្តបានកើតឡើង នោះយើងខ្ញុំត្រូវធ្វើការបង្ហាញនៅក្នុងរបាយការណ៍សវនករ ដើម្បី ទាញចំណាប់អារម្មណ៍អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុ ចំពោះការលាតត្រដាងព័ត៌មាននៅក្នុងរបាយការណ៍ ហិរញ្ញវត្ថុ ឬប្រសិនបើការលាតត្រដាងនោះនៅមិនទាន់គ្រប់គ្រាន់ទៀត យើងខ្ញុំត្រូវធ្វើការកែប្រែមតិយោបល់ របស់យើងខ្ញុំ។ សេចក្តីសន្និដ្ឋានសរុបរបស់យើងខ្ញុំ អាស្រ័យទៅលើភ័ស្តុតាងសវនកម្មដែលយើងខ្ញុំទទួលបាន រហូតដល់ថ្ងៃចុះហត្ថលេខាលើរបាយការណ៍សវនករនេះ។ ទោះជាយ៉ាងណាក៏ដោយ ព្រឹត្តិការណ៍ ឬលក្ខខណ្ឌ នានាក្នុងពេលអនាគត អាចបណ្តាលឱ្យធនាគារឈប់បន្តនិរន្តរភាពអាជីវកម្ម។
- វាយតម្លៃការបង្ហាញទូទៅ រចនាសម្ព័ន្ធ និងខ្លឹមសារក្នុងរបាយការណ៍ហិរញ្ញវត្ថុ រួមទាំងការលាតត្រដាងព័ត៌មាន ផ្សេងៗ និងកំណត់ថារបាយការណ៍ហិរញ្ញវត្ថុបានបង្ហាញពីប្រតិបត្តិការ និងព្រឹត្តិការណ៍ជាក់ស្តែង ដែលអាចធ្វើ ឱ្យមានការបង្ហាញត្រឹមត្រូវ។

យើងខ្ញុំបានរាយការណ៍ជូនអ្នកដែលទទួលបន្ទុកអភិបាលកិច្ចនូវបញ្ហាផ្សេងៗដូចជា ទំហំការងារតាមផែនការ និង ពេលវេលាសវនកម្ម ព្រមទាំងបញ្ហាសវនកម្មសំខាន់ៗ រួមទាំងរាយការណ៍ពីភាពខ្វះខាតជាសារវន្តក្នុងការគ្រប់គ្រង ផ្ទៃក្នុង ដែលយើងខ្ញុំបានរកឃើញក្នុងការធ្វើសវនកម្មរបស់យើងខ្ញុំ។

**ផ. ក្រុមហ៊ុន ប្រាយវ៉តធ័រហោវខូភើស៍ (ខេមបូឌា)**



**ឡាង ហ៊ី**
**Partner**

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៥



## ១៣.៣ របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

### គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤

| | | ២០២៤ | | ២០២៣ | |
|---|---|---|---|---|---|
| | កំណត់ សម្គាល់ | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **ទ្រព្យសកម្ម** | | | | | |
| សាច់ប្រាក់ក្នុងដៃ | ៤ | ១៦.៧៩៦.៥០៧ | ៦៧.៦០៥.៩៤១ | ១៤.៨៨៤.៣៩៥ | ៦០.៨០២.៧៥៤ |
| ប្រាក់បញ្ញើ និងការដាក់ប្រាក់នៅធនាគារកណ្តាល | ៥ | ១៤៦.២៤៧.២៩០ | ៥៨៨.៦៤៥.៣៤២ | ៥២.៧៨៥.៩៥៦ | ២១៥.៦៣០.៦៣០ |
| ប្រាក់បញ្ញើ និងការដាក់ប្រាក់នៅធនាគារផ្សេងៗ | ៦ | ២៤.៦៥២.៣៧០ | ៩៩.២២៥.៧៨៩ | ៣៦.៦៥៥.១៦៧ | ១៤៩.៧៣៦.៣៥៧ |
| ឥណទាន និងបុរេប្រទានវាស់វែងតាមថ្លៃដើមដករំលស់ | ៧ | ៨១០.១១៤.៣៣៩ | ៣.២៦០.៧១០.២១៤ | ៧១២.៧៤៦.១៨២ | ២.៩១១.៥៦៨.១៥៣ |
| ប្រាក់តម្កល់តាមច្បាប់នៅធនាគារកណ្តាល | ៨ | ៦០.២៦៣.០៨១ | ២៤២.៥៥៨.៩០១ | ៥៥.៤២៥.១៨៩ | ២២៦.៤១១.៨៩៧ |
| ទ្រព្យសកម្មដែលមានសិទ្ធិប្រើប្រាស់ | ៩ | ៩.៣០១.១៥៧ | ៣៧.៤៣៧.១៥៧ | ១០.២០៩.៨៦០ | ៤១.៧០៧.២៧៨ |
| ទ្រព្យសម្បត្តិ និងបរិក្ខារ | ១០ | ៧.៥១២.៤៣០ | ៣០.២៣៧.៥៣១ | ៨.៨៦៦.១៥៦ | ៣៦.២១៨.២៤៧ |
| ទ្រព្យសកម្មអរូបី | ១១ | ៧.៣៩៥.០៨២ | ២៩.៧៦៥.២០៥ | ៦.៩០៤.៨២៥ | ២៨.២០៦.២១០ |
| ទ្រព្យសកម្មផ្សេងៗ | ១៣ | ៨.៥៥៣.០០៣ | ៣៤.៤២៥.៨៣៧ | ៥.៣៩៣.៣៧៩ | ២២.០៣១.៩៥៣ |
| **ទ្រព្យសកម្មសរុប** | | **១.០៩០.៨៣៥.២៥៩** | **៤.៣៩០.៦១១.៩១៧** | **៩០៣.៨៧១.១០៩** | **៣.៦៩២.៣១៣.៤៧៩** |
| **បំណុល និងមូលធន** | | | | | |
| **បំណុល** | | | | | |
| ប្រាក់បញ្ញើរបស់អតិថិជន | ១៤ | ៦៤៧.៨៦៣.៩៥៦ | ២.៦០៧.៦៥២.៤២៣ | ៥៤៧.៤៥១.២១៧ | ២.២៣៦.៣៣៨.២២១ |
| ប្រាក់បញ្ញើរបស់គ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ | ១៥ | ១៧៩.៨៦៧.៥៤៣ | ៧២៣.៩៦៦.៨៦១ | ១១៧.៩៩៣.៧៥៧ | ៤៨២.០០៤.៤៩៧ |
| ប្រាក់កម្ចី | ១៧ | ៧៧.០៩៦.៥៨៣ | ៣១០.៣១៣.៧៤៧ | ៥៥.៧៦៧.៦៩១ | ២២៧.៨១១.០១៨ |
| បំណុលបន្ទាប់បន្សំ | ១៨ | ៤៦.៣២៩.០០៨ | ១៨៦.៤៧៤.២៥៧ | ៤៧.៩០១.៣៥៨ | ១៩៥.៦៧៧.០៤៧ |
| បំណុលភតិសន្យា | ៩ | ៩.៩៧៩.៧២១ | ៤០.១៦៨.៣៧៧ | ១០.៨៣០.៩៤១ | ៤៤.២៤៤.៣៩៤ |
| សំវិធានធនសម្រាប់អត្ថប្រយោជន៍បុគ្គលិក | ១៩ | ៦៥.៩៤៣ | ២៦៥.៤២១ | ៧៧.៩៣១ | ៣១៨.៣៤៨ |
| បំណុលពន្ធលើប្រាក់ចំណូលក្នុងគ្រា | ៣១(a) | ៩១.៣០៧ | ៣៦៧.៥១១ | ១៦៧.៤១៥ | ៦៨៣.៨៩០ |
| ពន្ធពន្យារជាបំណុល | ១២ | ១.៨៤៣.៩៧៥ | ៧.៤២១.៩៩៩ | ៥៥៩.៨០៣ | ២.២៨៦.៧៩៥ |
| បំណុលផ្សេងៗ | ២០ | ៤.៣៤៦.០៩៦ | ១៧.៤៩៣.០៣៦ | ៧.៣៨១.០៥១ | ៣០.១៥១.៥៩៣ |
| **បំណុលសរុប** | | **៩៦៧.៤៨៤.១៣២** | **៣.៨៩៤.១២៣.៦៣២** | **៧៨៨.១៣១.១៦៤** | **៣.២១៩.៥១៥.៨០៣** |
| **មូលធន** | | | | | |
| ដើមទុន | ២១ | ១០០.០០០.០០០ | ៤០៥.៨០៣.៩៣៥ | ១០០.០០០.០០០ | ៤០៥.៨០៣.៩៣៥ |
| ទុនបម្រុងកាតព្វកិច្ច | ២២ | ១.០២៦.៥៨២ | ៤.១៨៧.៦៥៧ | ៦៤៦.០២៣ | ២.៦៣៨.៤០១ |
| ទុនបម្រុងតាមបទប្បញ្ញត្តិ | ២៣ | ២១.២៨២.២៩២ | ៨៦.៧៧០.៨០៥ | ១១.៥៥០.៣២៣ | ៤៧.១៥១.៩៥៩ |
| ប្រាក់ចំណេញរក្សាទុក | | ១.០៨២.២៥៣ | ៤.២៣៥.៥២២ | ៣.៥៤៣.៥៩៩ | ១៤.៤១៨.៤៩១ |
| ទុនបម្រុងផ្សេងៗ | | - | (៤.៥០៩.៦៣៤) | - | ២.៧៨៤.៨៩០ |
| **មូលធនសរុប** | | **១២៣.៣៥១.១២៧** | **៤៩៦.៤៨៨.២៨៥** | **១១៥.៧៣៩.៩៤៥** | **៤៧២.៧៩៧.៦៧៦** |
| **បំណុល និងមូលធនសរុប** | | **១.០៩០.៨៣៥.២៥៩** | **៤.៣៩០.៦១១.៩១៧** | **៩០៣.៨៧១.១០៩** | **៣.៦៩២.៣១៣.៤៧៩** |

នេះគឺជារបាយការណ៍ដែលបានស្រង់ចេញ ហើយរបាយការណ៍នេះគួរតែត្រូវបានអានដោយភ្ជាប់ជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុពេញលេញដែលបានធ្វើសវនកម្ម។



## ១៣.៤ របាយការណ៍ចំណេញ-ខាត និងលទ្ធផលលម្អិតផ្សេងៗ

### សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤

| | | ២០២៤ | | ២០២៣ | |
|---|---|---|---|---|---|
| | កំណត់ សម្គាល់ | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ចំណូលការប្រាក់ | ២៤ | ១០១.៤៦៧.៦៤៦ | ៤១៣.០៧៤.៧៨៧ | ៨១.៤៣១.៧០៩ | ៣៣៤.៦៨៤.៣២៤ |
| ចំណាយការប្រាក់ | ២៤ | (៥៨.៦៣៩.៦៩៨) | (២៣៨.៧២២.២១១) | (៤៦.២៦៩.៨៥៤) | (១៩០.១៦៩.១០០) |
| **ចំណូលការប្រាក់សុទ្ធ** | **២៤** | **៤២.៨២៧.៩៤៨** | **១៧៤.៣៥២.៥៧៦** | **៣៥.១៦១.៨៥៥** | **១៤៤.៥១៥.២២៤** |
| ចំណូលកម្រៃជើងសា | ២៥ | ១.៧៤៤.៨៨៩ | ៧.១០៣.៤៤៣ | ៦៩០.៨៩៨ | ២.៨៣៩.៥៩១ |
| ចំណាយកម្រៃជើងសា | ២៥ | (១.១៤៩.៤៤៩) | (៤.៦៧៩.៤០៧) | (១.០៧៩.៧៣៣) | (៤.៤៣៧.៧០៣) |
| **ចំណូល/(ចំណាយ)កម្រៃជើងសាសុទ្ធ** | **២៥** | **៥៩៥.៤៤០** | **២.៤២៤.០៣៦** | **(៣៨៨.៨៣៥)** | **(១.៥៩៨.១១២)** |
| ចំណូលផ្សេងៗ | ២៦ | ១.០៩៤.៣៩៧ | ៤.៤៥៥.២៩០ | ១.០៤០.៣០៩ | ៤.២៧៥.៦៧០ |
| ខាតពីការថយចុះតម្លៃឥណទាន | ២៧ | (៥.២២៤.៨៥៥) | (២១.២៧០.៣៨៥) | (២.៦៦៧.៤៧៤) | (១០.៩៦៣.៣១៨) |
| ចំណេញផ្សេងៗ - សុទ្ធ | | ៨៦៧.៧៧១ | ៣.៥៣២.៧០៨ | ៤១៨.៤៨០ | ១.៧១៩.៩៥៣ |
| **ខាតប្រតិបត្តិការផ្សេងៗសុទ្ធ** | | **(៣.២៦២.៦៨៧)** | **(១៣.២៨២.៣៨៧)** | **(១.២០៨.៦៨៥)** | **(៤.៩៦៧.៦៩៥)** |
| **ចំណាយ** | | | | | |
| ចំណាយបុគ្គលិក | ២៨ | (១៨.៤៧៧.០៦៨) | (៧៥.២២០.១៤៤) | (១៧.៤៥១.៧៣៩) | (៧១.៧២៦.៦៤៧) |
| ចំណាយរំលស់ | ២៩ | (៥.៥២៦.៤៥២) | (២២.៤៩៨.១៨៦) | (៥.១០៤.៥៥០) | (២០.៩៧៩.៧០១) |
| ចំណាយប្រតិបត្តិការផ្សេងៗ | ៣០ | (៦.៥៨២.០៨៨) | (២៦.៧៩៥.៦៨០) | (៦.០៩១.៨៨១) | (២៥.០៣៧.៦៣១) |
| | | **(៣០.៥៨៥.៦០៨)** | **(១២៤.៥១៤.០១០)** | **(២៨.៦៤៨.១៧០)** | **(១១៧.៧៤៣.៩៧៩)** |
| **ចំណេញមុនពន្ធលើប្រាក់ចំណូល** | | **៩.៥៧៥.០៩៣** | **៣៨.៩៨០.២១៥** | **៤.៩១៦.១៦៥** | **២០.២០៥.៤៣៨** |
| ចំណាយពន្ធលើប្រាក់ចំណូល | ៣១(ខ) | (១.៩៦៣.៩១១) | (៧.៩៩៥.០៨២) | (១.៥៣០.៥៥៤) | (៦.២៩០.៥៧៧) |
| **ចំណេញក្នុងឆ្នាំ** | | **៧.៦១១.១៨២** | **៣០.៩៨៥.១៣៣** | **៣.៣៨៥.៦១១** | **១៣.៩១៤.៨៦១** |
| **ចំណូលលម្អិតផ្សេងៗ៖** | | | | | |
| *ខ្ទង់ដែលមិនត្រូវបានចាត់ថ្នាក់ឡើងវិញក្នុងចំណេញ-ខាត* | | | | | |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | (៧.២៩៤.៥២៤) | - | (៣.៥០៤.៩៧៨) |
| **ខាតលម្អិតផ្សេងៗក្នុងឆ្នាំ កាត់កងពន្ធ** | | - | **(៧.២៩៤.៥២៤)** | - | **(៣.៥០៤.៩៧៨)** |
| **ចំណូលលម្អិតសរុបក្នុងឆ្នាំ** | | **៧.៦១១.១៨២** | **២៣.៦៩០.៦០៩** | **៣.៣៨៥.៦១១** | **១០.៤០៩.៨៨៣** |
| **ចំណេញរបស់៖** | | | | | |
| ម្ចាស់ធនាគារ | | ៧.៦១១.១៨២ | ៣០.៩៨៥.១៣៣ | ៣.៣៨៥.៦១១ | ១៣.៩១៤.៨៦១ |
| **ចំណូលលម្អិតសរុបរបស់៖** | | | | | |
| **ម្ចាស់ធនាគារ** | | **៧.៦១១.១៨២** | **២៣.៦៩០.៦០៩** | **៣.៣៨៥.៦១១** | **១០.៤០៩.៨៨៣** |

នេះគឺជារបាយការណ៍ដែលបានស្រង់ចេញ ហើយរបាយការណ៍នេះគួរតែត្រូវបានអានដោយភ្ជាប់ជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុពេញលេញដែលបានធ្វើសវនកម្ម។

# ១៣.៥ របាយការណ៍បម្រែបម្រួលមូលធន

## សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤

| | ជារបស់ម្ចាស់ធនាគារ | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ដើមទុន | | ទុនបម្រុងកាតព្វកិច្ច | | ទុនបម្រុងតាមបទប្បញ្ញត្តិ | | ចំណេញរក្សាទុក | | ទុនបម្រុងផ្សេងៗ | | សរុប | |
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **សមតុល្យនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០២៣** | ៧៥.០០០.០០០ | ៣០៣.០៥៣.៩៣៥ | ៤៧៦.៧៤៣ | ១.៩៤២.៦៦០ | ៩.១១០.៧៦៣ | ៣៧.១២៥.៣៦៧ | ២.៧៦៦.៨២៨ | ១១.២២៥.៩៦៣ | - | ៦.២៨៩.៨៦៨ | ៨៧.៣៥៤.៣៣៤ | ៣៥៩.៦៣៧.៧៩៣ |
| ចំណេញក្នុងឆ្នាំ | - | - | - | - | - | - | ៣.៣៨៥.៦១១ | ១៣.៩១៤.៨៦១ | - | - | ៣.៣៨៥.៦១១ | ១៣.៩១៤.៨៦១ |
| ខាតលម្អិតផ្សេងៗ - លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | - | - | - | - | (៣.៥០៤.៩៧៨) | - | (៣.៥០៤.៩៧៨) |
| **ចំណេញលម្អិតសរុបក្នុងឆ្នាំ** | - | - | - | - | - | - | ៣.៣៨៥.៦១១ | ១៣.៩១៤.៨៦១ | - | (៣.៥០៤.៩៧៨) | ៣.៣៨៥.៦១១ | ១០.៤០៩.៨៨៣ |
| **ប្រតិបត្តិការដែលបានទទួលស្គាល់ដោយផ្ទាល់** | | | | | | | | | | | | |
| **នៅក្នុងមូលធនៈ** | | | | | | | | | | | | |
| បន្ថែមដើមទុនបានបង់ (កំណត់សម្គាល់២១) | ២៥.០០០.០០០ | ១០២.៧៥០.០០០ | - | - | - | - | - | - | - | - | ២៥.០០០.០០០ | ១០២.៧៥០.០០០ |
| ផ្ទេរទៅទុនបម្រុងកាតព្វកិច្ច (កំណត់សម្គាល់២២) | - | - | ១៦៩.២៨០ | ៦៩៥.៧៤១ | - | - | (១៦៩.២៨០) | (៦៩៥.៧៤១) | - | - | - | - |
| ផ្ទេរទៅទុនបម្រុងតាមបទប្បញ្ញត្តិ (កំណត់សម្គាល់២៣) | - | - | - | - | ២.៤៣៩.៥៦០ | ១០.០២៦.៥៩២ | (២.៤៣៩.៥៦០) | (១០.០២៦.៥៩២) | - | - | - | - |
| | **២៥.០០០.០០០** | **១០២.៧៥០.០០០** | **១៦៩.២៨០** | **៦៩៥.៧៤១** | **២.៤៣៩.៥៦០** | **១០.០២៦.៥៩២** | **(២.៦០៨.៨៤០)** | **(១០.៧២២.៣៣៣)** | - | - | **២៥.០០០.០០០** | **១០២.៧៥០.០០០** |
| **សមតុល្យនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣** | **១០០.០០០.០០០** | **៤០៥.៨០៣.៩៣៥** | **៦៤៦.០២៣** | **២.៦៣៨.៤០១** | **១១.៥៥០.៣២៣** | **៤៧.១៥១.៩៥៩** | **៣.៥៤៣.៥៩៩** | **១៤.៤១៨.៤៩១** | - | **២.៧៨៤.៨៩០** | **១១៥.៧៣៩.៦៤៥** | **៤៧២.៧៩៧.៦៧៦** |
| **សមតុល្យនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០២៤** | ១០០.០០០.០០០ | ៤០៥.៨០៣.៩៣៥ | ៦៤៦.០២៣ | ២.៦៣៨.៤០១ | ១១.៥៥០.៣២៣ | ៤៧.១៥១.៩៥៩ | ៣.៥៤៣.៥៩៩ | ១៤.៤១៨.៤៩១ | - | ២.៧៨៤.៨៩០ | ១១៥.៧៣៩.៦៤៥ | ៤៧២.៧៩៧.៦៧៦ |
| ចំណេញក្នុងឆ្នាំ | - | - | - | - | - | - | ៧.៦១១.១៨២ | ៣០.៩៨៥.១៣៣ | - | - | ៧.៦១១.១៨២ | ៣០.៩៨៥.១៣៣ |
| ខាតលម្អិតផ្សេងៗ - លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | - | - | - | | (៧.២៩៤.៥២៤) | - | (៧.២៩៤.៥២៤) |
| **ចំណេញលម្អិតសរុបក្នុងឆ្នាំ** | - | - | - | - | - | - | ៧.៦១១.១៨២ | ៣០.៩៨៥.១៣៣ | - | (៧.២៩៤.៥២៤) | ៧.៦១១.១៨២ | ២៣.៦៩០.៦០៩ |
| **ប្រតិបត្តិការដែលបានទទួលស្គាល់ដោយផ្ទាល់** | | | | | | | | | - | | | |
| **នៅក្នុងមូលធនៈ** | | | | | | | | | - | | | |
| ផ្ទេរទៅទុនបម្រុងកាតព្វកិច្ច (កំណត់សម្គាល់២២) | - | - | ៣៨០.៥៥៩ | ១.៥៤៩.២៥៦ | - | - | (៣៨០.៥៥៩) | (១.៥៤៩.២៥៦) | - | - | - | - |
| ផ្ទេរទៅទុនបម្រុងតាមបទប្បញ្ញត្តិ (កំណត់សម្គាល់២៣) | - | - | - | - | ៩.៧៣១.៩៦៩ | ៣៩.៦១៨.៨៤៦ | (៩.៧៣១.៩៦៩) | (៣៩.៦១៨.៨៤៦) | - | - | - | - |
| | - | - | **៣៨០.៥៥៩** | **១.៥៤៩.២៥៦** | **៩.៧៣១.៩៦៩** | **៣៩.៦១៨.៨៤៦** | **(១០.១១២.៥២៨)** | **(៤១.១៦៨.១០២)** | - | - | - | - |
| **សមតុល្យនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤** | **១០០.០០០.០០០** | **៤០៥.៨០៣.៩៣៥** | **១.០២៦.៥៨២** | **៤.១៨៧.៦៥៧** | **២១.២៨២.២៩២** | **៨៦.៧៧០.៨០៥** | **១.០៤២.២៥៣** | **៤.២៣៥.៥២២** | - | **(៤.៥០៩.៦៣៤)** | **១២៣.៣៥០.៨២៧** | **៤៩៦.៤៨៨.២៨៥** |

នេះគឺជារបាយការណ៍ដែលបានស្រង់ចេញ ហើយរបាយការណ៍នេះគួរតែត្រូវបានអានដោយភ្ជាប់ជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុពេញលេញដែលបានធ្វើសវនកម្ម។

# ១៣.៦ របាយការណ៍លំហូរសាច់ប្រាក់

## សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤

| | | ២០២៤ | | ២០២៣ | |
|---|---|---|---|---|---|
| | កំណត់សម្គាល់ | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | | | |
| សាច់ប្រាក់បានពី/(ប្រើក្នុង)ប្រតិបត្តិការ | ៣៣ | ២៥.៤៦៦.៦០៤ | ១០៣.៦៧៤.៥៥៤ | (២៧.១៨៤.០០៨) | (១១១.៧២៦.២៧៨) |
| ការប្រាក់បានទទួល | | ៩៩.៨៤៦.៣៧៨ | ៤០៦.៤៧៤.៦០៥ | ៧៩.៨៤៩.០៦៦ | ៣២៨.១៧៩.៦៦១ |
| ការប្រាក់បានបង់ | | (៥៥.៣៣១.៣៥១) | (២២៥.២៥៣.៩៣០) | (៤១.៨០៨.០៤៣) | (១៧១.៨៣១.០៥៧) |
| ពន្ធលើប្រាក់ចំណូលបានបង់ | ៣១ | (៧៥៥.៨៤៧) | (៣.០៧៧.០៥៣) | (១.៤០៥.៣១៣) | (៥.៧៧៥.៨៣៦) |
| ប្រាក់បំណាច់អតីតភាពការងារបានបង់ | ១៩ | (៨៤៩.៧៦៥) | (៣.៤៥៩.៣៩៣) | (៩១២.៩៨៧) | (៣.៧៥២.៣៧៧) |
| សាច់ប្រាក់សុទ្ធបានពីសកម្មភាពប្រតិបត្តិការ | | ៦៨.៣៧៦.០១៩ | ២៧៨.៣៥៨.៧៨៣ | ៨.៥៣៨.៧១៥ | ៣៥.០៩៤.១១៧ |
| **លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ** | | | | | |
| ប្រាក់បញ្ញើ និងការដាក់ប្រាក់នៅធនាគារ-កាលកំណត់លើសបីខែ | | - | - | ៥.០០០.០០០ | ២០.៥៥០.០០០ |
| មូលបត្រអាចជួញដូរបាន | | ៧៧៣.០០០ | ៣.១៤៦.៨៨៣ | (៦.៦៨១.៣៩៤) | (២៧.៤៦០.៥២៩) |
| ប្រាក់តម្កល់ធានាលើដើមទុន | | - | - | (២.៥០០.០០០) | (១០.២៧៥.០០០) |
| ការទិញទ្រព្យសម្បត្តិ និងបរិក្ខារ | ១០ | (១.៣៧៤.៦៧២) | (៥.៥៩៦.២៩០) | (១.០២៣.៣២២) | (៤.២០៥.៨៥៣) |
| ការទិញទ្រព្យសកម្មអរូបី | ១១ | (១.២០៩.៤៨០) | (៤.៩២៣.៧៩៣) | (២.៣៥២.៤៩៨) | (៩.៦៦៨.៧៦៧) |
| សាច់ប្រាក់បានពីការលក់ទ្រព្យសម្បត្តិ និងបរិក្ខារ | | ១៣.៥៤៣ | ៥៥.១៣៤ | ២.៤៧២ | ១០.១៦០ |
| សាច់ប្រាក់សុទ្ធប្រើក្នុងសកម្មភាពវិនិយោគ | | (១.៧៩៧.៦០៩) | (៧.៣១៨.០៦៦) | (៧.៥៥៤.៧៤២) | (៣១.០៤៩.៩៨៩) |
| **លំហូរសាច់ប្រាក់ពីសកម្មភាពហិរញ្ញប្បទាន** | | | | | |
| សាច់ប្រាក់បានពីការបោះផ្សាយភាគហ៊ុន | ២១ | - | - | ២៥.០០០.០០០ | ១០២.៧៥០.០០០ |
| ការទូទាត់សងការបោះផ្សាយមូលបត្របំណុល | ១៦ | - | - | (១៥.០០០.០០០) | (៦១.៦៥០.០០០) |
| សាច់ប្រាក់បានពីប្រាក់កម្ចី | ១៧ | ៤១.១១៨.០១២ | ១៦៧.៣៩១.៤២៧ | ៥៩.៩៨៦.៤២៣ | ២៤៦.៥៤៤.១៩៩ |
| ការទូទាត់សងប្រាក់កម្ចី | ១៧ | (១៩.៨៤១.៥២៥) | (៨០.៧៧៤.៨៤៨) | (៣៨.៨០៤.១៣៧) | (១៥៩.៤៨៥.០០៣) |
| សាច់ប្រាក់បានពីបំណុលបន្ទាប់បន្សំ | ១៨ | ១១.០០០.០០០ | ៤៤.៧៨១.០០០ | ២០.០០០.០០០ | ៨២.២០០.០០០ |
| ការទូទាត់សងបំណុលបន្ទាប់បន្សំ | ១៨ | (១២.៦៣១.៧៨៦) | (៥១.៤២៤.០០១) | (៨.៦១៣.១៣៩) | (៣៥.៤០០.០០១) |
| ការទូទាត់ភតិសន្យាជាប្រាក់ដើម | | (២.០៨២.៩២១) | (៨.៤៧៩.៥៧១) | (១.៧៩២.៥៤៩) | (៧.៣៦៧.៣៧៦) |
| សាច់ប្រាក់សុទ្ធបានពីសកម្មភាពហិរញ្ញប្បទាន | | ១៧.៥៦១.៧៨០ | ៧១.៤៩៤.០០៧ | ៤០.៧៧៦.៥៩៨ | ១៦៧.៥៩១.៨១៩ |
| **កំណើនសាច់ប្រាក់ និងសាច់ប្រាក់សមមូលសុទ្ធ** | | ៨៤.១៤០.១៩០ | ៣៤២.៥៣៤.៧២៤ | ៤១.៧៦០.៥៧១ | ១៧១.៦៣៥.៩៤៧ |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាដើមឆ្នាំ | | ៩៣.៧៣៦.៦០៤ | ៣៨២.៩១៤.០២៧ | ៥១.៩៧៦.០៣៣ | ២១៣.៩៨៥.៣២៨ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | (៩.៤៩៤.៦៥៦) | - | (២.៧០៧.២៤៨) |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាដំណាច់ឆ្នាំ** | ៣២ | **១៧៧.៨៧៦.៧៩៤** | **៧១៥.៩៥៤.០៩៥** | **៩៣.៧៣៦.៦០៤** | **៣៨២.៩១៤.០២៧** |

នេះគឺជារបាយការណ៍ដែលបានស្រង់ចេញ ហើយរបាយការណ៍នេះគួរតែត្រូវបានអានដោយភ្ជាប់ជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុពេញលេញដែលបានធ្វើសវនកម្ម។





# ១៤. បណ្តាញការិយាល័យសាខា






# ១៤.១ បណ្តាញសាខា

## រាជធានីភ្នំពេញ

### សាខា ៧មករា
អគារលេខ២១២៩ ផ្លូវ១២៨ កែង១៦៩
សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ
📞 098 688 955

### សាខា ទួលគោក
អគារ៨៥-៨៨ មហាវិថីគីមអ៊ីលស៊ុង (២៨៩)
សង្កាត់បឹងកក់ទី ២ ខណ្ឌទួលគោក
📞 015 435 999

### សាខា ចំការមន
អគារលេខ១១៨ ផ្លូវព្រះនរោត្តម
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
📞 015 885 124

### សាខា ខណ្ឌច្បារអំពៅ (២)
ផ្ទះលេខ២៥ ក្បាលដីលេខ ភព ១២៥៧៣ ផ្លូវជាតិលេខ១ ភូមិដើមអំពិល សង្កាត់ច្បារអំពៅទី១ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ
📞 015 885 172

### សាខា ពោធិ៍សែនជ័យ
ក្បាលដីលេខ ១០៣ និង ១០៤ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិប៉ប្រកខាងជើង សង្កាត់កាកាបទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ
📞 016 480 472

### សាខា ឫស្សីកែវ
បុរីមានភ្នំពេញ ផ្ទះលេខ៧២ដាប់បលយូ មហាវិថីអង្គរ
សង្កាត់ច្រាំងចំរេះទី១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ
📞 092 639 358

### សាខា ជ្រោយចង្វារ
ផ្ទះលេខអេហ្វ០៦ & អេហ្វ០៧ ផ្លូវជាតិលេខ៦អា
សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ
📞 016 888 751

### សាខា ច្បារអំពៅ
ផ្ទះលេខ២៥ ផ្លូវជាតិលេខ១ ភូមិព្រែកធំ២ សង្កាត់ក្បាលកោះ
ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ
📞 015 885 646

## ខេត្តកណ្តាល

### សាខា ស្រុកអង្គស្នួល
ផ្ទះលេខ១៨អា១ ភូមិស្វាយជ្រុំ ឃុំបែកចាន
ស្រុកអង្គស្នួល ខេត្តកណ្តាល
📞 016 885 726

### សាខា ស្រុកមុខកំពូល
ផ្ទះលេខ១៣១អេ ផ្លូវជាតិលេខ៦អា ភូមិក្រោម ឃុំព្រែកអញ្ចាញ
ស្រុកមុខកំពូល ខេត្តកណ្តាល
📞 081 777 306

## ខេត្តកំពង់ចាម

### សាខា ខេត្តកំពង់ចាម
ផ្លូវជាតិលេខ៧ ភូមិទី៦ សង្កាត់វាលវង់ ក្រុងកំពង់ចាម
ខេត្តកំពង់ចាម
📞 016 888 419

### សាខា ស្រុកជើងព្រៃ
ផ្លូវជាតិលេខ៦ ភូមិតាសែន ឃុំសូទិព្វ
ស្រុកជើងព្រៃ ខេត្តកំពង់ចាម
📞 016 888 692

### សាខា ស្រុកបាធាយ
ភូមិផ្អាវ ឃុំផ្អាវ ស្រុកបាធាយ
ខេត្តកំពង់ចាម
📞 081 2555 554



## ខេត្តព្រៃវែង

### សាខា ស្រុកកំពង់ត្របែក
ផ្លូវជាតិលេខ១១ ភូមិស្វាយអន្ទរទី១ ឃុំស្វាយអន្ទរ
ស្រុកស្វាយអន្ទរ ខេត្តព្រៃវែង
📞 016 888 519

### សាខា ស្រុកស្វាយអន្ទរ
ភូមិស្វាយអន្ទរទី១ ឃុំស្វាយអន្ទរ
ស្រុកស្វាយអន្ទរ ខេត្តព្រៃវែង
📞 081 799 995

### សាខា ស្រុកពារាំង
ផ្លូវជាតិលេខ៨ ភូមិស្វាយពល ឃុំរកា
ស្រុកពារាំង ខេត្តព្រៃវែង
📞 085 601 000

### សាខា ស្រុកព្រះស្តេច
ភូមិលិង្គ ឃុំអង្គររាជ្យ ស្រុកព្រះស្តេច
ខេត្តព្រៃវែង
📞 016 888 403

## ខេត្តតាកែវ

### សាខា ក្រុងដូនកែវ
ផ្លូវជាតិលេខ២ ភូមិផ្សារតាកោ សង្កាត់រកាក្នុង
ក្រុងដូនកែវ ខេត្តតាកែវ
📞 087 288 881

### សាខា ស្រុកបាទី
ផ្លូវលេខជាតិ២ ភូមិបចាម ឃុំចំបក់ ស្រុកបាទី
ខេត្តតាកែវ
📞 016 999 749

### សាខា ស្រុកគិរីវង់
ផ្លូវជាតិលេខ២ ភូមិកំពង់ថ្មី ឃុំព្រះបាទជាន់ជុំ
ស្រុកគិរីវង់ ខេត្តតាកែវ
📞 015 885 347

### សាខា ស្រុកព្រៃកប្បាស
ភូមិផ្សារជ្រៃ ឃុំអង្កាញ់ ស្រុកព្រៃកប្បាស
ខេត្តតាកែវ
📞 016 888 410

### សាខា ស្រុកត្រាំកក់
ផ្លូវជាតិលេខ៣ ភូមិយាយឡ ឃុំត្រាំកក់
ស្រុកត្រាំកក់ ខេត្តតាកែវ
📞 016 888 160

### សាខា ស្រុកកោះអណ្តែត
ផ្លូវលេខ១២៩ឌី ភូមិរមេញខាងជើង ឃុំរមេញ ស្រុកកោះ អណ្តែត
ខេត្តតាកែវ
📞 **016 888 391**

## ខេត្តកំពង់ស្ពឺ

### សាខា ខេត្តកំពង់ស្ពឺ
ផ្លូវជាតិលេខ៤ ភូមិក្រាំងពលទេព សង្កាត់រកាធំ
ក្រុងច្បារមន ខេត្តកំពង់ស្ពឺ
📞 016 888 239

### សាខា ស្រុកបរសេដ្ឋ
ផ្លូវជាតិលេខ៤១ ភូមិព្រះម្លប់ ឃុំភារីមានជ័យ
ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ
📞 015 885 362

### សាខា ស្រុកគងពិសី
ផ្លូវជាតិលេខ៣ ភូមិលៀក ឃុំព្រះនិព្វាន
ស្រុកគងពិសី ខេត្តកំពង់ស្ពឺ
📞 016 888 297

### សាខា ស្រុកសំរោងទង
ផ្លូវជាតិលេខ៤ ភូមិត្រពាំងអំពិល ឃុំត្រពាំងគង
ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ
📞 016 888 227

## ខេត្តកំពត

### សាខា ស្រុកកំពង់ត្រាច
ផ្លូវជាតិលេខ៣១ ភូមិកំពង់ត្រាចទី១ ឃុំកំពង់ត្រាចខាងកើត
ស្រុកកំពង់ត្រាច ខេត្តកំពត
📞 016 888 420

## ខេត្តព្រះសីហនុ

### សាខា ស្រុកព្រៃនប់
ភូមិសំរុងកណ្តាល ឃុំសំរុង ស្រុកព្រៃនប់
ខេត្តព្រះសីហនុ
📞 016 885 234

## ខេត្តកោះកុង

### សាខាក្រុងខេមរភូមិន្ទ
ភូមិ១ សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង
016 888 428

## ខេត្តបាត់ដំបង

### សាខា ខេត្តបាត់ដំបង
ផ្ទះលេខ៦៣៩ ផ្លូវជាតិលេខ៥ ភូមិរំចេក៤ សង្កាត់រតនៈ
ក្រុងបាត់ដំបង ខេត្តបាត់ដំបង
015 885 166

### សាខា ស្រុកមោងឫស្សី
ផ្លូវជាតិលេខ៥ ភូមិពោធិ៍២ ឃុំគារ ស្រុកមោងឫស្សី
ខេត្តបាត់ដំបង
016 885 649

### សាខា ស្រុកបវេល
ផ្លូវជាតិលេខ 57B ភូមិបវេល មួយ ឃុំបវេល
ស្រុកបវេល ខេត្តបាត់ដំបង
016 888 701

### សាខា ស្រុកភ្នំព្រឹក
ភូមិភ្នំតូច ឃុំពេជ្រចិន្តា ស្រុកភ្នំព្រឹក
ខេត្តបាត់ដំបង
015 885 619

### សាខា ស្រុករតនមណ្ឌល
ផ្លូវជាតិលេខ៥៧ ភូមិស្ដៅ ឃុំស្ដៅ ស្រុករតនមណ្ឌល
ខេត្តបាត់ដំបង
016 888 537

## ខេត្តត្បូងឃ្មុំ

### សាខា ក្រុងសួង
ផ្លូវជាតិលេខ៧ ភូមិជ្រៃបិទមាស សង្កាត់សួង
ក្រុងសួង ខេត្តត្បូងឃ្មុំ
016 888 623

## ខេត្តប៉ៃលិន

### សាខា ក្រុងប៉ៃលិន
ភូមិអូរតាពុកលើ សង្កាត់ប៉ៃលិន ក្រុងប៉ៃលិន
ខេត្តប៉ៃលិន
016 888 515

## ខេត្តមណ្ឌលគិរី

### សាខា ក្រុងសែនមនោរម្យ
ផ្លូវជាតិលេខ៧៦ ភូមិកណ្ដាល សង្កាត់ស្ពានមានជ័យ
ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី
016 888 365

## ខេត្តស្ទឹងត្រែង

### សាខាក្រុងស្ទឹងត្រែង
ផ្លូវលេខ ៦៤ ភូមិរាជានុកូល សង្កាត់ស្ទឹងត្រែង
ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង
016 888 478



## ខេត្តព្រះវិហារ

### សាខា ក្រុងព្រះវិហារ
ភូមិសំរោង សង្កាត់កំពង់ប្រណាក ក្រុងព្រះវិហារ
ខេត្តព្រះវិហារ
015 885 677

## ខេត្តរតនគិរី

### សាខា ខេត្តរតនគិរី
ផ្លូវជាតិលេខ៧៨ ភូមិភ្នំស្វាយ សង្កាត់បឹងកន្សែង
ក្រុងបានលុង ខេត្តរតនគិរី
070 925 555

## ខេត្តឧត្តរមានជ័យ

### សាខាស្រុកអន្លង់វែង
ភូមិអូរជញ្ជៀន ឃុំអន្លង់វែង ស្រុកអន្លង់វែង
ខេត្តឧត្តរមានជ័យ
016 888 721

## ខេត្តសៀមរាប

### សាខា ក្រុងសៀមរាប
ភូមិចុងកៅស៊ូ សង្កាត់ស្លក្រាម ក្រុងសៀមរាប
ខេត្តសៀមរាប
015 885 373

## ខេត្តបន្ទាយមានជ័យ

### សាខាក្រុងសេរីសោភ័ណ
ផ្លូវជាតិលេខ៥ ភូមិ៤ សង្កាត់ព្រះពន្លា
ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ
093 777 855

## ខេត្តពោធិ៍សាត់

### សាខា ស្រុកបាកាន
ផ្លូវជាតិលេខ៥ ភូមិខ្នាចរមាស ឃុំបឹងខ្នារ ស្រុកបាកាន
ខេត្តពោធិ៍សាត់
070 888 436

## ខេត្តក្រចេះ

### សាខា ក្រុងក្រចេះ
ផ្លូវជាតិលេខ៧ ភូមិអូរឫស្សី១ សង្កាត់អូរឫស្សី
ក្រុងក្រចេះ ខេត្តក្រចេះ
015 885 565

### សាខា ស្រុកស្នួល
ផ្ទះលេខ១៣៣អា ផ្លូវជាតិលេខ៧ ភូមិផ្សារស្នួល
ឃុំស្នួល ស្រុកស្នួល ខេត្តក្រចេះ
015 885 613

## ខេត្តកំពង់ធំ

### សាខា ក្រុងស្ទឹងសែន

ផ្លូវជាតិលេខ៦ ភូមិកំពង់ក្របៅ សង្កាត់កំពង់ក្របៅ
ក្រុងស្ទឹងសែន

016 885 120

## ខេត្តស្វាយរៀង

### សាខា ក្រុងបាវិត

ផ្លូវជាតិលេខ១ ភូមិបាវិតលើ សង្កាត់បាវិត
ក្រុងបាវិត ខេត្តស្វាយរៀង

081 899 995

## ខេត្តកំពង់ឆ្នាំង

### សាខា ស្រុកកំពង់ត្រឡាច

ផ្លូវជាតិលេខ៥ ភូមិច្រករមៀត ឃុំឈូកស
ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង

086 744 442








# អេស ប៊ី អាយ លី ហួរ
## អាយ ប៊េងឃីង




ធនាគារតាមប្រព័ន្ធអ៊ីនធឺណិត គ្រប់ពេល គ្រប់ទីកន្លែង ប្រកបដោយទំនុកចិត្ត

គ្រប់ទីកន្លែង

គ្រប់ពេល

ប្រកបដោយទំនុកចិត្ត



# ធនាគារមានភាពច្នៃប្រឌិត
# និងគួរឱ្យទុកចិត្ត ដើម្បីភាពរីកចម្រើន

ទាញយកឥឡូវនេះ
SBI LY HOUR Bank App

ទូរសព្ទ: (+៨៥៥) ២៣ ៩៨០ ៨៨៨ / (+៨៥៥) ៩៣ ៦៧១ ១១១
អ៊ីម៉ែល: info@sbilhbank.com.kh គេហទំព័រ: www.sbilhbank.com.kh
អាសយដ្ឋាន: អគារលេខ ២១៩ ផ្លូវ ១២៨ និង ១៦៩ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ